**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**

**និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**


**របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា**

# ការអភិវឌ្ឍរបស់ឃុំជីរោទ៍ទី២

កម្មសិក្សាពីថ្ងៃទី ១៧ មេសា ដល់ថ្ងៃទី ៣០ មេសា ឆ្នាំ ២០១៩

ឈ្មោះស្ថាប័ន៖ **ឃុំជីរោទ៍ទី២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ**


តាក់តែងឡើងដោយ

និស្សិតឈ្មោះ **ខាន់ សុធារៈ**

**តន លីណា**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ឈុន ពហុ**


ថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្ត្រសេដ្ឋកិច្ច

ឆ្នាំចូលសិក្សា ២០១៥

ជំនាញ សេដ្ឋកិច្ចអភិវឌ្ឍន៍ ជំនាន់ទី៣

ឆ្នាំសរសេររបាយការណ៍ ២០១៩

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ ខាន់ សុធារៈ និង ភន លីណា ជានិស្សិតផ្នែកបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ជំនាន់ទី៣ក្រុមD4C1នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

## សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ

- **លោកអ្នកមានគុណទាំងពីររូប**របស់យើងខ្ញុំដែលបានផ្តល់កំណើត និង ខិតខំប្រឹងប្រែងបីបាច់ថែរក្សា ទូន្មានអប់រំដើម្បីអោយយើងខ្ញុំដើរលើមាគាដ៏ត្រឹមត្រូវតាំងពីតូចរហូតដល់ធំពេញវ័យ។ លោកទាំងពីរផ្គត់ផ្គង់អ្វីៗគ្រប់បែបយ៉ាងទាំងកម្លាំងកាយ កម្លាំងចិត្ត ថវិកាគ្រប់យ៉ាងដើម្បីឱ្យយើងខ្ញុំមានកាសទទួលបានការអប់រំចាប់តាំងពីថ្នាក់បឋមសិក្សារហូតដល់យើងខ្ញុំបញ្ចប់ថ្នាក់បរិញ្ញាបត្រជាស្ថាពរ។
- ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ប្រធានការិយាល័យសិក្សា និង បណ្ឌិតសាស្ត្រាចារ្យគ្រប់មុខវិជ្ជាទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំប្រឹងប្រែងអស់ពីសមត្ថភាពអស់ពីកម្លាំងកាយចិត្តក្នុងការបង្រៀន ការអប់រំយ៉ាងយកចិត្តទុកដាក់ និង បានផ្តល់ចំណេះដឹងគ្រប់យ៉ាងដល់យើងខ្ញុំទាំងអស់គ្នាក្នុងអំឡុងការសិក្សារយៈពេល៤ឆ្នាំឯកន្លងមកនេះ។
- លោកសាស្ត្រាចារ្យបណ្ឌិត **ឈុន ពេហុ** ជាសាស្ត្រាចារ្យណែនាំយើងខ្ញុំបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការណែនាំជាមតិយោបល់ ការប្រមូលរាល់ទិន្នន័យឯកសារ និង ជួយត្រួតពិនិត្យកែតម្រូវកិច្ចការស្រាវជ្រាវរបស់យើងខ្ញុំរហូតទទួលបានជោគជ័យជាស្ថាពរ។
- អ្នកគ្រូ សំណាង ផលដេត ដែលបានជួយក្នុងការសម្របសម្រួលលិខិតស្នើសុំចុះស្រាវជ្រាវឯកសារ ប្រកបដោយភាពរលូន
- លោកមេឃុំសាលាឃុំជីពោទ៍ទី២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ព្រមទាំងជំទប់១ ជំទប់ទី២ និង ស្មៀនឃុំ ដែលបានអនុញ្ញាត និងផ្តល់នូវឯកសារសំខាន់ៗ ព្រមទាំងផ្តល់បទសម្ភាសដល់យើងខ្ញុំ។

ជាទីបញ្ចប់ យើងខ្ញុំសូមគោរពជូនពរដល់លោកអ្នកមានគុណទាំងពីរ ឯកឧត្តមលោក លោកស្រីសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូគ្រប់ៗរូប ប្រកបដោយសេចក្តីសុខចម្រើន មានសុភមង្គលល្អអាយុយឺនយូរ និងជួបតែពុទ្ធពរទាំងបួនប្រការគឺ អាយុវណ្ណៈ សុខៈ ពលៈ កុំបីអាក់ខានឡើយ។

# អារម្ភកថា

យើងខ្ញុំជានិស្សិតឆ្នាំទី៤ផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញ សេដ្ឋកិច្ចអភិវឌ្ឍន៍ នៃសាកលវិទ្យាល័យភូមិនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ យើងខ្ញុំបានសម្រេចធ្វើការជ្រើសរើសយកការចុះកម្មសិក្សា និងសរសេររបាយការណ៍កម្មសិក្សា នៅក្នុងឆមាសទី២ នៃឆ្នាំទី៤ដើម្បីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំកន្លងមក ដោយមានការអនុញ្ញាតឱ្យសរសេររបាយការណ៍កម្មសិក្សា ឬ សារណា ពីខាងសាលា យើងខ្ញុំ បានមានចំណាប់អារម្មណ៍ និងចង់ស្វែងយល់ពីដំណើរការអភិវឌ្ឍរបស់ឃុំមួយនៅខេត្តត្បូងឃ្មុំជាខេត្តដែលទើបនឹងបង្កើតថ្មី ជាកន្លែងសម្រាប់ចុះកម្មសិក្សា និងសរសេររបាការណ៍កម្មសិក្សា ក្រោមប្រធានបទ ការអភិវឌ្ឍរបស់ឃុំជីរោទ៍ទី២ នៅស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

ក្នុងការធ្វើរបាយការណ៍កម្មសិក្សានេះ បានផ្តល់នូវបទពិសោធន៍ ចំណេះដឹងជាច្រើនក្នុងការអភិវឌ្ឍជាក់ស្តែង។ មួយវិញទៀតយើងខ្ញុំបានយល់ដឹងពីការជួបប្រទះបញ្ហាប្រឈម និង ដំណោះស្រាយនៃការអភិវឌ្ឍរបស់ឃុំជីរោទ៍ទី២ផ្ទាល់តែម្តង។ ការធ្វើសិក្សាស្រាវជ្រាវមួយនេះគឺបានពង្រីកចំណេះដឹងនិងផ្សារភ្ជាប់ជាមួយការសិក្សានៅទ្រឹស្តីនៅសាកលវិទ្យាល័យនឹងមានការអនុវត្តជាក់ស្តែងក្នុងការដំណើរការអភិវឌ្ឍរបស់ឃុំជីរោទ៍ទី២។

យើងខ្ញុំសង្ឃឹមថា របាយការណ៍មួយនេះនឹងបានផ្តល់នូវប្រយោជន៍ច្រើនក្នុងការសិក្សាស្វែងយល់កាន់តែច្បាស់ និងបានឆ្លុះបញ្ចាំងពីដំណើរការអភិវឌ្ឍឃុំ ព្រមទាំងធ្វើជាឯកសារជំនួយដល់មិត្តនិស្សិត ដែលសរសេរសារណា ឫរបាយការណ៍បញ្ចប់ការសិក្សានៅជំនាន់ក្រោយៗទៀត។

ជាចុងបញ្ចប់ យើងខ្ញុំទាំងពីរសូមអភ័យទោសចំពោះកំហុសឆ្គងដែលកើតឡើងដោយអចេតនាក្នុងប្រការណាមួយនៅក្នុងកិច្ចការស្រាវជ្រាវបញ្ចប់ឆ្នាំសិក្សាមួយនេះ។ យើងខ្ញុំរីករាយនឹងទទួលនូវការរិះគន់ ការកែលម្អនូវរាល់ចំណុចខ្វះខាតទាំងអស់ អំពីមិត្តអ្នកអានទាំងអស់។

# មាតិកា

ទំព័រ

បញ្ជីអក្សរកាត់.....vi

បញ្ជីតារាង.....vii

បញ្ជីក្រាហ្វិក.....viii

បញ្ជីឧបសម្ព័ន្ធ.....ix

## សេចក្តីផ្តើម

១. លំនាំបញ្ហា ..... ១

២. ចំណោទបញ្ហា ..... ១

៣. គោលបំណងនៃការស្រាវជ្រាវ..... ២

៤. ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ..... ២

៥. វិធីសាស្ត្រនៃការស្រាវជ្រាវ ..... ២

៦. សារៈសំខាន់នៃការស្រាវជ្រាវ ..... ៤

៧. រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ ..... ៤

## ជំពូកទី១
## រំលឹកទ្រឹស្តី និងនិយមន័យ

**១.១ ការអភិវឌ្ឍ**..... ៦

១.១.១ និយមន័យ ..... ៦

១.១.២ ទ្រឹស្តីនៃការអភិវឌ្ឍ ..... ៦

១.១.៣ កម្មវត្ថុនៃការអភិវឌ្ឍ .....៧

១.១.៤ ការអភិវឌ្ឍប្រកបដោយនិរន្តរភាព..... ៨

១.១.៥ ការអភិវឌ្ឍតាមបែបចូលរួម ..... ៩

ក. និយមន័យនៃការចូលរួម ..... ៩

ខ. កំរិតនៃការចូលរួម.....១០

គ. គោលការណ៍នៃការអភិវឌ្ឍតាមបែបចូលរួម .....១០

**១.២ គោលនិយោបាយអភិវឌ្ឍន៍ជនបទរបស់រដ្ឋាភិបាល**.....១០

១.២.១ លក្ខណៈទូទៅ ........ ១០
១.២.២ ទិសដៅនៃការអភិវឌ្ឍ ........ ១១
១.២.៣ យុទ្ធសាស្រ្តអភិវឌ្ឍន៍ជនបទ ........ ១១
១.២.៤ គោលដៅសំរាប់ការអភិវឌ្ឍន៍ជនបទ ........ ១២
**១.៣ ការអភិវឌ្ឍឃុំ សង្កាត់** ........ ១៣
**១.៤ រចនាសម្ព័ន្ធឃុំ សង្កាត់** ........ ១៤
១.៤.១ ក្រុមប្រឹក្សាឃុំ សង្កាត់ ........ ១៤
១.៤.២ មេឃុំ ចៅសង្កាត់ ........ ១៥
១.៤.៣ ជំទប់ ចៅសង្កាត់រង ........ ១៥
១.៤.៤ ស្មៀន ........ ១៥
១.៤.៥ មេភូមិ ........ ១៥
**១.៥ ស្ថានភាពទូទៅ** ........ ១៥
ក. ឃុំ សង្កាត់ និងការអភិវឌ្ឍន៍ ........ ១៥
ខ. វិមជ្ឈការ និងប្រសិទ្ធភាព ........ ១៦
គ.អភិបាលឃុំ សង្កាត់ ........ ១៧
**១.៦ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ឃុំ សង្កាត់** ........ ១៧
ក. ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ឃុំ សង្កាត់ដែលរួមមានផ្នែក ........ ១៨
ខ. ប្រភពចំណូលសំខាន់ៗរបស់ឃុំ សង្កាត់ ........ ១៨
**១.៧ មុខងាររបស់ក្រុមប្រឹក្សា សង្កាត់លើកិច្ចអភិវឌ្ឍន៍** ........ ១៩

## ជំពូកទី២

## ស្ថានភាពទូទៅជុំវិញការអភិវឌ្ឍឃុំជីពោន៍ទី២ ចាប់ពីឆ្នាំ២០១៤ ដល់២០១៧

**២.១ ស្ថានភាពទូទៅរបស់ឃុំជីពោន៍ទី២** ........ ២១
២.១.១ ទីតាំងភូមិសាស្រ្ត ........ ២១
២.១.២ ស្ថានភាពប្រជាជនរបស់ឃុំជីពោទ៍ទី២ ........ ២១
**២.២ ស្ថានភាពអភិវឌ្ឍន៍ក្នុងឃុំជីពោន៍ទី២** ........ ២២
២.២.១ ផ្នែកសេដ្ឋកិច្ច ........ ២២
២.២.១.១ វិស័យកសិកម្ម ........ ២៣

២.២.១.២ វិស័យដឹកជញ្ជូន.................................................................................................... ២៤
២.២.២ ផ្នែកសង្គមកិច្ច ..............................................................................................................២៥
២.២.២.១ វិស័យអប់រំ.................................................................................................................. ២៥
២.២.២.២ វិស័យសុខាភិបាល ........................................................................................................២៦
២.២.៣ ផ្នែកធនធានធម្មជាតិ និងបរិស្ថាន ...............................................................................២៩
២.២.៤ ផ្នែកសេវាកម្មរដ្ឋបាល និង សន្តិសុខ ............................................................................២៩
២.២.៤.១ ការងាររដ្ឋបាល .............................................................................................................២៩
២.២.៤.២ ការងារសន្តិសុខ.............................................................................................................៣០
២.២.៥ ផ្នែកយេនឌ័រ .................................................................................................................៣១
**២.៣ សកម្មភាពដែលបានអនុវត្តចន្លោះឆ្នាំ ២០១៤-២០១៧**..........................................................៣២
២.៣.១ សកម្មភាពបានអនុវត្តក្នុងឆ្នាំ២០១៤ ...............................................................................៣២
២.៣.២ សកម្មភាពបានអនុវត្តក្នុងឆ្នាំ២០១៥...................... ............................................................៣៤
២.៣.៣ សកម្មភាពបានអនុវត្តក្នុងឆ្នាំ២០១៦................................................................................៣៦
២.៣.៤ ព័ត៌មានមួយចំនួននៃសកម្មភាពបានអនុវត្តក្នុងឆ្នាំ២០១៧................................... ៣៧
**២.៤ សមិទ្ធិផលនៃការអភិវឌ្ឍ**.................................................................................................. ៣៧
**២.៥.បញ្ហាជួបប្រទះ និង ដំណោះស្រាយ**.....................................................................................៤០
២.៥.១.បញ្ហាជួបប្រទះ...................................................................................................................៤០
២.៥.២ ដំណោះស្រាយ....................................................................................................................៤១
**២.៦ ទិសដៅអនាគតក្នុងការអភិវឌ្ឍរយៈពេល៥ឆ្នាំ** (**២០១៧-២០២២**). .................... ៤៣
២.៦.១ ចក្ខុវិស័យអភិវឌ្ឍន៍. ......................................................................................................... ៤៣
២.៦.២ គោលបំណងអភិវឌ្ឍន៍.....................................................................................................៤៣
២.៦.២.១ គោលបំណងផ្នែកសេដ្ឋកិច្ច............................................................................................ ៤៣
២.៦.២.២ គោលបំណងផ្នែកសង្គមកិច្ច.......................................................................................... ៤៣
២.៦.២.៣ គោលបំណងផ្នែកការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ
បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ. ............................៤៤
២.៦.២.៤ គោលបំណងផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សារធារណៈ. .............៤៤
២.៦.៣ គោលដៅអភិវឌ្ឍន៍...........................................................................................................៤៤

២.៦.៣.១ គោលដៅផ្នែកសេដ្ឋកិច្ច........................................................................៤៤
២.៦.៣.២ គោលដៅផ្នែកសង្គមកិច្ច ........................................................................៤៥
២.៦.៣.៣ គោលដៅផ្នែកការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ...............................៤៥
២.៦.៣.៤ គោលដៅផ្នែករដ្ឋបាល និង សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ.................៤៥
២.៦.៤ យុទ្ធសាស្ត្រអភិវឌ្ឍន៍ ..........................................................................៤៦
២.៦.៤.១ យុទ្ធសាស្ត្រអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច.........................................................៤៦
២.៦.៤.២ យុទ្ធសាស្ត្រអភិវឌ្ឍន៍ផ្នែកសង្គមកិច្ច ......................................................៤៦
២.៦.៤.៣ យុទ្ធសាស្ត្រអភិវឌ្ឍន៍ផ្នែកការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធាន ធម្មជាតិ បរិស្ថាន គ្រោះមហន្តរាយ និង ការប្រែប្រួលអាកាសធាតុ............ ៤៧
២.៦.៥ យុទ្ធសាស្ត្រអភិវឌ្ឍន៍ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ............... ៤៧
២.៦.៦ ក្របខ័ណ្ឌអភិវឌ្ឍន៍ ..........................................................................៤៨

## ជំពូកទី៣

## ការពិភាក្សាលើលទ្ធផលស្រាវជ្រាវ

**៣.១ ការវិភាគលើសមិទ្ធិផល**.......................................................................៥០
៣.១.១ ការគ្រប់គ្រងរដ្ឋបាល.......................................................................៥០
៣.១.២ វិស័យសេដ្ឋកិច្ច..........................................................................៥០
៣.១.២.១ ស្ថានភាពមុខរបរចំបងក្នុងវិស័យសេដ្ឋកិច្ចរបស់ឃុំជីពោទ៍ទី២ ...................៥០
៣.១.២.២ វិស័យកសិកម្ម.......................................................................៥១
៣.១.៣ វិស័យសិប្បកម្ម .........................................................................៥២
៣.១.៤ វិស័យសេវាកម្ម .........................................................................៥៣
៣.១.៥ វិស័យឧស្សាហកម្ម .....................................................................៥៤
៣.១.៦ វិស័យសុខាភិបាល ......................................................................៥៥
៣.១.៧ វិស័យអប់រំ ..............................................................................៥៥
៣.១.៨ វិស័យគមនាគមន៍ .......................................................................៥៦
៣.១.៩ វិស័យសង្គមកិច្ច.......................................................................... ៥៧
៣.១.១០ រដ្ឋបាលសន្តិសុខ ........................................................................ ៥៧

៣.១.១១ ការលើកកម្ពស់សមាសភាពសមធម៌យេនឌ័រ និងការជួយជនរងគ្រោះ ................ ៥៨
**៣.២ បញ្ហាប្រឈម និង ដំណោះស្រាយ** ................ ៥៨
៣.២.១ បញ្ហាហេដ្ឋារចនាសម្ព័ន្ធ ................ ៥៨
៣.២.២ បញ្ហាទិន្នផលកសិកម្ម ................ ៥៩
៣.២.៣ បញ្ហាសុខាភិបាល ................ ៥៩
៣.២.៤ បញ្ហាការអប់រំ ................ ៦០
៣.២.៥ បញ្ហារដ្ឋបាល ................ ៦០
៣.២.៦ បញ្ហារដ្ឋបាលសន្តិសុខ ................ ៦១
៣.២.៧ បញ្ហាទំនាស់ដីធ្លី ................ ៦១
៣.២.៨ បញ្ហាចំណាកស្រុក ................ ៦១
**សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍**
១. សេចក្តីសន្និដ្ឋាន ................ ៦៣
២. ការផ្តល់អនុសាសន៍ ................ ៦៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

គ.ក.ន.ក : គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ

គ.ជ.អ.ប : គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

CCJAP : ភាពជាដៃគូសម្រាប់ជំនួយរកយុត្តិធម៌ដល់សហគមន៍នៅកម្ពុជា

CMAC : មជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីនកម្ពុជា

Basic Needs : តម្រូវការចាំបាច់ជាមូលដ្ឋាន

# បញ្ជីតារាង


តារាងទី១:  បង្ហាញពីប្រភេទរថយន្តដឹកអ្នកដំណើរដែលត្រូវបង់ពន្ធ ក្នុងឃុំជីរោទ៍ទី២ ............. ៥៣

តារាងទី២:  បង្ហាញពីប្រភេទរថយន្តដឹកទំនិញដែលត្រូវបង់ពន្ធ ក្នុងឃុំជរោទ៍ទី២.................... ៥៣

តារាងទី៣:  បង្ហាញពីប្រភេទរឺម៉កសណ្តោងដែលត្រូវបង់ពន្ធ ក្នុងឃុំជីរោទ៍ទី២ ........................ ៥៤

# បញ្ជីក្រាហ្វិក

ក្រាហ្វិកទី១ : ស្ថានភាពមុខរបរប្រជាជនរបស់ឃុំ ជីពាទ៍ទី២.................................................៥០

ក្រាហ្វិកទី២: ការវាយតម្លៃទិន្នផលស្រូវរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងទិន្នផលស្រូវរបស់ឃុំជីពាទ៍ទី២...................................................៥១

ក្រាហ្វិកទី៣: ស្ថានភាពការប្រើប្រាស់ផ្ទៃដីក្នុងការធ្វើស្រែរបស់ឃុំជីពាទ៍ទី២..........................៥១

ក្រាហ្វិកទី៤ : ការអនុវត្តគម្រោង ក្នុងការជួសជុល និង បង្កើតផ្លូវក្រាលគ្រួសក្រហម ..............៥៦

# បញ្ជីឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី ១** : រូបភាពផែនទីរបស់ឃុំជីរោទ៍ទី២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ

**ឧបសម្ព័ន្ធទី ២** : លទ្ធិផលនៃការអនុវត្តគម្រោង (ឆ្នាំ២០១៤,ឆ្នាំ២០១៥,ឆ្នាំ២០១៦ និង ២០១៧)

**ឧបសម្ព័ន្ធទី ៣** : តារាងក្របខ័ណ្ឌអភិវឌ្ឍន៍ឃុំ ក្នុងទិសដៅរយៈពេល៥ឆ្នាំ (២០១៧-២០២២)

**ឧបសម្ព័ន្ធទី ៤** : ការកំណត់ប្រាក់ពន្ធតាមប្រភេទមធ្យោបាយដឹកជញ្ជូន របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**ឧបសម្ព័ន្ធទី៥** : ក្របខ័ណ្ឌបទបញ្ញាតិ និងច្បាប់ ស្តីពីវិស័យសហគ្រាសធនតូច មធ្យម និងសិប្បកម្ម របស់ក្រសួងឧស្សាហាកម្ម និងសិប្បកម្ម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលធ្លាប់បានឆ្លងកាត់នូវសង្គ្រាមជាងបីទសវត្សមកហើយ។ សង្គ្រាមស៊ីវិលបានបំផ្លាញនូវហេដ្ឋារចនាសម្ព័ន្ធផ្សេងៗដូចជា ផ្លូវថ្នល់ សាលារៀន មន្ទីពេទ្យ ស្ពាន ធនាគារ ជាពិសេសបានធ្វើឲ្យបាត់បង់ធនធានមនុស្សស្ទើរតែទាំងអស់ដែលជាធនធានមួយដ៏សម្ខាន់សម្រាប់ធ្វើការអភិវឌ្ឍប្រទេសជាតិ។ ដោយសព្វថ្ងៃនេះប្រទេសកម្ពុជាគឺជា ប្រទេសកំពុងអភិវឌ្ឍន៍ ហើយកត្តាដែលចម្បងនោះ គឺជាការស្តារឡើងវិញទៅលើគ្រប់វិស័យទាំងអស់ ដើម្បីឲ្យប្រទេសមាន ការរីកចំរើន និងជឿនលឿនឆ្ពោះទៅមុខដូចបណ្តាប្រទេសអភិវឌ្ឍន៍ដទៃទៀតក្នុងពិភពលក។

ជាការពិតណាស់ ប្រទេសមួយដែលកំពុងតែប្រឈមមុខនឹងភាពក្រីក្រ និងអត្រាចំណូលនៃប្រជាជនរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រនោះ គឺជាទិសដៅនៃសកម្មភាពដ៏ចម្បង និងជាអាទិភាពខ្ពស់បំផុត គឺធ្វើការរអភិវឌ្ឍប្រទេសជាតិឲ្យរីកចម្រើន និងធ្វើយ៉ាងណាកាត់បន្ថយអត្រានៃភាពក្រីក្រនោះឲ្យនៅសល់កម្រិតទាបបំផុតតាមដែលអាចធ្វើទៅបាន។ តែការអភិវឌ្ឍនេះត្រូវរៀបចំទិសដៅឲ្យបានច្បាស់លាស់ និងហ្មត់ចត់ទើបធ្វើឲ្យកំណើនសេដ្ឋកិច្ចទទួលបានលទ្ធផលដូចដែលយើងរំពឹងទុក គឺការចូលរួមទាំង រដ្ឋាភិបាល ប្រជាជន និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួនទើបធ្វើឲ្យដំណើការអភិវឌ្ឍនេះឆ្ពោះទៅមុខបាន យ៉ាងណាមិញ ប្រទេសកម្ពុជាមានប្រជាជន៨០% ដែលជាប្រជាកសិករហើយភាគច្រើនរស់នៅតំបន់ជនបទ។ ដូច្នេះការអភិវឌ្ឍតំបន់ជនបទត្រូវយកចិត្តទុកដាក់យ៉ាងខ្លាំងក្លាដល់ជីវភាពរស់នៅរបស់ប្រជាកសិករជាសំខាន់គឺ ចំណីអាហារ ទីជំរក និងសម្លៀកបំពាក់។ ម្យ៉ាងវិញទៀតប្រទេសកម្ពុជាមានស្ថានភាពអំណោយផលដល់ការប្រកបរបរកសិកម្ម ជាហេតុដែលរដ្ឋាភិបាលបានយកចិត្តទុកដាក់លើវិស័យកសិកម្មផងដែរ។ ក្នុងន័យនេះ បើនិយាយពីការអភិវឌ្ឍជនបទ នោះយើងត្រូវតែនិយាយអំពីការអភិវឌ្ឍពីឃុំ សង្កាត់ជាមុនសិន ព្រោះថាឃុំសង្កាត់ជាផ្នែកមួយនៃជនបទ។ ដូចនេះបើឃុំ សង្កាត់មានការរីកចម្រើនហើយនៅជនបទក៏មានការរីចម្រើនដែរ។ នៅតាមជនបទមានការរីកចម្រើននោះវាប្រាកដណាស់ថា សមិទ្ធិផល និងលទ្ធផលទាំងឡាយដែលបានមកនេះនឹងបានដល់ដៃប្រជាពលរដ្ឋមូលដ្ឋានទាំងនោះដែលវាជាជំនួយ វិភាគទានដ៏ធំ និងមានប្រសិទ្ធិភាពដើម្បីរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ

## ២. ចំណោទបញ្ហា

បច្ចុប្បន្ននេះរាជរដ្ឋាភិបាល បានខិតខំប្រឹងប្រែងនឹងយកចិត្តទុកដាក់ការកសាងហេដ្ឋារចនា

សម្ព័ន្ធនានាដែលត្រូវបានបំផ្លាញដោយសារសង្គ្រាមជាងបីទសវត្ស ក្នុងគោលបំណងដើម្បីអភិវឌ្ឍន៍ប្រទេសឲ្យមានការរីកចម្រើន។ ការអភិវឌ្ឍឃុំ សង្កាត់គឺជាគោលដៅសំខាន់របស់រដ្ឋាភិបាលកម្ពុជា។ តើឃុំ សង្កាត់បានចូលរួមចំណែកអភិវឌ្ឍប្រទេសយ៉ាងណាខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

យើងខ្ញុំទាំងពីរនាក់ធ្វើការស្រាវជ្រាវក្នុងគោលបំណងដូចជា៖

- ចង់សិក្សាអំពីសកម្មភាពរបស់ឃុំចំពោះការអភិវឌ្ឍតាមមូលដ្ឋាន
- ចង់សិក្សាអំពីតួនាទីរបស់ក្រុមប្រឹក្សាឃុំក្នុងការអភិវឌ្ឍតាមមូលដ្ឋាន
- ចង់សិក្សាពីកម្រិតអភិវឌ្ឍន៍របស់ឃុំ
- ចង់សិក្សាពីការលំបាករបស់ឃុំដែលគាត់ជួបប្រទះក្នុងការអភិវឌ្ឍតាមមូលដ្ឋាន
- ចង់សិក្សាពីគម្រោងអភិវឌ្ឍន៍ និងជំនួយពីអង្គការ និងស្ថាប័ននានា។

## ៤. ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ

នៅក្នុងការសិក្សានេះយើងខ្ញុំទាំងពីរមិនបានសិក្សាអោយស៊ីជម្រៅនៅរាល់សកម្មភាពអភិវឌ្ឍន៍ទាំងអស់របស់ឃុំនោះទេ គឺយើងខ្ញុំទាំងពីរសិក្សាផ្តោតសំខាន់តែទៅលើការរៀបចំគម្រោងអភិវឌ្ឍន៍ និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានរបស់ឃុំតែប៉ុណ្ណោះ។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវអាចសម្រេចទៅបាន លុះត្រាតែយើងអាចប្រមូលបានទិន្នន័យចាំបាច់ដែលទាក់ទងទៅនឹងដំណើរការអភិវឌ្ឍ។

ដើម្បីទទួលបាននូវទិន្នន័យទាំងនេះ នៅក្នុងការសិក្សាស្រាវជ្រាវដោយប្រើប្រាស់ វិធីសាស្ត្រដែលបានអនុវត្តន៍ទៅតាមតំណាក់កាលបន្តបន្ទាប់ដូចខាងក្រោម៖

ក. កំណត់ទីតាំងក្នុងការសិក្សាស្រាវជ្រាវ

ខ. កំណត់ប្រភេទទិន្នន័យដែលត្រូវការ

គ. កំណត់ពីរបៀបនៃការប្រមូលទិន្នន័យ

ឃ. កំណត់ពីរបៀបនៃការវិភាគទិន្នន័យ។

➢ ប្រភេទទិន្នន័យ

នៅក្នុងការសិក្សាស្រាវជ្រាវនេះ បានបែងចែកទិន្នន័យជាពីរប្រភេទដូចខាងក្រោម:

- **ទិន្នន័យចំបង**

ទិន្នន័យចំបងនេះ គឺជាប្រភេទទិន្នន័យឯកសារស្តីពីការអភិវឌ្ឍរបស់ឃុំ ហើយបានចងក្រងជា

សៀវភៅ ដែលបានតម្កល់ទុកនៅក្នុងសាលាឃុំ។ ទិន្នន័យចំបង ដែលយើងខ្ញុំបានស្នើសុំឯកសារពាក់ព័ន្ធមួយចំនួនមានដូចខាងក្រោម៖

- ឯកសារគម្រោងក្នុងការអភិវឌ្ឍរបស់ឃុំជីពោទ៍ទី២ក្នុងឆ្នាំ២០១៤
- ឯកសារបានអនុវត្តគម្រោងក្នុងការអភិវឌ្ឍរបស់ឃុំជីពោទ៍ទី២ក្នុងឆ្នាំ២០១៤
- សៀវភៅកម្មវិធីវិនិយោគឃុំជីពោទ៍ទី២ក្នុងឆ្នាំ២០១៥
- សៀវភៅកម្មវិធីវិនិយោគឃុំជីពោទ៍ទី២ក្នុងឆ្នាំ២០១៦
- គម្រោងសាងសង់ផ្លូវក្រាលក្រួសក្រហម ក្នុងឆ្នាំ២០១៧
- ផែនការអភិវឌ្ឍរយៈពេល៥ឆ្នាំរបស់ឃុំជីពោទ៍ទី២ (២០១៧-២០២២)។

- **ទិន្នន័យបន្ទាប់សន្សំ**

ទិន្នន័យបន្ទាប់បន្សំ គឺជាប្រភេទទិន្នន័យដែលត្រូវបំពេញបន្ថែម ដើម្បីបង្ហាញអោយឃើញកាន់តែលម្អិតពីការអភិវឌ្ឍរបស់ឃុំជីពោទ៍ទី២។ វិធីសាស្ត្រនៃការប្រមូលទិន្នន័យបន្ទាប់បន្សំ ក្រុមយើងបានប្រើ២វិធីសាស្ត្រ មានដូចខាងក្រោម៖

១. ទំនាក់ទំនងតាមទូរស័ព្ទ: យើងខ្ញុំបានធ្វើការទំនាក់ទំនងតាមទូរស័ព្ទជាមួយប្រធានក្រុមប្រឹក្សាឃុំ (មេឃុំ) លេខាកត់ត្រាថ្មី (ស្មៀនថ្មី) និងលេខាកត់ត្រាចាស់ (ស្មៀនចាស់)

២. តាមរយៈការធ្វើអង្កេត: យើងខ្ញុំបានចុះទៅឃុំដោយផ្ទាល់ ក្នុងការពិនិត្យមើលអំពីស្ថានភាពការរស់នៅរបស់ប្រជាជន ផ្នែកហេដ្ឋារចនាសម្ព័ន វិស័យសុខាភិបាល និងការអប់រំ។

- **ប្រភពទិន្នន័យ**

ដោយកម្មវត្ថុបំណងនៃការស្រាវជ្រាវនេះ គឺផ្តោតសំខាន់ទៅលើដំណើរការអភិវឌ្ឍ របស់ឃុំជីពោទ៍ទី២ ដូចនេះទិន្នន័យ ដែលធ្វើការសិក្សាស្រាវជ្រាវនេះចង់បាន គឺមានប្រភពមកពីឃុំជីពោទ៍ទី២ ហើយយើងទទួលបានទិន្នន័យនេះដោយមាន ការយល់ព្រមពីមេឃុំផងដែរ មួយវិញទៀត ទិន្នន័យដែលទាក់ទងទៅនឹងទ្រឹស្តីយើងទទួលបានពីបណ្ណាល័យ (របាយការណ៍សិក្សា និងសៀវភៅមួយចំនួនទៀត) និងមេរៀនរបស់លោកសាស្ត្រចារ្យដែលបានបង្រៀនកន្លងមក។

- **របៀបនៃការប្រមូលទិន្នន័យ**

យើងដឹងហើយថា ទិន្នន័យណាខ្លះដែលត្រូវប្រមូល មាននៅកន្លែងណា ហើយយើងត្រូវដឹងវាថាតើវាត្រូវប្រមូលយ៉ាងដូចម្តេច?

ដើម្បីទទួលបានទិន្នន័យពីសាលាឃុំ ការស្រាវជ្រាវត្រូវរៀបចំឯកសារមួយចំនួនដូចខាងក្រោម៖

- សុំលិខិតចុះកម្មសិក្សាពីសាលាផ្ញើរទៅអោយសាលាឃុំ
- ស្នើសុំឯកសាពីសាលាឃុំ។

➢ **របៀបនៃការវិភាគទិន្នន័យ**

នៅក្នុងការសិក្សាស្រាវជ្រាវនេះ ទិន្នន័យដែលបានធ្វើការវិភាគតាមវិធីសាស្ត្រដូចខាងក្រោម៖

- ធ្វើការប្រៀបធៀបការអនុវត្តន៍ជាក់ស្តែងជាមួយទ្រឹស្តី
- ធ្វើការវិភាគអំពីកំរិតការអភិវឌ្ឍរបស់ឃុំចាប់ពីឆ្នាំ ២០១៤ ដល់ ២០១៧
- ធ្វើការវិភាគទិសដៅអនាគត់ចាប់ពីឆ្នាំ ២០១៧ ដល់ ២០២២។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះធ្វើឡើង គឺដើម្បីវាយតម្លៃនៃសកម្មភាព និងកំរិតអភិវឌ្ឍន៍ឃុំទៅលើផ្នែកអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ទន្ទឹមនឹងនេះ ការសិក្សានេះបានផ្តល់មកនៅចំណេះដឹង និងគុណសម្បត្តិដូចជា:

- ផ្តល់ចំណេះដឹងកាន់តែច្បាស់អំពីការយកចិត្តទុកដាក់របស់ឃុំ ក៏ដូចជាក្រុមប្រឹក្សាឃុំក្នុងការអភិវឌ្ឍមូលដ្ឋាន
- យល់ដឹងអំពីយុទ្ធសាស្ត្រនៃការចាត់ចែងនូវតួនាទីការងារ និងយុទ្ធសាស្ត្រការអភិវឌ្ឍរបស់ឃុំ
- ផ្តល់នូវចំណេះដឹងអំពីតួនាទី និងភារៈកិច្ចរបស់ឃុំក្នុងការរួមចំណែកអភិវឌ្ឍន៍ប្រទេស

## ៧. រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ

ចំពោះការសិក្សាស្រាវជ្រាវស្តីពីការអភិវឌ្ឍរបស់ឃុំជីពោទ៍ទី២ ត្រូវបានចែកចេញជាបួនជំពូកដូចខាងក្រោម៖

- ដំណាក់កាលទី១: ធ្វើការកំណត់អំពី សេចក្តីផ្តើម លំនាំបញ្ហា គោលបំណង វិធីសាស្ត្រ ទំហំ និងដែនកំណត់ សារៈសំខាន់។
- ដំណាក់កាលទី២: ធ្វើការរំលឹកទ្រឹស្តីទាក់ទងនឹងប្រធានបទ
- ដំណាក់កាលទី៣: សិក្សាស្រាវជ្រាវពីស្ថានភាព ទូទៅរបស់ឃុំ
- ដំណាក់កាលទី៤: ធ្វើការពិភាក្សាលើលទ្ធផលស្រាវជ្រាវអំពីការអភិវឌ្ឍរបស់ឃុំ

- ដំណាក់កាលទី៥: ធ្វើការសន្និដ្ឋាន និងធ្វើការផ្តល់អនុសាសន៍ចំពោះដំណើរការអភិវឌ្ឍ របស់ឃុំ ។

# ជំពូកទី ១

# រំលឹកទ្រឹស្តី និងនិយមន័យ

## ១.១ ការអភិវឌ្ឍ

### ១.១.១ និយមន័យ[1]

ការអភិវឌ្ឍ គឺត្រូវបានគេឱ្យនិយមន័យខុសៗគ្នាអាស្រ័យទៅតាមការយល់ឃើញរបស់អ្នកសេដ្ឋកិច្ច និងស្របទៅតាមសម័យកាលនីមួយៗ។

និយមន័យជាច្រើនផ្តោតសំខាន់ទៅលើគោលដៅ ឬក៏ចំណុចបញ្ចប់នៃគម្រោងអភិវឌ្ឍន៍ ។ ពាក្យថា អភិវឌ្ឍន៍ ត្រូវបានគេឱ្យនិយមន័យផ្សេងៗគ្នាជាច្រើនយ៉ាងដូចជា៖

**ការអភិវឌ្ឍ** គឺជាការប្រែក្លាយរចនាសម្ព័ន្ធសេដ្ឋកិច្ច-សង្គម វប្បធម៌និងស្ថាប័នដែលបង្កលក្ខណៈងាយស្រួល ឬ អំណោយផលដល់ការធ្វើអោយសេដ្ឋកិច្ចមានការរីកចម្រើន និង ធ្វើឱ្យមានកំណើនសេដ្ឋកិច្ចបានយូរ ឬ អភិវឌ្ឍន៍ជាការបង្កលក្ខណៈងាយស្រួលអោយមានកំណើនសេដ្ឋកិច្ច។

**ការអភិវឌ្ឍ** គឺជាដំណើរការនៃការធ្វើអោយប្រសើរឡើងខាងគុណភាពនៃការរស់នៅរបស់មនុស្សទាំងអស់។

**ការអភិវឌ្ឍ** គឺជាដំណើរការនៃការធ្វើអោយមានការផ្លាស់ប្តូរពីស្ថានភាពអន់ថយទៅកាន់ភាពរីកចម្រើន តែមិនធ្វើអោយប៉ះពាល់ដល់មនុស្សជំនាន់ក្រោយ។

ជាទូទៅគោលដៅការអភិវឌ្ឍ គឺធ្វើយ៉ាងណាដើម្បីកាត់បន្ថយភាពក្រីក្រ ធ្វើឲ្យប្រសើរឡើងនូវកំរិតជីវភាពរស់នៅរបស់ប្រជាជន ដែលនៅក្នុងនោះរួមមានការកើនឡើងនូវប្រាក់ចំណូល ការអប់រំ សុខភាព ដែលយ៉ាងហោចណាស់អាចបំពេញបាននូវតម្រូវការជាមូលដ្ឋានរបស់ប្រជាពលរដ្ឋការធ្វើឲ្យប្រសើរឡើងខាងសេរីភាពគ្រប់បែបយ៉ាង និងចុងបញ្ចប់រួចផុតពីភាពក្រីក្រ។

### ១.១.២ ទ្រឹស្តីនៃការអភិវឌ្ឍ

+ តាមទ្រឹស្តីលោក Micheal P.Todaro[2]

លោកយល់ឃើញថា ការអភិវឌ្ឍ អាចកើតមានឡើងនិងប្រកបដោយចីរភាពវាត្រូវបានចាប់ផ្តើមពីតំបន់នៅជនបទជាពិសេសចំពោះវិស័យកសិកម្ម។ ហើយប្រទេសមួយដែលអាចឈានទៅដល់ការអភិវឌ្ឍ យ៉ាងហោចណាស់ត្រូវមានកត្តាបីយ៉ាងតិចដូចខាងក្រោម៖

[1] ការអភិវឌ្ឍន៍របស់សហគមន៍របស់អង្គការល្ងថេរ៉ានបំរើពិភពលោកនៅខេត្តបាត់ដំបង ទំព័រ៣ និងការអភិវឌ្ឍន៍ជនបទស្រុកថ្មពួក ទំព័រទី៥

[2] Michael P.Todro Economic Development˝ Fifth Edition 1994 page 08

- ❖ កត្តាទី១ ការពន្លឿនoutputតាមរយៈការធ្វើកំណែទម្រង់ស្ថាប័ន និងបច្ចេកវិទ្យាដែលត្រូវបានរៀបចំឡើងដើម្បីបង្កើនផលិតភាពសម្រាប់កសិករតូចតាច។
- ❖ កត្តាទី២ ត្រូវបង្កើនតម្រូវក្នុងស្រុកសម្រាប់ផលិតផលកសិកម្មដែលមានប្រភពមកពីយុទ្ធសាស្ត្រអភិវឌ្ឍន៍ការងារតំបន់ជាយក្រុង។
- ❖ កត្តាទី៣ សកម្មភាពអភិវឌ្ឍជនបទដើម្បីពង្រីកកម្លាំងពលកម្មមិនមែនកសិកម្មនិងវិស័យផ្សេងៗទៀតដែលគាំទ្រដោយផ្ទាល់ ឬដោយប្រយោលពីសមាគមន៍កសិកម្ម។

+ Francophone[3]

Francophone គឺជាទ្រឹស្តីការអភិវឌ្ឍមនុស្ស(ការអភិវឌ្ឍដោយមនុស្សនិងសម្រាប់មនុស្ស)បានឲ្យនិយមន័យនៃការអភិវឌ្ឍ គឺជាការរួមផ្សំនៃការផ្លាស់ប្តូរគំនិត និងសង្គមរបស់ប្រជាជនមួយក្រុមក្នុងការរួមផ្សំផ្តល់មកវិញនូវកំណើនផ្ទួនៗ និងស្ថេរភាពនៃផលិតផលសរុបពិតរបស់ពួកគេ។ លោកបានធ្វើការបែងចែករវាងការអភិវឌ្ឍ និងសញ្ញាណផ្សេងៗទៀតដែលជានិច្ចកាលវាបានចូលរួមក្នុងការពង្រីកការកើនឡើង និងការវិវត្តន៍។ អភិវឌ្ឍន៍ជាបាតុភូតសេដ្ឋកិច្ច និងសង្គមមួយដែលទើបតែកើតមានឡើងនាពេលចុងក្រោយនេះហើយវាជាកត្តាមួយដែលខានពុំបានសម្រាប់ធ្វើឲ្យប្រទេសជឿនលឿន ប៉ុន្តែប្រសិនបើយើងចង់ឲ្យសង្គមជាតិ ទាំងមូលមានការឈានឡើងជាវិជ្ជមានលើគ្រប់វិស័យនោះយើងមិនត្រូវចំលងពីគេទាំងស្រុងនោះទេ ដោយសារតែ សេចក្តីត្រូវការជាមូលដ្ឋានតម្លៃមនុស្សរស់នៅសមរម្យជាមនុស្ស និងសេរីភាពក្នុងការធ្វើដំណើរ ត្រូវកំណត់ទៅលើមូលដ្ឋានសង្គមប្រវត្តិសាស្ត្រ ភូមិសាស្ត្រ និងស្ថាប័ននៅក្នុងប្រទេសនីមួយៗ។ លើសពីនេះទៅទៀតការអភិវឌ្ឍមានកម្មវត្ថុដូចខាងក្រោម៖

- បង្កើនសមត្ថភាពសម្រាប់ប្រទេសនៅក្នុងការដោះស្រាយបញ្ហាជាមូលដ្ឋាន
- បង្កើនកម្រិតជីវភាពសម្រាប់មនុស្សគ្រប់រូប
- បង្កើនកិត្យានុភាពខាងសេដ្ឋកិច្ចនិងសង្គមកិច្ចរបស់ប្រទេស

### ១.១.៣ កម្មវត្ថុនៃការអភិវឌ្ឍ[4]

ការអភិវឌ្ឍគឺជាប់ពាក់ព័ន្ធទៅនឹងការរស់នៅ និងការងារ។ ភាពវិចវិល និងភាពក្រខ្សត់ទាំងអស់នេះបានបង្ហាញនូវភាពមិនរីកចម្រើន ហើយគេបានជួបប្រទះវានៅគ្រប់នៅទី

[3] របាយការណ៍សិក្សាអភិវឌ្ឍសហគមន៍ភូមិព្រៃទទឹងឆ្នាំ២០១១ ទំព័រ ០៧

[4] Michael P. Todro " Economic Development" Fifth Edition 1994 page 18

កន្លែងទាំងអស់។ដូច្នេះការងារជាកត្តាចាំបាច់ណាស់ដើម្បីកាត់បន្ថយភាពក្រីក្រ។ ភាពក្រីក្របង្កឲ្យមនុស្សមានភាពអយុត្តិធម៌គំនិតប្រាជ្ញាអន់ថយព្រមទាំងអសមត្ថភាពផងដែរ។ ការអភិវឌ្ឍគឺជាការបង្កើនសមត្ថភាពដើម្បីឥទ្ធិពលរបស់ពួកគេនៅថ្ងៃអនាគតដែលមានអត្ថន័យផ្ទាល់របស់វា:

- ទី១ មានន័យថាយកចិត្តទុកដាក់លើសមត្ថភាពលើអ្វីដែលត្រូវពង្រឹងសមត្ថភាព នឹងថាមពលដើម្បីធ្វើការផ្លាស់ប្តូរ។
- ទី២ គឺចូលរួមដោយសមត្ថភាព។ ការយកចិត្តទុកដាក់លើក្រុមផ្សេងៗមិនស្មើគ្នានិងធ្វើឲ្យប្រជាជនមានការបែងចែក ដែលអាចធ្វើឲ្យមានមហន្តរាយដល់ពួកគេ។
- ទី៣ គឺការផ្តល់អំណាចមានន័យថាបើប្រជាជនមានអំណាចខ្លះគឺពួកគេនឹងអាចទទួលបានផលចំណេញពីការអភិវឌ្ឍ។
- ទី៤ ធ្វើឲ្យមានម្ចាស់ការលើខ្លួនឯងដើម្បីឲ្យមាននិរន្តភាពទៅថ្ងៃអនាគត។

បើតាមទ្រឹស្តីលោក Michael P. Todaro ដើម្បីធ្វើឲ្យជីវិតប្រសើរឡើងនោះគឺត្រូវតែអភិវឌ្ឍសង្គមទាំងមូលហើយយ៉ាងហោចណាស់ក៏ត្រូវមានគោលដៅបីដូចខាងក្រោម:

- ដើម្បីបង្កើនភាពអាចរកបាន ហើយពង្រីកនូវការចែកចាយនៅទំនិញដែលទ្រទ្រង់ជីវិតជាមូលដ្ឋានដូចជា អាហារ ជំរកស្នាក់នៅ សុខភាព សំលៀកបំពាក់ ការអប់រំ ជាដើម។
- ដើម្បីលើកស្ទួយកំរិតរស់នៅរួមទាំងការបង្កើនចំណូល ការផ្តល់ការងារ ការអប់រំ និងការយកចិត្តទុកដាក់ជាធំ លើតម្លៃមនុស្ស និង វប្បធម៌។ លើសពីនេះធ្វើឲ្យសុខភាពបុគ្គលម្នាក់ៗ កាន់តែប្រសើរឡើងថែមទៀត ព្រមទាំងពង្រឹងសមត្ថភាពមនុស្សដើម្បីអាចប្រើប្រាស់បាន។
- ដើម្បីជម្រុញតម្លៃសេដ្ឋកិច្ច និងការជ្រើសរើសរបស់សង្គមដែលអាចទទួលយកបានជាលក្ខណៈបុគ្គលផង និងជាតិផងដោយធ្វើឲ្យពួកគេមិនត្រឹមរួចផុតពីភាពអវិជ្ជានិងទុរគតភាពក្នុងការទាក់ទងទៅកាន់មនុស្សដទៃ និងមនុស្សជាតិទូទៅប៉ុណ្ណោះថែមទាំងជម្រុញឲ្យពួកគេរួចផុតពីអនិស្សរភាពនិងសេរគតិភាពទៀត។

### ១.១.៤ ការអភិវឌ្ឍប្រកបដោយនិរន្តរភាព[5]

ពាក្យ និរន្តភាព ត្រូវបានគេឲ្យនិយមន័យជាច្រើន ដោយពឹងផ្អែកទៅលើគោលគំនិតផ្សេងៗរបស់អ្នកឯកទេសក្នុងការអភិវឌ្ឍ។ ការឲ្យនិយមន័យសង្កត់ធ្ងន់ទៅលើគំនិតសំខាន់ៗដូចជាៈ

[5] របាយការណ៍បញ្ចប់ការសិក្សាឆ្នាំ ២០០៦ ដំណើរការអភិវឌ្ឍន៍របស់អង្គការអភិវឌ្ឍន៍កសិកម្មកម្ពុជាខេត្តតាកែវ ទំព័រ១២

- ការអភិវឌ្ឍដែលប្រកបដោយនិរន្តភាពអាចឆ្លើយតបទៅនឹងសេចក្តីត្រូវការក្នុងថ្ងៃនេះ ដោយគ្មានឧបសគ្គដល់លទ្ធភាពប្រជាជនដើម្បីបំពេញតម្រូវការរបស់ពួកគាត់នៅថ្ងៃស្អែក។ ប្រភពធនធានធម្មជាតិលើផែនដីមានចំនួនកំណត់របស់វា ហើយដើម្បីឲ្យធនធានធម្មជាតិទាំងនោះមានជីវិតយូរអង្វែង គឺទាមទារឲ្យមានច្បាប់ការពារគ្រប់គ្រងនិងថែរក្សា និងទាមទារការរៀបចំប្រើប្រាស់ឲ្យមានតុល្យភាពហើយនិងការពារដល់សម្បត្តិធនធានធម្មជាតិសម្រាប់តម្រូវរបស់មនុស្សជំនាន់ក្រោយៗទៀត។
- ការអភិវឌ្ឍប្រកបដោយនិរន្តភាពគឺ ផ្តល់អាទិភាពទៅលើការប្រមូលផ្តុំធនធានទាំងអស់ក្នុងមូលដ្ឋានសម្រាប់ធ្វើការវិនិយោគទុន សម្រាប់ការអប់រំបង្កើនសមត្ថភាព និងជំនាញបច្ចេកទេសដល់ប្រជាជនដើម្បី៖

- ទទួលខុសត្រូវជីវិតរស់នៅរបស់ពួកគេផ្ទាល់ក្នុងសហគមន៍ និងធនធានដែលមាន ចូលរួមដំណើរការសំរេចចិត្តផ្សេងៗយល់ព្រមក្នុងការបែងចែកនិងការទទួលខុសត្រូវសម្រាប់សុខភាពសហគមន៍ទាំងមូលធ្វើឲ្យមានការគោរពការការពារនិងការអភិរក្សបរិស្ថានដើម្បីថែរក្សាទំនាក់ទំនងមនុស្សនិងធម្មជាតិ។
- ការអភិវឌ្ឍប្រកបដោយនិរន្តភាពគឺជាការយកប្រជាជនជាធំ និងត្រូវចាត់ទុកប្រជាជនជាចំណុចដែលត្រូវយកចិត្តទុកដាក់ខ្លាំងពីព្រោះប្រជាជនជាអ្នកធ្វើឲ្យកើតមានឡើង និងបញ្ជាក់នូវការងារអភិវឌ្ឍន៍មានកំរិត។

### ១.១.៥ ការអភិវឌ្ឍន៍តាមបែបចូលរួម[6]

ដើម្បីធ្វើឲ្យការអភិវឌ្ឍអាចប្រកបបានដោយនិរន្តភាព គឺត្រូវផ្តោតទៅលើការយកចិត្តទុកដាក់ដល់ការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងសហគមន៍លើគ្រប់សកម្មភាពអភិវឌ្ឍន៍រួមទាំងមានការស្វែងរកឬសគល់នៃបញ្ហាវិភាគ បញ្ហាការប៉ាន់ប្រមាណលើការធ្វើផែនការ ការអនុវត្តគម្រោងលើផែនការ ការត្រួតពិនិត្យ ការតាមដាន និងការវាយតម្លៃលើគម្រោងផែនការជាដើម។

#### ក . និយមន័យនៃការចូលរួម

ការចូលរួមមានន័យថាគឺជាសកម្មភាពរួមគ្នាដើម្បីសំរេចទិសដៅតែមួយ។ វាមានអត្ថន័យថាមនុស្សម្នាក់ៗដែលមានការចាប់អារម្មណ៍ត្រូវតែធ្វើការចូលរួម។ ម្នាក់ៗត្រូវធ្វើការចូលរួមក្នុងការធ្វើផែនការ ការសំរេចចិត្តការអនុវត្ត និងការវាយតម្លៃសកម្មភាពតាមមូលដ្ឋានដើម្បីលុបបំបាត់នូវភាពក្រីក្រនិងដើម្បីធានានូវការអភិវឌ្ឍន៍ជានិរន្តន៍។ ការចូលរួមគឺត្រូវបានគេមើលឃើញថាជាគោលដៅ

[6] របាយការណ៍បញ្ចប់ការសិក្សាឆ្នាំ ២០០៥ ដំណើរការអភិវឌ្ឍន៍សហគមន៍ស្រុកសាមគ្គីខេត្តកំពង់ឆ្នាំងទំព័រ១២ ទំព័រ០៧

មួយផងដែរ ដែលប្រជាពលរដ្ឋត្រូវបានគេផ្តល់សិទ្ធិអំណាចក្នុងការទទួលបាននូវជំនាញចំណេះដឹង បទពិសោធន៍ និងធនធានដើម្បីឲ្យពួកគេអាចគ្រប់គ្រងដំណើរការនៃការអភិវឌ្ឍផ្ទាល់ខ្លួនរបស់ពួកគេបាន។ នៅពេលនោះការចូលរួមក្លាយជាយន្តការសម្រាប់ផ្លាស់ប្តូរដែលមានគោលបំណងផ្តល់ឲ្យអ្នកក្រីក្រនូវធនធានដែលពួកគេត្រូវការក្នុងគោលបំណងលុបបំបាត់នូវភាពក្រីក្រ(UNDP,1997)។

**ខ កំរិតនៃការចូលរួម**

ការចូលរួមរបស់ប្រជារាស្ត្រតាមមូលដ្ឋានកើតឡើងតាមកំរិតផ្សេងៗគ្នា។ ការចូលរួមកំរិតទាបបំផុតពោលគឺ ប្រជាពលរដ្ឋតាមមូលដ្ឋានគ្រាន់តែត្រូវបានប្រាប់ដោយរដ្ឋអំណាចថ្នាក់លើឲ្យអនុវត្តនូវគម្រោងកម្មវិធីសហគមន៍របស់គេតែប៉ុណោះ។ ការចូលរួមបន្ទាប់គឺថាគំនិតយោបល់និងសំណូមពររបស់ប្រជាពលរដ្ឋតាមមូលដ្ឋានត្រូវបានគេយកចិត្តទុកដាក់។ ការចូលរួមមួយកំរិតទៀតគឺថាអ្នកភូមិត្រូវបានចាត់ទុកជាដៃគូអភិវឌ្ឍន៍។ ការចូលរួមកំរិតខ្ពស់បំផុតនោះ គឺជាទស្សនៈអំពីការផ្តល់សិទ្ធអំណាចត្រូវបានយល់ជ្រួតជ្រាបហើយប្រជាពលរដ្ឋចាប់ផ្តើមគ្រប់គ្រងស្ថានភាពដែលមានផលប៉ះពាល់ទៅលើជីវិតរបស់ពួកគេ។

**គ គោលការណ៍នៃការអភិវឌ្ឍតាមបែបចូលរួម**

ចំនុចសំខាន់របស់យុទ្ធសាស្ត្រនៃការចូលរួមគឺប្រជាពលរដ្ឋដែលរស់នៅតាមជនបទ។ គ្រប់ការផ្តួចផ្តើមទាំងអស់ដើម្បីលើកកម្ពស់ការចូលរួមដែលចាប់ផ្តើមដោយតម្រូវការ ការរំពឹងទុកគំនិតយោបល់ដែលត្រូវបានលើកឡើងដោយសមាជិកសហគមន៍តាមមូលដ្ឋានក្រុមមនុស្ស និងគ្រួសារ។ ហេតុដូចនេះ គឺត្រូវគិតនៅពេលដែលធ្វើសេចក្តីសំរេចចិត្តគេត្រូវលើកអាទិភាពនៃការអភិវឌ្ឍរបស់ប្រជាពលរដ្ឋតាមមូលដ្ឋានខ្លួនឯង។

យុទ្ធសាស្ត្រនៃការចូលរួមគឺធ្វើឲ្យមានការចូលរួមពីសហគមន៍ទាំងមូលរួមទាំងស្ត្រី និងបុរស មិនថា អ្នកមាន អ្នកក្រ សហគ្រិនឯកជន វិទ្យាស្ថានសាធារណៈ អាជ្ញាធរក្នុង និងក្រៅប្រទេសជាដើម។ ការចូលរួមរបស់ពួកគេត្រូវបានជម្រុញនៅគ្រប់ដំណាក់កាលទាំងអស់ដូចជានៅពេលវិភាគស្ថានភាពពេលទិសដៅពេលរៀបចំយុទ្ធសាស្ត្រពេលអនុវត្តន៍និងពេលចុងបញ្ចប់នៅពេលត្រួតពិនិត្យតាមដាន និងវាយតម្លៃសកម្មភាពជាប្រចាំ។

## ១.២ គោលនយោបាយអភិវឌ្ឍន៍ជនបទរបស់រដ្ឋាភិបាល[7]

### ១.២.១ លក្ខណៈទូទៅ

[7] ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ៥ឆ្នាំលើកទី២(២០០១-២០០៥)ក្រសួងអភិវឌ្ឍន៍ជនបទ.ខែសីហា ឆ្នាំ២០០០ ទំព័រទី ២៦៣-២៦៦

ការអភិវឌ្ឍជនបទត្រូវបានរដ្ឋាភិបាលយកជាយុទ្ធសាស្ត្រពង្រីកគ្រឹះកិច្ចការនីតិសម្បទានិងអភិវឌ្ឍន៍ប្រទេសជាតិឲ្យមានភាពរុងរឿងតាមរយៈការជម្រុញការអភិវឌ្ឍជនបទដើម្បីជាការលើកកម្ពស់កំរិតជីវភាពរបស់ប្រជាជនបង្កើនសុខមាលភាពសាធារណៈ និងរួមចំណែក ការពារសន្តិសុខ និង ឯកភាពនៃសង្គម។

ហេតុនេះហើយទើបរាជរដ្ឋាភិបាលកម្ពុជាបានលើកឡើងនៅគោលនិយោបាយអភិវឌ្ឍន៍ជនបទ ដែលជាបន្ទាត់នយោបាយមួយជម្រុញដើម្បីជម្រុញឲ្យមានការឯកភាពគ្នាខាងផ្នែកទិសដៅយុទ្ធសាស្ត្រ និងគោលការណែនាំក្នុងការអភិវឌ្ឍន៍ជនបទឲ្យមានភាពរលូនទៅមុខ។

### ១.២.២ ទិសដៅនៃការអភិវឌ្ឍ

ទិសដៅចម្បងនៃការអភិវឌ្ឍជនបទរួមមានដូចខាងក្រោមៈ

- លើកស្ទួយកំរិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋរស់នៅតាមតំបន់ជនបទឲ្យមានស្វ័យភាពសេដ្ឋកិច្ចគ្រប់គ្រាន់ និងឈានឡើងប្រហាក់ប្រហែលបណ្តាប្រទេសក្នុងតំបន់អាស៊ីគ្នេយ៍នាពេលអនាគតដោយខិតខំបំពេញនូវតម្រូវការចាំបាច់ជាមូលដ្ឋាន (Basic Needs)កសាងហេដ្ឋារចនាសម្ព័ន្ធជនបទព្រមទាំងបង្កើននូវប្រាក់ចំណូលនិងមុខរបរក្រៅពីកសិកម្ម។
- លើកទឹកចិត្តដល់ចលនាប្រជារាស្ត្រជនបទចូលរួមក្នុងដំណាក់កាលនៃគម្រោងអភិវឌ្ឍន៍ដើម្បីធានានៅប្រសិទ្ធភាពការងារ និងភាពស្ថិតស្ថេរទៅថ្ងៃអនាគត។ ជំរុញឲ្យចលនាប្រជារាស្ត្រឲ្យមានការចូលរួមកិច្ចការពារនីតិសម្បទា ធនធានធម្មជាតិ និងបរិស្ថាននៅតំបន់ជនបទដើម្បីបង្កលក្ខណៈងាយឲ្យការរស់នៅមានតុល្យភាពជាមួយធម្មជាតិ។ រៀបចំកម្មវិធីឲ្យបានសមស្របទៅតាមលទ្ធភាព និងជំនាញសង្គមជនបទ ណែនាំប្រជាកសិករឲ្យចូលរួមចំណែកការកែលម្អផលិតកម្មកសិកម្ម ការរកទីផ្សារដែលជំរុញឲ្យសេដ្ឋកិច្ចជាតិកាន់តែល្អសើរឡើង។
- ប្រគល់សិទ្ធ និងភារៈកិច្ចជូនប្រជាកសិករជនបទឲ្យមានទំនុកចិត្តលើខ្លួនឯង ជាជាងរងចាំដំណោះស្រាយពីរដ្ឋាភិបាល ឬពីភ្នាក់ងារអភិវឌ្ឍន៍ជនបទផ្សេងៗទៀត។
- ខិតខំសហការជាមួយស្ថាប័នពាក់ព័ន្ធ ដោះស្រាយរាល់បញ្ហាកកស្ទះនៃប្រជារាស្ត្រនៅទីក្រុងដែលបង្កឡើងដោយ ការចាកចោលទីជនបទរបស់ប្រជាជនក្រីក្រមកតាំងទីលំនៅនៅទីក្រុងដោយសារសង្គ្រាម និងដោយសាភាពក្រីក្រ។

### ១.២.៣ យុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ

ឈានចេញពីទិសដៅខាងលើរាជរដ្ឋាភិបាលបានកំណត់នូវយុទ្ធសាស្ត្រមួយចំនួនដូចខាងក្រោម:

- ជម្រុញសកម្មភាពចុះស្រាវជ្រាវ និងស្រង់ទិន្នន័យនៅតាមថ្នាក់ភូមិឲ្យបានឆាប់រហ័ស ដើម្បីធ្វើជាមូលដ្ឋានបង្អែកដ៏រឹងមាំក្នុងការកសាងផែនការអភិវឌ្ឍន៍ជនបទប្រកបដោយប្រសិទ្ធភាព។
- ដំណើការការងារអភិវឌ្ឍន៍ជនបទ ដោយមានការយកចិត្តទុកដាក់ឲ្យបានខ្លាំងក្លា ក្នុងការដោះស្រាយបញ្ហាសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងសន្តិសុខនៅតំបន់ដែល បានកំណត់ជាក់លាក់ទៅតាមលំដាប់លំដោយនៃអាទិភាពសមស្របទៅតាមស្ថាន និងតំរូវការជាក់ស្តែងរបស់ប្រជាជនដោយការធ្វើវិមជ្ឈការ ទទួលខុសត្រូវជូនគណៈកម្មាធិការថ្នាក់ក្រោមក្នុងការកំណត់តំបន់គោលដៅនៅក្នុងមូលដ្ឋានរបស់គេ។
- លើកកម្ពស់កំរិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅគ្រប់តំបន់ដូចជាតំបន់មិនសូវលូតលាស់ តំបន់ដែលមានការលូតលាស់សមរម្យ និងតំបន់រីកចម្រើន។
- យកចិត្តទុកដាក់ក្នុងការសម្របសម្រួលរវាងស្ថាប័នរបស់រាជរដ្ឋាភិបាល ទីភ្នាក់ងារអន្តរជាតិ នានា ផ្នែកឯកជន និងប្រជារាស្ត្រដើម្បីរួមគ្នាក្នុងការដោះស្រាយបញ្ហាជាមូលដ្ឋានរបស់សហគមន៍ជនបទ។ ទន្ទឹមនឹងនេះជម្រុញឲ្យមានការគាំទ្រផលិតកម្ម ការបង្កើនប្រាក់ចំណូល និងផ្តល់ការងារដល់ប្រជាជន សង្កត់ធ្ងន់ទៅលើការប្រើប្រាស់បច្ចេក វិទ្យាសមស្របទៅតាមស្ថានភាពមូលដ្ឋាននីមួយៗ។
- គាំទ្រតួនាទីរបស់សហគមន៍ និងប្រជារាស្ត្រជនបទទូទៅក្នុងការដោះស្រាយនូវបញ្ហាផ្ទាល់ខ្លួន និងដោយខ្លួនឯង អាចឈានដោះស្រាយបញ្ហាសហគមន៍ទាំងមូលដែលអាចលើកទឹកចិត្តឲ្យសហគមន៍និងប្រជារាស្ត្រកាន់តែប្រសើរឡើងនូវសកម្មភាពស្វ័យឧបត្ថម និងទំនុកចិត្តលើខ្លួនឯង។ មានការគាំទ្រចំពោះមុខងារ និងតួនាទីព្រះពុទ្ធសាសនាដើម្បីរួមចំណែកការអភិវឌ្ឍន៍សហគមន៍នៅតំបន់ជនបទ។

### ១.២.៤ គោលដៅសំរាប់ការអភិវឌ្ឍជនបទ

ដើម្បីដើរតាមគោលនយោបាយអភិវឌ្ឍន៍នៅតាមជនបទ ដែលជាគោលដៅរួមឲ្យមានប្រសិទ្ធភាព ក្នុងនោះក៏ត្រូវមានការយកចិត្តទុកដាក់លើគោលដៅអភិវឌ្ឍន៍ជនបទដែលបានដាក់ចុះរួមមាន៖

**ក.គោលដៅផ្នែកសេដ្ឋកិច្ច :** កាត់បន្ថយភាពក្រីក្រតាមរយៈការលើកកម្ពស់ការងារស្តារ

នឹងអភិវឌ្ឍន៍កសិកម្មជនបទដោយផ្តល់អាទិភាពចម្បងទៅលើការដោះស្រាយបញ្ហាទឹកឲ្យបានគ្រប់គ្រាន់។ ការជម្រុញផលិតភាពកសិកម្ម ការស្វែងរកទីផ្សារកសិផល ផ្សព្វផ្សាយឲ្យមានការដាំដុះមានគុណភាព និងបច្ចេកទេសថ្មីៗប្រភពការងារក្រៅពីកសិកម្ម និងធ្វើឲ្យប្រសើរឡើងនូវកម្មវិធីអភិវឌ្ឍន៍សហគមន៍ចំរុះ។

**ខ. គោលដៅផ្នែកសង្គមកិច្ច :** ធានានូវសមធម៌ និងប្រសិទ្ធភាពនៃការបែងចែកសេវាសង្គម ជាពិសេសការផ្តល់ឱកាស និងផលប្រយោជន៍ឲ្យប្រជារាស្ត្របានទទួលនូវសេវាជាមូលដ្ឋាន។ ការលើកកម្ពស់នូវសេវាសុខាភិបាលសាធារណៈ ទឹកស្អាត និងការបង្កើនមានសុវត្ថភាពនៃជីវិត និងមានសមត្ថភាពស្វ័យសម្រេច។

**គ. គោលដៅផ្នែកសន្តិសុខ:** យកចិត្តទុកដាក់ និងរៀបចំជាគោលដៅផ្នែកសន្តិសុខដើម្បីរួមចំណែកក្នុងការអភិវឌ្ឍន៍ជនបទដោយមានគោលបំណងបំបាត់កត្តាទាំងឡាយណាដែលបានបង្ករបញ្ហាដល់សន្តិសុខនៅក្នុងតំបន់ជនបទ ដោយធ្វើសមាហរនកម្មប្រព័ន្ធអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ចទៅក្នុងសង្គមគោលនយោបាយសន្តិសុខជាតិ។

**ឃ. ការលើកកម្ពស់នៃការរស់នៅ :** ការលើកទឹកចិត្តឲ្យសហគមន៍ និងប្រជាពលរដ្ឋនៅជនបទមានការចូលរួមក្នុងដំណើរការកែលម្អឲ្យប្រសើរឡើងនូវគុណភាពនៃការរស់នៅរបស់គ្រួសារ ក៏ដូចជាសហគមន៍របស់ពួកគេដូចជា ការកែលម្អលំនៅដ្ឋាន និងបរិស្ថាន។ បង្ករលក្ខណៈឲ្យមានការចូលរួមក្នុងការកំណត់នូវដំណើរប្រព្រឹត្តទៅនៃជីវិតរបស់សង្គមព្រមទាំងការអភិវឌ្ឍន៍ផ្នែកស្មារតីរបស់ប្រជាជនក្នុងសហគមន៍។

**ង. ការលើកកម្ពស់ពុទ្ធសាសនាក្នុងការអភិវឌ្ឍន៍ជនបទ:** លើកទឹកចិត្តដល់ព្រះសង្ឃលោកអាចារ្យ ចាស់ព្រឹទ្ធាចារ្យ និងពុទ្ធសាសនិកជនដែលមានកេរ្តិ៍ឈ្មោះល្អ និងជាទីទុកចិត្តរបស់ប្រជាជនឲ្យចូលរួមលើកស្ទួយសហគមន៍តាមរយៈការដឹកនាំកម្មវិធីអភិវឌ្ឍន៍ជនបទក្នុងសហគមន៍ ឬភូមិ។

## ១.៣ ការអភិវឌ្ឍ ឃុំ សង្កាត់[8]

រដ្ឋបាលឃុំ សង្កាត់មានតួនាទីក្នុងការជម្រុញនិងគាំពារអភិបាលកិច្ចល្អ ដោយចាត់ចែងប្រើប្រាស់ធនធាននានាដែលមានប្រកបដោយចិរភាព សម្រាប់បំពេញនូវសេចក្តីត្រូវការជាមូលដ្ឋាននៅ

[8] ដកស្រង់ចេញពីនិក្ខេបបទថ្នាក់អនុបណ្ឌិតាំ លោក ជា ចំរើន ប្រធានបទ“ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់បែបវិជ្ជការ” ទំព័រ ៣៨-៤៥ និង “ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០០១”

ក្នុងឃុំ សង្កាត់របស់ខ្លួន បម្រើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋនិងគោរពផលប្រយោជន៍របស់ជាតិស្របតាមនយោបាយទូទៅរបស់រដ្ឋ។

រដ្ឋបាលឃុំ សង្កាត់មានតួនាទីពីរប្រភេទគឺ:

- តួនាទីបម្រើកិច្ចការជាមូលដ្ឋានសម្រាប់បម្រើផលប្រយោជន៍ឃុំ សង្កាត់និង ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន។
- តួនាទីជាភ្នាក់ងាររដ្ឋ ក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ។

➢ ក្នុងតួនាទីបម្រើកិច្ចការមូលដ្ឋាន រដ្ឋបាលឃុំ សង្កាត់មានភារកិច្ច:

- ធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ
- រៀបចំចាត់ចែងសេវាធារណៈចាំបាច់ និងមើលការខុសត្រូវឲ្យកិច្ចការទាំងនោះឲ្យល្អ
- លើកទឹកចិត្តឲ្យមានការបង្កើនជាសុខភាពនិងសុខុមាលភាពរបស់ប្រជាពលរដ្ឋ
- ជម្រុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងលើកកម្ពស់ការស់នៅរបស់ប្រជាពលរដ្ឋ
- ការពារ ថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ
- សម្របសម្រួលទស្សនៈរបស់ប្រជាពលរដ្ឋដើម្បីឲ្យមានការយោគយល់អធ្យាស្រ័យគ្នាទៅវិញទៅមក
- បំពេញកិច្ចការជាទូទៅដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។

ក្នុងតួនាទីជាភ្នាក់ងារតំណាងរដ្ឋ រដ្ឋបាលឃុំ សង្កាត់មានភារកិច្ចអនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធ។

ក្នុងករណីនេះអាជ្ញាធររដ្ឋអាចធ្វើប្រតិភូកម្មអំណាចដល់ឃុំ សង្កាត់ដោយភ្ជាប់ជាមួយនៅការបង្កើនសមត្ថភាពនិងផ្គត់ផ្គង់មធ្យោបាយ សម្ភារៈ ថវិកា សម្រាប់អនុវត្ត។

ប្រតិភូកម្មខាងលើនេះ ត្រូវផ្តល់ចំពោះតែសមូហភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់តែប៉ុណ្ណោះ។

➢ តួនាទីជាភ្នាក់ងារតំណាងរដ្ឋ ក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ: រដ្ឋបាលឃុំ សង្កាត់ មានភារកិច្ចអនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ។

## ១.៤ រចនាសម្ព័ន្ធឃុំ សង្កាត់

### ១.៤.១ ក្រុមប្រឹក្សាឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់ត្រូវគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ សង្កាត់។ សមាជិករបស់ក្រុមប្រឹក្សានេះមានចំនួនពីប្រាំទៅដប់មួយរូប ដោយផ្អែកតាមភូមិសាស្ត្រ និងប្រជាសាស្ត្រ។ ចំនួន

ក្រុមប្រឹក្សាជាក់ស្តែងត្រូវបានកំណត់ដោយអនុក្រឹតរបស់រាជរដ្ឋបាលភិបាល។
(ឧទាហរណ៍: ៥ ៧ ៩ ឬ១១)

ក្រុមប្រឹក្សាឃុំ សង្កាត់តំណាងឲ្យអំណាចបញ្ញតិ ហើយក៏ជាអង្គការសម្រេចធំបំផុតរបស់រដ្ឋបាលឃុំ សង្កាត់ដែរ។

**១.៤.២ មេឃុំ ចៅសង្កាត់**

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ជាមេឃុំ ចៅសង្កាត់ ដែលជ្រើសរើសចេញពីបេក្ខជន លេខលើគេ បង្អស់នៃបញ្ជីបេក្ខជន ដែលបានទទួលសម្លេងឆ្នោតច្រើនជាងគេបង្អស់។
មេឃុំ ចៅសង្កាត់ជាតំណាងឲ្យអំណាចប្រតិបត្តិ ក្នុងការរក្សាសណ្តាប់ធ្នាប់សាធារណៈនៅក្នុងរដ្ឋ បាលឃុំ សង្កាត់។

**១.៤.៣ ជំទប់ ចៅសង្កាត់រង**

រដ្ឋបាលឃុំ សង្កាត់ត្រូវមានជំនួយការជា

- ជំទប់ទី១ ចៅសង្កាត់រងទី១ : ទទួលបន្ទុកលើកិច្ចការខាងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ជំទប់ទី២ ចៅសង្កាត់រងទី២: ទទួលបន្ទុកទៅលើកិច្ចការរដ្ឋបាល សង្គមកិច្ច សេវាសាធារណៈនិងសណ្តាប់ធ្នាប់សាធារណៈ។

មេឃុំចៅសង្កាត់អាចប្រគល់ភារកិច្ចបន្ថែមលើភារកិច្ចដែលបានកំណត់ខាងលើ។

**១.៤.៤ ស្មៀន**

ឃុំ សង្កាត់មានមន្ត្រីក្របខ័ណ្ឌក្រសួងមហាផ្ទៃមួយរូបដើម្បីធ្វើជាស្មៀន។ ស្មៀននេះគឺត្រូវបានគេតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដែលមានភារកិច្ចជួយការងារក្នុងឃុំ សង្កាត់ និងធានានិរន្តភាពកិច្ចការក្នុងរដ្ឋបាលឃុំ សង្កាត់។

**១.៤.៥ មេភូមិ**

ដើម្បីលើកកម្ពស់ឲ្យមានប្រសិទ្ធភាពនៃការគ្រប់គ្រង់រដ្ឋបាលថ្នាក់ឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំជ្រើសរើសឲ្យមានមេភូមិម្នាក់ សម្រាប់ភូមិនីមួយៗចំណុះឃុំ សង្កាត់របស់ខ្លួន។ មេភូមិនេះ មិនមែនជាបុគ្គលិកនៅក្នុងក្របខ័ណ្ឌរដ្ឋទេ។ មេភូមិត្រូវរៀបចំចាត់តាំងឲ្យមានអនុប្រធានមួយរូប និងសមាជិកមួយរូបជាជំនួយការ។

**១.៥ ស្ថានភាពទូទៅ**

**ក. ឃុំ សង្កាត់ និងការអភិវឌ្ឍ**

មុខងារមួយដ៏សំខាន់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ គឺអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន។ ក្រុមប្រឹក្សាត្រូវ

ទទួលខុសត្រូវចំពោះការរៀបចំយល់ព្រមនឹងផែនការអភិវឌ្ឍន៍ ឃុំសង្កាត់ឲ្យស្របទៅ នឹងអាទិភាពអភិវឌ្ឍន៍ជាតិ។ ហើយលើសពីនេះទៅទៀតក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវតែវាយតម្លៃលើសកម្មភាពអភិវឌ្ឍន៍ដែលបានកំពុងកើតនៅក្នុងឃុំ សង្កាត់របស់ខ្លួន។ ត្រូវវាយតម្លៃសេចក្តីត្រូវការផ្សេងៗរៀបចំកម្មវិធីដែលត្រូវឆ្លើយតបទៅនឹងតម្រូវការនេះ ហើយបន្ទាប់មកទៀតត្រូវតាមដានវាយតម្លៃទៅលើលទ្ធផលនៃការអនុវត្តកម្មវិធីអភិវឌ្ឍន៍របស់ខ្លួន។

សកម្មភាពរបស់អភិវឌ្ឍន៍របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើទៅតាមតម្លាភាពរយៈពេលរាយការណ៍ប្រចាំឆ្នាំ។ ចំពោះឯកសារត្រូវចម្លងជូនក្រសួងមហាផ្ទៃ និងក្រសួងពាក់ព័ន្ធផ្សេងទៀតដើម្បីតម្កល់ទុក។ វាជាកំណត់ត្រាសាធារណៈនឹងប្រគល់ឲ្យសហគមន៍ ឬអង្គការដទៃទៀតដោយគិតជាប្រាក់។

កម្មវិធីអភិវឌ្ឍន៍មូលដ្ឋាន និងវិជ្ឈការមានរៀបចំដោយមានបណ្តុំក្រសួងមួយចំនួនដែលពាក់ព័ន្ធជាមួយ។

កម្មវិធីសម្រាប់ពង្រឹងអាជ្ញាធរមូលដ្ឋានរបស់កម្ពុជាក្នុងបរិបទនៃយុទ្ធសាស្ត្រនៃវិសហមជ្ឈការ-វិមជ្ឈការ ត្រូវបានអនុម័តដោយរដ្ឋាភិបាលកម្ពុជា។ កម្មវិធីនេះមានគោលបំណងធំៗបីគឺ:

**១**-ពង្រឹងការអភិវឌ្ឍន៍នៅមូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រតាមរយៈវិធីសាស្ត្រពហុវិស័យដែលរួមមានការផ្តល់សេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ការជម្រុញសន្តិភាព និងបង្រួបបង្រួមផ្សះផ្សាជាតិ។

**២**-ស្ថាបនាសកម្មភាពអាជ្ញាធរឃុំ សង្កាត់ និងខេត្តសម្រាប់ការចាត់ចែងអភិវឌ្ឍន៍ឲ្យមានស្ថេរភាពតាមរយៈពិសោធន៍ជាក់ស្តែង។

**៣**-បង្កើតមេរៀនសម្រាប់ការអភិវឌ្ឍន៍គោលនិយោបាយវិសហមជ្ឈការ និងវិមជ្ឈការឲ្យទទួលបានជោគជ័យ និងបានបង្ហាញថាវិសាលភាពដំណើរនៃការផែនការដែលផ្តល់គុណភាពដល់ការធ្វើផែនការអភិវឌ្ឍន៍ក្រុមប្រឹក្សាឃុំ សង្កាត់។

### ខ. វិមជ្ឈការ និងប្រសិទ្ធភាព

មូលដ្ឋាននៃអំណះអំណាងដែលបានលើកយកមកក្នុងការគាំទ្រចំពោះវិជ្ឈការពង្រឹងប្រសិទ្ធភាពនៃការបែងចែកចំពោះធនធាន នេះជាចំណង់ចំណូលចិត្តរបស់ប្រជាពលរដ្ឋក្នុងការផ្គត់ផ្គង់ទូទៅរបស់រដ្ឋបាលកណ្តាលចំពោះផ្លូវថ្នល់ និងការអប់រំមិនបានបំពេញចិត្តគណបក្សណាមួយទេ ការបែងចែកធនធានតាមរយៈវិមជ្ឈការ និងបំពេញតាមតម្រូវការនានាបានប្រសើរជាងរដ្ឋបាលកណ្តាល។ អ្នកជំនាញសេដ្ឋកិច្ចខាងវិមជ្ឈការបានអះអាងថា អំណះអំណាងប្រសិទ្ធភាពមូលដ្ឋាន

អាចត្រូវបានគេទិចទៀន និងរិះគន់ទៅលើចំណុចពីរយ៉ាង:

ទី១-មិនពាក់ព័ន្ធជាពិសេសណាមួយទៅនឹងប្រទេសកំពុងអភិវឌ្ឍន៍

ទី២-បានផ្តោតជាសំខាន់ទាំងស្រុងទៅលើប្រសិទ្ធភាព និងតម្រូវការមិនប្រងើយកន្តើយចំពោះប្រសិទ្ធភាពនៃការផ្គត់ផ្គង់។

ការអះអាងជាមូលដ្ឋានចំពោះការគាំទ្រនូវប្រព័ន្ធវិមជ្ឈការ គឺមានប្រសិទ្ធភាពច្រើនព្រោះប្រជាជនមានចំណង់ចំណូលចិត្តផ្សេងៗគ្នាដែលត្រូវបំពេញដោយមេដឹកនាំមូលដ្ឋាន។ ការបោះឆ្នោតនៅមូលដ្ឋានជាទូទៅត្រូវបានសម្រេចដោយពឹងផ្អែកលើមូលដ្ឋាននៃភាពស្មោះត្រង់ចំពោះគណបក្សនយោបាយ ឬបុគ្គលណាមួយមិនមែនផ្អែកទៅលើភាពលាយបញ្ចូលគ្នានៃកញ្ចប់ពន្ធអាករនោះទេ។

ការបោះឆ្នោតនៅមូលដ្ឋាន គឺជាការសាកល្បងសម្រាប់ការបោះឆ្នោតថ្នាក់ជាតិ។ វិមជ្ឈការគួរតែត្រូវបានទទួលនូវការត្រួតពិនិត្យអំពីឥទ្ធិពលរបស់វាទៅលើការបែងចែកឡើងវិញ(ទាំងការបែងចែកឡើងវិញជាអន្តរបុគ្គល ឬជាអន្តរយុត្តាធិការ)។ ការបែងចែកជាអន្តរបុគ្គលអាចទទួលរងឥទ្ធិពលពីវិមជ្ឈការ គឺវាអាចនាំទៅរកការអនុវត្តន៍ផ្សេងៗគ្នាចំពោះអ្នកដែលមានឋានៈស្មើគ្នានៅក្នុងប្រទេស។ ការបែងចែកឡើងវិញជាអន្តរយុត្តាធិការអាចទទួលឥទ្ធិពលអវិជ្ជមានផងដែរពីរបបវិមជ្ឈការ។ ប្រព័ន្ធវិមជ្ឈការមួយដែលក្នុងនោះចំណាយលើពន្ធអាករទាំងឡាយដែលត្រូវបានធ្វើឡើងដោយយុត្តាការរៀងៗខ្លួន និងមិនបានបែងចែកឡើងវិញនូវចំណូលនានាឲ្យយុត្តាធិការដទៃទៀត។ អាស្រ័យដូច្នេះគ្មានវិធានការណាមួយជាក់លាក់ដែលបានប្រមូលពន្ធ និងចំណូលផ្សេងៗ អាចជម្រុញឲ្យមានសមភាពកម្រិតថ្នាក់ជាតិទាំងមូលបានឡើយ។

**គ.អភិបាលឃុំ សង្កាត់**

តម្រូវការសំខាន់ដើម្បីពង្រឹង និងបង្កើនគុណភាពសេវាសាធារណៈឲ្យបានខ្ពស់ដើម្បីផ្តល់ឲ្យដល់ប្រជាពលរដ្ឋនៅជនបទ។ ទស្សនៈរបស់រដ្ឋាភិបាលបានចាត់ទុកថា ធ្វើវិសហមជ្ឈការរដ្ឋបាលមិនគ្រាន់តែជាធនធានមួយដើម្បីអភិវឌ្ឍន៍លើការផ្តល់សេវាសាធារណៈទៅក្នុងតំបន់ប៉ុណ្ណោះទេ ប៉ុន្តែវាអាចជួយជម្រុញឲ្យមានការអភិវឌ្ឍន៍រួមទាំងការពង្រីកនូវលទ្ធិប្រជាធិបតេយ្យរបស់ប្រទេសដែរ។ ទោះបីជាយ៉ាងនេះក៏ដោយនៅពេលដំណើរការវិមជ្ឈការនឹងផ្តល់នូវផលវិបាកយ៉ាងច្រើនដូចជា ការត្រួតពិនិត្យហិរញ្ញវត្ថុមិនបានគិតដល់ និងមានការកើនឡើងនូវវិសមភាពចំពោះប្រយោជន៍សាធារណៈ។ យុទ្ធសាស្ត្រនេះត្រូវបានធ្វើឡើងដោយប្រុងប្រយ័ត្ន និងគ្រប់ជ្រុងជ្រោយ។

## **១.៦ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ឃុំ សង្កាត់**[9]

---

[9] ដកស្រង់ចេញពីសៀវភៅណែនាំស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ទំព័រទី៥-១៨

ច្បាប់ស្តីពីការគ្រប់គ្រងឃុំ សង្កាត់ត្រង់មាត្រា៧៣ចែងថា ឃុំ សង្កាត់មានធនធានហិរញ្ញវត្ថុ ថវិការ និង ទ្រព្យសម្បត្តិផ្ទាល់ខ្លួន។ មាត្រា៨២ចែងថា ឃុំ សង្កាត់ត្រូវបង្កើតឲ្យមានប្រព័ន្ធគ្រប់គ្រងតាមដាន និងត្រួតពិនិត្យហិរញ្ញវត្ថុរបស់ខ្លួន។

**ក. ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ឃុំ សង្កាត់ដែលរួមមានផ្នែក**

- ថវិកាឃុំ សង្កាត់
- ប្រព័ន្ធទូទាត់ និងប្រព័ន្ធគណនេយ្យឃុំ សង្កាត់
- ការគ្រប់គ្រងចំណាយ និងលទ្ធកម្មឃុំ សង្កាត់។

វិមជ្ឈការជាគោលនយោបាយថ្មីមួយសម្រាប់ការងារអភិបាលកិច្ចនៅក្នុងប្រទេសកម្ពុជា។ ដើម្បីអនុវត្តន៍នៅគោលនយោបាយនេះបានតម្រូវឲ្យយើងខិតខំបំពេញភារៈកិច្ចរបស់ខ្លួនឲ្យបានខ្លាំងក្លា។

ឃុំ សង្កាត់មានសិទ្ធទទួលបានធនធានហិរញ្ញវត្ថុ។ ឃុំ សង្កាត់មានការទទួលខុសត្រូវចំពោះការគ្រប់គ្រងធនធានហិរញ្ញវត្ថុយ៉ាងហ្មត់ចត់ដើម្បីឲ្យសាធារណៈជនមានជំនឿក្នុងការប្រើប្រាស់ធនធានរបស់ឃុំ សង្កាត់ ។

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ត្រង់មាត្រា៧៤ចែងថា **ឃុំ សង្កាត់មានសិទ្ធទទួល ចំណូលផ្ទាល់ដែលបានមកពីចំណូលសារពើពន្ធ ចំណូលមិនមែនសារពើរពន្ធ និងកំរៃសេវាផ្សេងៗ** ត្រង់មាត្រា៨៣ចែងថា **របបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបន្ទាប់ពីបានពិភាក្សាឯកភាពជាមួយក្រសួងមហាផ្ទៃ។**

**ខ. ប្រភពចំណូលសំខាន់ៗរបស់ឃុំ សង្កាត់មាន៣ គឺ**:

- ឃុំ សង្កាត់មានអំណាចក្នុងការប្រមូលចំណូលផ្ទាល់ ដូចជាសារពើពន្ធនៅក្នុងមូលដ្ឋានលើដីធ្លី ឬអាគារ។ ក្រុមប្រឹក្សាត្រូវបានអនុញ្ញាតឲ្យយកថ្លៃឈ្នួលនៅពេលដែលខ្លួនផ្តល់សេវា ។ សេចក្តីលំអិតនឹងបញ្ជាក់នៅច្បាប់ដោយឡែក។
- ឃុំ សង្កាត់មានចំណូលពីការផ្ទេរមូលនិធិរបស់ឃុំ សង្កាត់ផងដែរ។ ចំណូលពីការផ្ទេរមូលនិធិរបស់ឃុំ សង្កាត់មានចំណែកសម្រាប់ចំណាយរដ្ឋបាល និងសម្រាប់ការអភិវឌ្ឍន៍ឃុំ សង្កាត់។ ចំណែកមូលនិធិសរុបដែលអាចផ្ទេរទៅឲ្យឃុំ សង្កាត់នីមួយៗត្រូវកំនត់ដោយរូបមន្តមួយ។
- ឃុំ សង្កាត់មានសិទ្ធទទួលចំណូលដែលបានមកពីការបំពេញភារកិច្ចដោយឃុំ សង្កាត់ជំនួសស្ថាប័នកណ្តាល រដ្ឋបាលខេត្ត-ក្រុង និងស្ថាប័នដទៃទៀតដែល

ហៅថា **ចំណូលមុខងារជាភ្នាក់ងារ** ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុវត្តន៍នីតិនានាដើម្បីធានាថាធនធានទាំងអស់ត្រូវប្រមូល និងប្រើប្រាស់ដោយមានតម្លាភាពនៃការទទួលខុសត្រូវ។

## ១.៧ មុខងាររបស់ក្រុមប្រឹក្សា សង្កាត់លើកិច្ចអភិវឌ្ឍន៍[10]

នៅថ្ងៃទី ៣០ មិថុនា ឆ្នាំ២០១២ ថ្មីៗនេះប្រជាពលរដ្ឋខ្មែរប្រហែល៥.៨៧លាននាក់ក្នុងចំណោមប្រជាពលរដ្ឋដែលមានសិទ្ធបោះឆ្នោតចំនួន៩.២លាននាក់បានចូលរួមបោះឆ្នោតទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៣។ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នៅគ្រប់ឃុំ សង្កាត់ត្រូវចាត់ចែង គ្រប់គ្រង និងអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន។

មុខងារមួយដ៏សំខាន់របស់ក្រុមប្រឹក្សាឃុំ សង្កាត់គឺអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួនឯង។ ក្រុមប្រឹក្សាត្រូវទទួលខុសត្រូវចំពោះការរៀបចំ នឹងការយល់ព្រមនិងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ឲ្យស្របទៅនឹងអាទិភាពអភិវឌ្ឍន៍ជាតិ និងតម្រូវការរបស់ប្រជាពលរដ្ឋ។ ហើយលើសពីនេះទៅទៀតក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវវាយតម្លៃទៅលើសកម្មភាពអភិវឌ្ឍន៍ដែលកំពុងកើតមានក្នុងសង្កាត់របស់ខ្លួន។ ត្រូវវាយតម្លៃសេចក្ដីត្រូវការផ្សេងៗរបស់ឃុំ និងប្រជាពលរដ្ឋ ហើយរៀបចំកម្មវិធីដែលត្រូវឆ្លើយតបទៅនឹងតម្រូវការនេះហើយបន្ទាប់មកទៀតត្រូវតាមដានវាយតម្លៃទៅលើលទ្ធផលនៃការអនុវត្តកម្មវិធីអភិវឌ្ឍន៍របស់ខ្លួន ។

សកម្មភាពអភិវឌ្ឍន៍របស់ក្រុមប្រឹក្សាត្រូវតែធ្វើទៅតាមតម្លាភាព តាមរយៈគោលការណ៍ប្រចាំឆ្នាំ។ ចំពោះឯកសារត្រូវចម្លងជូនក្រសួងមហាផ្ទៃ និងក្រសួងពាក់ព័ន្ធផ្សេងទៀតដើម្បីរក្សាទុក។ វាជាកំណត់ត្រាសាធារណៈត្រូវប្រគល់ឲ្យសហគមន៍ ឬអង្គការដទៃទៀតដោយគិតជាប្រាក់។

កម្មវិធីអភិវឌ្ឍន៍មូលដ្ឋាន និងវិមជ្ឈការបានរៀបចំដោយមានបណ្ដុំក្រសួងដែលពាក់ព័ន្ធជាមួយ។ កម្មវិធីនេះសម្រាប់ពង្រឹងអាជ្ញាធរមូលដ្ឋានរបស់កម្ពុជាក្នុងបរិបទនៃយុទ្ធសាស្ត្រវិសហមជ្ឈការ វិមជ្ឈការ ត្រូវបានអនុម័តដោយរដ្ឋាភិបាលកម្ពុជា ។ កម្មវិធីនេះមានគោលដៅធំៗ ចំនួនបីគឺ៖

- ការអភិវឌ្ឍសមត្ថភាពសមាជិកក្រុមប្រឹក្សាមូលដ្ឋាន៖ ក្រុមប្រឹក្សាមូលដ្ឋានទទួលបានសមត្ថភាពតាមរយៈការបណ្ដុះបណ្ដាល ការបង្ហាត់បង្ហាញ និងការរៀនសូត្រដកបទពិសោធន៍ពីគ្នាទៅវិញទៅមក ធ្វើបែបនេះដើម្បីឲ្យក្រុមប្រឹក្សាអនុវត្តន៍តួ

[10] ស្រង់ចេញពីរបាយការណ៍កម្មសិក្សាការគ្រប់គ្រងគម្រោងអភិវឌ្ឍន៍ឃុំ សង្កាត់ករណី ឃុំព្រៃថ្នង ស្រុកទឹកឈូ ខេត្តកំពតទំព័រទី២២-២៥

នាទី របស់ខ្លួនយ៉ាងមានប្រសិទ្ធភាព មានតម្លាភាព ជាពិសេស មានគណនេយ្យភាព។

- ការតស៊ូជាមតិដើម្បីជាប្រយោជន៍ដល់ក្រុមប្រឹក្សាមូលដ្ឋាន៖ រាល់បញ្ហា និងតម្រូវការរបស់ក្រុមប្រឹក្សាមូលដ្ឋានត្រូវបានប្រមូលផ្តុំចងក្រងយន្តការ វិធីសាស្ត្រ និងគោលដៅសម្រាប់ដោះស្រាយបញ្ហាឲ្យមានភាពច្បាស់លាស់ និងមានប្រសិទ្ធភាព។ ភាពជាដៃគូជាមួយស្ថាប័នពាក់ព័ន្ធមានភាពល្អប្រសើ ហើយការផ្សព្វផ្សាយពតិមានធ្វើឡើងដោយសមាគមក្រុមប្រឹក្សាមូលដ្ឋាន។
- ការផ្តល់សេវាបន្ថែមដល់ក្រុមប្រឹក្សាមូលដ្ឋាន ដើម្បីសម្រេចបាននៅគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍៖ អាជ្ញាធរនៅមូលដ្ឋានមានលទ្ធភាពក្នុងការផ្តល់នៅសេវា និងលើកកម្ពស់ស្តីពីការអភិវឌ្ឍដែលមានចីរភាព មានប្រសិទ្ធភាព និងមានប្រសិទ្ធផលដល់ប្រជាពលរដ្ឋរបស់ខ្លួន ។

# ជំពូកទី២
# ស្ថានភាពទូទៅជុំវិញការអភិវឌ្ឍរបស់ឃុំជីរោទ៍ទី២ចាប់ពីឆ្នាំ ២០១៤ ដល់២០១៧

## ២.១ ស្ថានភាពទូទៅរបស់ឃុំជីរោទ៍ទី២[11]

### ២.១.១ ទីតាំងភូមិសាស្រ្ត

ឃុំជីរោទ៍ទី២ ជាឃុំមួយក្នុងចំណោមឃុំទាំង១៤ ស្ថិតនៅក្នុងស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំមានចម្ងាយ៨៦គីឡូម៉ែត្រ ពីទីរួមខេត្តដែលមានព្រំប្រទល់ដូចខាងក្រោមៈ

-ខាងជើងទាល់នឹង ឃុំថ្មពេជ្រ ស្រុកត្បូងឃ្មុំ

-ខាងត្បូងទាល់នឹង ឃុំជប់ ស្រុកត្បូងឃ្មុំ

-ខាងលិចទាល់នឹង ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ

-ខាងកើតទាល់នឹង ឃុំជប់ ស្រុកត្បូងឃ្មុំ

ផ្ទៃដីសរុបរបស់ឃុំមាន ៣.១២២ហិចតា ចែកចេញជាៈ

- ផ្ទៃដីភូមិជាទីតាំងសង់លំនៅដ្ឋាន របស់ប្រជាពលរដ្ឋមានចំនួន ៥៥២ហិចតា
- ផ្ទៃដីផលិតកម្មដំណាំស្រូវវស្សាមានចំនួន ៣៥៨,៥០ហិចតា
- ផ្ទៃដីចំការរយៈពេលខ្លីមានចំនួន ៨៦ហិចតា
- ផ្ទៃដីចំការយៈពេលវែងមានចំនួន ៩២៧ហិចតា
- ផ្ទៃដីផ្សេងៗមានចំនួន ១.៣០៩,៥០ហិចតា

សណ្ឋានដីចែកចេញជា២ប្រភេទ គឺវាលទំនាបសំរាប់ដាំដុះផលិតកម្មដំណាំស្រូវរដូវវស្សានិងតំបន់ព្រៃល្បះសម្រាប់ជាកន្លែងរកអុសដុតរបស់ប្រជាពលរដ្ឋក្នុងឃុំ។ ឃុំមានហេដ្ឋារចនាសម្ព័ន្ធផ្លូវគមនាគន៍សំខាន់ៗ មានផ្លូវជាតិលេខ៧មានប្រវែង៩.០០០ម៉ែត្រ និងមានព្រំប្រទល់ ជាប់ឃុំទន្លេបិទ និងឃុំជប់ ដែលកាត់ភូមិទួលវិហារ ស្រែសៀម អណ្តូងជា និងភូមិម្រាមទាក។ មានផ្លូវលំក្រាលគ្រួសក្រហមខ្វាត់ខ្វែងកាត់ពីភូមិមួយទៅភូមិមួយមានប្រវែង១១.១៨៤ម៉ែត្រ។ ផែនទីរដ្ឋបានបែងចែកជា១២ភូមិ ក្នុងនោះមានភូមិចំការកៅស៊ូ១ភូមិ ភូមិដែលនៅដាច់ស្រយាលឆ្ងាយជាគេពីសាលាឃុំគឺភូមិជ្រោយគរ ភូមិត្រាវ ភូមិ៣២ និងភូមិទួលពន្លៃ ភូមិទាំងនេះនៅឆ្ងាយពីមណ្ឌលសុខភាពផងដែរ។

### ២.១.២ ស្ថានភាពប្រជាជនរបស់ឃុំជីរោទ៍២

[11] ដកស្រង់ចេញពីសៀវភៅកម្មវិធីវិនិយោគឆ្នាំ ២០១៥ និង ២០១៦

នៅក្នុងឃុំជីរោទ៍ទី២ មានគ្រួសារសរុបចំនួន៣,០៣៦គ្រួសារ មានប្រជាពលរដ្ឋសរុប ១៥,៤៩០ នាក់ ស្ត្រី ៧,៥០៥នាក់ ភាគរយស្ត្រីមាន ៣៧.៧១% ។ទំហំគ្រួសារមានជាមធ្យម៥នាក់ក្នុងមួយគ្រួសារ។ ប្រជាជន៩៧% នៃគ្រួសារសរុបជាកសិករ មានមុខរបរផ្នែកកសិកម្ម ផលិតកម្មដាំដុះស្រូវរដូវវស្សា បន្ទាប់បន្សំធ្វើចំការដំឡូងមី ដំឡូងជ្វា ដាំបន្លែបង្ការ និងដំណាំរួមផ្សំ។ មុខរបរចិញ្ចឹមសត្វ (គោ ក្របី ជ្រូក មាន់ ទា និងមានមុខរបរសិប្បកម្ម (ឡើងត្នោត ឡូតដូ នេសាទ តម្បាញ ចង្អេរកញ្ច្រែង................)[12]

## ២.២ ស្ថានភាពអភិវឌ្ឍន៍ក្នុងឃុំជីរោទ៍ទី២

ក្រុមប្រឹក្សាឃុំជីរោទ៍ទី២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ បានរៀបចំផែនការអភិវឌ្ឍន៍ ដោយផ្តល់ឱកាសអោយមានការចូលរួមដោយផ្ទាល់ពីប្រជាពលរដ្ឋនៅក្នុងឃុំ និងអ្នកពាក់ព័ន្ធនានានៅក្នុងដំណើរការនៃការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ឃុំរយៈពេល៥ឆ្នាំ។ ផែនការអភិវឌ្ឍន៍ ដែលបានបង្កើតឡើងនេះ មានសារៈសំខាន់ណាស់ ដើម្បីជួយតម្រង់ទិសឃុំ ក្នុងការរៀបចំ និងអនុវត្តគម្រោង ឫសកម្មភាពអភិវឌ្ឍន៍អោយឆ្លើយតបទៅនឹងតម្រូវការពិតប្រាកដដល់ប្រជាពលរដ្ឋនៅក្នុងឃុំ ជាពិសេសសំរាប់ណែនាំរាល់ការធ្វើសេចក្តីសម្រេចចិត្តអំពីការងារអភិវឌ្ឍន៍ឃុំ ការកសាងកម្មវិធីវិនិយោគឃុំប្រចាំឆ្នាំ និងការរៀបចំថវិការប្រចាំឆ្នាំរបស់ឃុំ។

ក្នុងនាមក្រុមប្រឹក្សាឃុំជីរោទ៍ទី២ សូមថ្លែងអំណរគុណដល់ប្រជាពលរដ្ឋក្នុងឃុំ ដែលបានចូលរួមលើកឡើងអំពីបញ្ហាជាក់ស្តែង ដែលបានជួបប្រទះ និងសេចក្តីត្រូវការអភិវឌ្ឍន៍នានា។ ជាមួយគ្នានេះដែរ ក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់គណៈកម្មាធិការកសាងផែនការ និងថវិការឃុំ ជនបង្គោលនានារបស់ឃុំ មន្ត្រីបច្ចេកទេសគាំទ្រឃុំ បុគ្គលិកគាំទ្របច្ចេកទេសស្រុក ទីប្រឹក្សាស្រុក តំណាងមន្ទីការិយាល័យអង្គភាព និងអង្គការមិនមែនរដ្ឋាភិបាលដែលបានចូលរួមចំណែក និងគាំទ្រនៅក្នុងដំណើរការនៃការកសាងផែនការអភិវឌ្ឍន៍ឃុំ រហូតសំរេចជាស្ថាពរ។

ក្នុងនាមក្រុមប្រឹក្សាឃុំ បានរៀបចំកម្មវិធីវិនិយោគឃុំ ដើម្បីប្រមូលផ្តុំនូវសេចក្តីត្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋក្នុងឃុំ និងកៀរគរធនធាននានាក្នុងការឆ្លើយតបទៅនឹងសេចក្តីត្រូវការជាអាទិភាពទាំងនេះ ដែលចូលរួមចំណែកដោយផ្ទាល់ដល់ជីវភាពរស់នៅ និងសុខុមាលភាពរបស់ពលរដ្ឋ។ ផែនការអភិវឌ្ឍន៍ឃុំ ក៏ត្រូវបានប្រើប្រាស់ជាមូលដ្ឋានក្នុងការធ្វើសេចក្តីសម្រេចចិត្តអំពីការងារអភិវឌ្ឍន៍ឃុំនិងប្រើប្រាស់ជាមូលដ្ឋានក្នុងការរៀបចំថវិការប្រចាំឆ្នាំរបស់ឃុំផងដែរ។

### ២.២.១.ផ្នែកសេដ្ឋកិច្ច

[12] ដកស្រង់ចេញពី សៀវភៅកម្មវិធីវិនិយោគឃុំឆ្នាំ២០១៦ និងតាមទិន្នន័យភូមិឃុំ របស់ឃុំជីរោទ៍ទី២

នៅក្នុងឃុំមានប្រជាពលរដ្ឋចំនួន៣,០៣៩គ្រួសារ ប្រកបរបរកសិកម្មជាចំបងក្នុងនោះចំនួន ២៩១៦គ្រួសារ ធ្វើស្រែជាចំបង១៣២គ្រួសារ ដាំដំណាំស្រូវរួមផ្សំ២៧គ្រួសារ មានមុខរបរសិប្បកម្មជាចំបង៩៦៨គ្រួសារ ប្រកបមុខរបរសេវាកម្មជាចំបង៥៩គ្រួសារ ប្រកបមុខរបរជំនាញ៩១៩គ្រួសារ និងគ្រួសារប្រកបមុខរបរមិនច្បាស់លាស់។ ក្នុងនោះមានប្រជាជនចេញទៅប្រកបរបរច្បាស់លាស់ក្រៅភូមិ៤០៥នាក់ ប្រជាពលរដ្ឋទាំងនោះមួយចំនួនបានទៅធ្វើការនៅក្រៅប្រទេសដូចជាៈ ប្រទេសកូរ៉េ ថៃ មួយចំនួនទៀតទៅធ្វើជាកម្មករកាត់ដេរ ឬ កម្មករសំណង់នៅរាជធានីភ្នំពេញ និងបណ្តាខេត្តផ្សេងៗ។

### ២.២.១.១ វិស័យកសិកម្ម

ឃុំមានសកម្មភាពសេដ្ឋកិច្ចខ្លាំងលើវិស័យកសិកម្ម ប្រជាពលរដ្ឋនៅពឹងផ្អែកលើមុខរបរកសិកម្ម ដែលជាប្រពៃណីរបស់ខ្លួន។ ដីបង្កបង្កើនផលស្រូវវស្សាមានចំនួន៣៥,៨៥០ហិចតា ដែលមានទិន្នផល១,៥០តោន/ហិចតា។ គ្រួសារដែលទទួលទឹកពីប្រព័ន្ធស្រោចស្រពចំនួន២៧៩គ្រួសារ។ ទោះបីឃុំមានសកម្មភាពផ្អែកសេដ្ឋកិច្ចលើវិស័យកសិកម្មជាអទិភាពក៏ដោយ តែប្រជាពលរដ្ឋជាកសិករភាគច្រើនធ្វើស្រែវស្សាតាមទំលាប់ពុំមានប្រព័ន្ធធារាសាស្ត្រផ្គត់ផ្គង់ទឹកគ្រប់គ្រាន់ដល់ការធ្វើស្រែឡើយ គឺមានផ្ទៃដី៣០,៨៥០ហិកតាពឹងផ្អែកលើទឹកភ្លៀងទាំងស្រុង និងមានផ្ទៃដីតែ៧,៦៥០ ហិកតាដែលបូមទឹកបញ្ចូលទឹកបង្ហូរប់ដោយទំនប់ប្រឡាយ។ មានគ្រួសារចំនួន១,០១៩ គ្រួសារមានដីតិចជាងមួយហិកតា និង១៣៨គ្រួសារគ្មានដីស្រែផ្ទាល់ខ្លួន បរិមាណផលស្រូវសរុបក្នុងឃុំជាមធ្យមប្រជាពលរដ្ឋម្នាក់៦៣គីឡូក្រាម ដែលអាចធានាការដោះស្រាយស្បៀងគ្រប់គ្រាន់ដល់ប្រជាពលរដ្ឋក្នុងឃុំ ត្រូវធ្វើការនាំចូលពីឃុំដទៃមួយចំនួន។ ទិន្នផលស្រូវរដូវវស្សាជាមធ្យមមានកម្រិតទាប ហើយការប្រើប្រាស់ជីគីមីក៏មានកម្រិតខ្ពស់។ ប្រជាកសិករគ្មានដីស្រែធ្វើផលិតកម្មច្រើនឡើយ ហើយក្នុងនោះមាន៤,៥៤% (ត្រូវជា១៣៨គ្រួសារ)គ្មានដីស្រែទៀតផង ពួកគាត់បានជួលស្រែគេធ្វើ ឃើញថាការងារបង្កបង្កើតផលរបស់ប្រជាពលរដ្ឋទទួលបានបច្ចេកទេសវិទ្យាផលិតកម្មទំនើបនៅមានកម្រិតទាបនៅឡើយ គួបផ្សំនឹងការអភិរក្សនិយមប្រព្រឹត្តទៅតាមទម្លាប់ពឹងផ្អែកទាំងស្រុងទៅលើធម្មជាតិ។ ការងារបង្កបង្កើតផលមានតែមួយដងក្នុងមួយឆ្នាំនៅលើផ្ទៃដីដាំដុះប្រើប្រាស់តែពូជក្នុងស្រុក ចំណេះដឹងពីបច្ចេកទេសដាំដុះរបស់ប្រជាពលរដ្ឋនៅមានកម្រិតទាប មានការប្រើប្រាស់ជីគីមីថ្នាំសម្លាប់សត្វល្អិតមិនត្រឹមត្រូវតាមបច្ចេកទេស។

ប្រជាពលរដ្ឋភាគច្រើននៅក្នុងឃុំមានមុខរបរចិញ្ចឹមសត្វ ក្នុងនោះគ្រួសារចិញ្ចឹមគោ ក្របីសរុប១.០១២គ្រួសារ គ្រួសារចិញ្ចឹមគោ ក្របី ជាកម្លាំងអូសទាញមាន៩១គ្រួសារ ហើយគ្រួសារ

ចិញ្ចឹមជ្រូកសរុប៨៤គ្រួសារ ចំនួនកសិដ្ឋានចិញ្ចឹមទា សរុប១គ្រួសារ និងគ្រួសារចិញ្ចឹមត្រីក្នុងស្រះ ៤៣គ្រួសារ។ ប្រជាពលរដ្ឋក្នុងឃុំនិយមការចិញ្ចឹមសត្វ ប៉ុន្តែការចិញ្ចឹមសត្វរបស់ប្រជាពលរដ្ឋមានតែលក្ខណៈគ្រួសារមិនទាន់មានទ្រង់ទ្រាយធំនៅឡើយ ដូចជាការចិញ្ចឹមគោ សម្រាប់តែកម្លាំងអូសទាញតែប៉ុណ្ណោះ ហើយពុំមានកសិដ្ឋានចិញ្ចឹមជ្រូកនៅឡើយទេ។ កត្តាខ្វះខាតដោយសារប្រជាពលរដ្ឋខ្វះបច្ចេកទេសចិញ្ចឹមសត្វ ភូមិខ្លះជួបប្រទះសត្វមានជម្ងឺ ដូច្នេះដើម្បីដោះស្រាយនូវបញ្ហាដែលកើតមាន និងលើកកម្ពស់ការងារចិញ្ចឹមសត្វ ឃុំមានគម្រោងផ្តល់៖

-ឥណទានប្រាក់ ដែលមានការប្រាក់ទាប ឬឥណទានសត្វ

-ផ្តល់ពូជសត្វល្អ និងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វ

-បង្កើតពេទ្យសត្វភូមិតាមរយៈការសហការជាដៃគូជាមួយអង្គការ និងមន្ទីជំនាញក្នុងការអភិវឌ្ឍឃុំ ចំពោះដំណាំរួមផ្សំ ឃុំមានដីចំការដំឡូងមី ដីចំការដំឡូងជ្វា។ នៅក្នុងឃុំមិនមានចំការទ្រង់ទ្រាយធំទេ គឺមានជាលក្ខណៈគ្រួសារដូចជាដំណាំត្រសក់ ដំណាំស្ពៃបន្តិចបន្តួចសម្រាប់ដោះស្រាយជីវភាពគ្រួសារតែប៉ុណ្ណោះ។ ជាទិសដៅដោយសក្តានុពលដីនៅក្នុងភូមិដែលសល់បំផុសអោយប្រជាពលរដ្ឋដាំដំណាំរួមផ្សំផ្សេងៗបន្ថែមក្រៅពីធ្វើស្រែដើម្បីជួយសម្រួលដោះស្រាយជីវភាពគ្រួសារ។

#### ២.២.១.២ វិស័យដឹកជញ្ជូន

ផ្លូវគោកមានសកម្មភាពសេដ្ឋកិច្ចជាចំបងរបស់ឃុំជីពោទ៍ទី២។ ឃុំមានហេដ្ឋារចនាសម្ព័ន្ធផ្លូវគមនាគមន៍កាត់ខ្វាត់ខ្វែងមានច្រើន មានផ្លូវជាតិលេខ៧ កាត់តាមភូមិទួលវិហារ ភូមិស្រែសៀម ភូមិអណ្តូងជា និងភូមិម្រាមទាក និងមានផ្លូវលំកាត់ខ្វាត់ខ្វែងគ្រប់ភូមិយ៉ាងច្រើន ចំងាយពីភូមិទៅផ្សារដែលនៅជិតបំផុតមានចំងាយ១៣គ.ម និងចំងាយពីភូមិទៅសាលាឃុំមាន៨.៥០គ.ម ទោះបីចំងាយនេះមិនជាឆ្ងាយ ប៉ុន្តែការធ្វើដំណើរមានការលំបាកតិចតួច។ មធ្យោបាយដឹកជញ្ជូនតាមកង់ម៉ូតូ ឬរ៉ឺម៉ករថយន្តផ្សេងៗ។ នៅក្នុងឃុំជាមធ្យម ១គ្រួសារមានកង់ និងរទេះ មានម៉ូតូមួយគ្រឿងក្នុងគ្រួសារ និងមានគោយន្តចំនួន១គ្រឿង រថយន្តដឹកជញ្ជូនទំនិញ៣៧គ្រឿង។ ការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនភាគច្រើនសំរាប់បំរើផលប្រយោជន៍ក្នុងគ្រួសារ(ម៉ូតូ)ចំពោះរថយន្តសម្រាប់ដឹកអ្នកដំណើរ បំរើសកម្មភាពតិចតួចផ្នែកសេវាកម្មដឹកជញ្ជូន គ្រាន់តែជាមុខរបរបន្ទាប់បន្សំ ដូចជាសកម្មភាពដឹកអ្នកដំណើរ បំរើសកម្មភាពតិចតួចប៉ុនណ្ណោះរបស់ប្រជាពលរដ្ឋនៅក្នុងឃុំ ដែលទិន្នន័យមានបង្ហាញថាគ្រួសារប្រកបមុខរបរដឹកជញ្ជូនមាន២១%។ តែនោះជាសកម្មភាពសេវាកម្មដឹកជញ្ជូនមិនមែនជាមុខរបរសំខាន់របស់ប្រជាពលរដ្ឋនៅក្នុងឃុំ តែចរាចរណ៍មានគ្រោះថ្នាក់ ចរាចរណ៍អាចកើតមាននៅក្នុង

ឃុំ បណ្តាលមកពីប្រជាពលរដ្ឋមិនចេះច្បាប់ចរាចរ ជាពិសេសក្រុមយុវជន និងក្មេងៗ។ សេវាដឹកជញ្ជូនមិនទាន់រីកចំរើននៅក្នុងឃុំ គឺមកពីកត្តាជីវភាពប្រជាពលរដ្ឋជាចំណែកមួយ និងកត្តាហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នៅក្នុងឃុំ ជាចំណែកមួយយ៉ាងសំខាន់ផងដែរ។ ដូចនេះបញ្ហាការកសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវគមនាគមន៍ក៏នៅតែមានបញ្ហាជាអាទិភាពរបស់ឃុំ ព្រោះការដឹកជញ្ជូននូវផលិតកម្មកសិកម្ម និងផលិតផលផ្សេងៗទៀត ធ្វើអោយផ្លូវដែលមានស្រាប់ពុំអាចធានាដល់ការដឹកជញ្ជូនអោយបានទាន់ពេលវេលា ដូចនេះត្រូវធ្វើការជួសជុលសារជាថ្មី និងលើកថ្មី។ ការលំបាកដែលចំពោះមុខ ឃុំលើកគម្រោងផ្លូវក្រាលគ្រួសក្រហមត្រូវជួសជុល១.៥២៣ម៉ែត្រ ត្រូវលើកថ្មី១.៥២៣ម៉ែត្រ ចូលទៅក្នុងកម្មវិធីវិនិយោគរបស់ឃុំ ព្រមទាំងទំនាក់ទំនងជាមួយសប្បុរសជននានា និងអង្គការដើម្បីជួយគាំទ្រ គឺផ្លូវលំ១ខ្សែប្រវែង៥៥០ម៉ែត្រ និងផ្លូវក្រាលគ្រួសក្រហម សំរាប់ធានាដល់ការចរាចរណ៍ទំនិញ និងសកម្មភាពសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋក្នុងឃុំ ដូចនេះឃុំមានគម្រោង៖

- សាងសង់ផ្លូវក្រាលកៅស៊ូ
- សាងសង់ផ្លូវបេតុង
- កែលម្អផ្លូវក្រាលគ្រួសក្រហម
- ជួសជុលផ្លូវដីស
- គម្រោងសាងសង់លូកាតផ្លូវ

## ២.២.២ ផ្នែកសង្គមកិច្ច

### ២.២.២.១ វិស័យអប់រំ

ការអប់រំជាតម្រូវការបន្ទាន់ និងចាំបាច់សម្រាប់ការអភិវឌ្ឍធនធានមនុស្សនៅក្នុងឃុំសម្រាប់ការវិនិយោគទៅអនាគត់។ ប៉ុន្តែស្ថានភាពអប់រំនៅក្នុងឃុំនៅតែមិនទាន់បានល្អប្រសើរឡើយ ដោយមាននៅក្នុងឃុំពុំទាន់មានសាលាមតេយ្យរដ្ឋនៅឡើយ ធ្វើអោយមានផលប៉ះពាល់ដល់កុមារ ពីអាយុ៣ឆ្នាំ ដល់៥ឆ្នាំ។ ព្រោះកុមារដែលបានឆ្លងកាត់ការសិក្សានៅកំរិតមត្តេយ្យ មិនសូវបោះបង់សាលានៅក្នុងកម្រិតបឋមឡើយ ហើយសិក្សាបានលទ្ធផលជាងកុមារដែលដល់អាយុហើយទើបចូលរៀននៅថ្នាក់បឋម ដោយមិនបានឆ្លងកាត់មត្តេយ្យសិក្សា។ កុមារពីអាយុ៦ ដល់១១ឆ្នាំ មិនបានទៅរៀនសរុបស្មើ៨.០៣% (ប្រុស៥៦នាក់)មិនទៅរៀននៅសាលាបឋមសិក្សា។ កុមារអាយុពី១២-១៤ឆ្នាំ មិនបានទៅរៀនចំនួន១០១៥នាក់ ស្មើ១,២៣% (ប្រុស៦.៥៨នាក់ ស្រី៣៥៦នាក់)។ នៅក្នុងនោះមានអ្នកមិនចេះអក្សរភាគច្រើនក្នុងចន្លោះអាយុ១៥-៦០ សរុប១៣១៩ ស្មើ១០,១២% ក្នុងនោះស្រី៥៩៥

នាក់ ស្មើ៨,៩០%អ្នកមិនចេះអក្សរភាគច្រើនក្នុងចន្លោះអាយុ២៥-៦០ឆ្នាំ ដែលមាន១០៣៣នាក់ ស្មើ ២២,៦៦%ក្នុងនោះមានស្រី៤៨៦នាក់ស្មើ២០,៥៤%។

ដើម្បីអភិវឌ្ឍន៍វិស័យអប់រំនៅក្នុងឃុំ ក្រុមព្រឹក្សាឃុំ បានបង្កើតកិច្ចសហការជាមួយមេភូមិ នាយកសាលា គ្រូបង្រៀននិងមាតាបិតាសិស្ស ពិភាក្សារិះរកមធ្យោបាយក្នុងការជំរុញអោយកុមារទាំងអស់ទៅរៀនជាប្រចាំអោយបានយ៉ាងហោចណាស់ចប់ថ្នាក់កម្រិតអនុវិទ្យាល័យ ដោយឃុំមានគម្រោងក្នុងផែនការអភិវឌ្ឍកម្មវិធីវិនិយោគ ផ្សព្វផ្សាយអោយបានទូលំទូលាយ ដល់ឪពុកម្តាយអោយនាំយកកូនមកចុះឈ្មោះចូលរៀនបានគ្រប់ៗគ្នា កម្មវិធីជម្រុញការចូលរៀននៅកម្រិតបឋមសិក្សា ដោយសាងសង់សាលាបឋមសិក្សាបន្ថែម និងអប់រំផ្សព្វផ្សាយអំពីតម្លៃនៃកាសិក្សា និងការអភិវឌ្ឍធនធានមនុស្សអោយឪពុកម្តាយរបស់សិស្សយល់ដឹងជ្រួតជ្រាបទូទាំងឃុំមុនបវេសនាកាលនៃឆ្នាំសិក្សានីមួយៗទំនាក់ទំនងជាមួយមន្ទីអប់រំបង្កើនគ្រូបង្រៀននៅកម្រិតបឋមសិក្សា ដើម្បីលើកកម្ពស់សម្ថភាពសិស្ស គ្រូបង្កើតសាលាមធ្យមសិក្សាបឋមភូមិ ដើម្បីអោយប្រជាពលរដ្ឋ ជាពិសេសសិស្សបានទទួលបានសេវាគ្រប់គ្រាន់។ កាត់បន្ថយបន្ទុកចំណាយរបស់មុខសញ្ញា អោយបានល្អជាងមុនសម្រាប់កម្មវិធីផ្តល់អាហារូបករណ៍(នៅបឋមសិក្សាបឋមភូមិ) ពង្រីកនិងកំណត់នៅមុខសញ្ញាអោយបានល្អជាងមុន សម្រាប់កម្មវិធីផ្តល់អាហារសម្រន់នៅបឋមសិក្សា និងកម្មវិធីលើកទឹកចិត្តសម្រាប់សិក្សានៅថ្នាក់ទី៧ ដល់ទី៩។ កាត់បន្ថយអក្ខរជនអោយនៅកម្រិតទាបបំផុត និងឈានទៅបំបាត់នៅពេលខាងមុខ តាមរយៈធ្វើកិច្ចសហការជាមួយមន្ទីអប់រំ អង្គការជាតិ ក្នុងការបង្កើតថ្នាក់អក្ខរកម្ម ព្រោះភាពអវិជ្ជានៃប្រជាកសិករ វាជាឧបសគ្គសម្រាប់ការអភិវឌ្ឍន៍ជីវភាពគ្រួសារ និង សង្គម។

### ២.២.២.២ វិស័យសុខាភិបាល

ស្ថានភាពសុខាភិបាលរបស់ប្រជាពលរដ្ឋក្នុងឃុំ នៅមិនទាន់បានចាត់ទុកជាល្អប្រសើរតាមបំណងប្រាថ្នាដែលបានកំណត់ឡើង នៅក្នុងគោលដៅសហវត្សរ៍ និងទិសដៅវិស័យ។ ប្រសិនបើប្រជាពលរដ្ឋមានសុខភាពល្អ ការប្រឈមមុខរបចិញ្ចឹមជីវិតបានជាប្រក្រតី មិនខាតបង់ពេលវេលា និងទ្រព្យសម្បត្តិទៀតផង។ ការមានជម្ងឺ ឬ មានសុខភាពមិនល្អជាកត្តាដ៏ចំបង ដែលនាំឲ្យគ្រួសារមួយចំនួនធ្លាក់ទៅក្នុងស្ថានភាពក្រីក្រ។ ការកែលម្អរសេវាសុខភាពដែលបានផ្តល់តាមរយៈមណ្ឌលសុភាព ការអប់រំប្រជាពលរដ្ឋនៅក្នុងឃុំឲ្យដឹងពីសារៈសំខាន់នៃការនាំកូនមកចាក់ថ្នាំបង្ការ ការប្រែទម្លាប់ពីការសម្រាលកូនដោយពេទ្យខ្មែរបុរាណ ឲ្យមកប្រើប្រាស់នៅសេវាពេទ្យឆ្មប ដែលធានានៅសុវត្ថិភាព គឺជាប្រការចាំបាច់ដែលត្រូវមានការគាំទ្រ និងការសហការទាំងប្រជាពលរដ្ឋទាំងបុគ្គលិកសុខភាពជំនាញ។ ក្នុងឃុំមានមណ្ឌលសុខភាពមួយកន្លែង ស្ថិតនៅភូមិស្រែសៀម តែទោះយ៉ាង

នេះក្តី ឆ្នាំកន្លងទៅទូទាំងឃុំមានស្ត្រីសម្រាលកូនដោយឆ្មប់បុរាណចំនួនច្រើន គឺភាគច្រើនស្ថិតនៅក្នុងភូមិដែលឆ្ងាយពីមណ្ឌលសុខភាព។ កុមារមិនទាន់ចាក់ថ្នាំបង្ការគ្រប់មុខ ស្ថិតនៅក្នុងចំនួនមរណភាពកុមារអាយុ៥ឆ្នាំ។ ឃើញទៅសម្រាលកូនដោយឆ្មប់បុរាណនៅក្នុងឃុំមានចំនួនច្រើននៅឡើយ ដែលប្រការនេះមានផលប៉ះពាល់ដល់អាយុជីវិតម្តាយ និងទាករក និងធ្វើឲ្យជួបប្រទះបញ្ហាសុខភាពទ្រុឌទ្រោមចំណាយថវិការច្រើន ក្នុងការព្យាបាលជម្ងឺធ្វើឲ្យជីវភាពគ្រួសារត្រូវធ្លាក់ចុះ។ កត្តាមិនទាន់បានទទួលយកនៅសេវាកម្មពីមណ្ឌលសុលភាពរបស់ប្រជាពលរដ្ឋមួយចំនួនធំ គឺមកពីប្រជាពលរដ្ឋនៅមិនយល់ពីផលប៉ះពាល់សុខភាព នៃការសម្រាលកូនដោយឆ្មបបុរាណមានជំនឿលើឆ្មបបុរាណទាំងពីដើមមក បញ្ហាជីវភាពប្រជាពលរដ្ឋមានការខ្វះខាតមិនអាចទទួលយកបាននូវសេវាសុខាភិបាល ដែលមានការចំណាយថវិការ។ ដើម្បីដោះស្រាយបញ្ហាខាងលើ ត្រូវបណ្តុះបណ្តាលដល់ឆ្មបដែលមានស្រាប់ជាប្រចាំឲ្យមានចំណេះដឹងពីជំនាញបន្ថែម និងផ្តល់សម្ភារៈឧបករណ៍ជាជំនួយដល់ការបម្រើសេវាឆ្មប។ ជ្រើសរើស និងបណ្តុះបណ្តាលឲ្យឆ្មបពេទ្យប្រចាំភូមិណាដែលពុំទាន់មានឆ្មបពេទ្យនៅឡើយ និងផ្សព្វផ្សាយដល់ស្ត្រីទាំងអស់ឲ្យយល់ដឹងពីសុខភាពអនាម័យ យល់ដឹងពីសញ្ញានានាដែលត្រូវប្រុងប្រយ័ត្ន នៅពេលមានផ្ទៃពោះ និងនៅពេលសម្រាលកូន ជម្រុញឲ្យស្ត្រីមាន ផ្ទៃពោះគ្រប់រូបទៅពិនិត្យផ្ទៃពោះនៅមណ្ឌលសុខភាពឲ្យបានពីរដងយ៉ាងតិច និងពង្រឹងសេវាសម្រាលកូននៅមណ្ឌលសុខភាព។

មណ្ឌលសុខភាព របស់ប្រជាពលរដ្ឋ វាមានការពាក់ព័ន្ធដល់ការប្រើប្រាស់ទឹក និងបង្គន់អនាម័យជាកត្តាសំខាន់ផងដែរ។ នៅក្នុងឃុំមានអណ្តូងស្នប់ចំនួន៥៨អណ្តូង(ខូចខាត១៨អណ្តូង) អណ្តូងលូចំនួន៥១៣អណ្តូង និងអណ្តូងដែលមិនអាចប្រើប្រាស់បាននៅរដូវប្រាំងមានអណ្តូងស្នប់ចំនួន៣០អណ្តូង និងអណ្តូងលូចំនួន៣០៩អណ្តូង។ អណ្តូងត្រូវបានជួសជុល និងស្តារមានអណ្តូងស្នប់ចំនួន១៥អណ្តូង និងអណ្តូងលូចំនួន៨៦អណ្តូង។ ប្រជាពលរដ្ឋទទួលបានពីប្រភពទឹកមិនស្អាតចំនួន១.០៧៨គ្រួសារ ប្រើប្រាស់អណ្តូងឆ្ងាយពីផ្ទះជាង១៥០ម៉ែត្រ មានចំនួន៣៦៥គ្រួសារ។ ឃើញថានៅក្នុងឃុំមានការជួបប្រទះការលំបាកពីបញ្ហាទទួលទានសេវាកម្មទឹកស្អាតសម្រាប់ប្រើប្រាស់ ដែលបញ្ហាទាំងនេះធ្វើឲ្យប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋជាចំបង ធ្វើឲ្យជីវភាពគ្រួសារគឺកាន់តែជួបប្រទះការលំបាកដោយសារតែការប្រើប្រាស់ទឹកមិនស្អាត ព្រោះមានគ្រួសារដែលប្រើប្រាស់ឧករណ៍ចម្រោះទឹកមាន៣% និងគ្រួសារមានទំលាប់ទទួលទឹកដាំពុះមាន៧០%នៃចំនួនគ្រួសារសរុប។

ការប្រើប្រាស់បង្គន់អនាម័យនៅទូទាំងឃុំឃើញថាមានប្រជាពលរដ្ឋ៨៦៦គ្រួសារស្មើនឹង ១៦,៨%ប៉ុណ្ណោះ ដែលមានបង្គន់អនាម័យប្រើប្រាស់។ ភូមិដែលមានទឹកប្រើប្រាស់ទៅដល់ផ្ទះ ការ

ប្រើប្រាស់បង្គន់អនាម័យ និងទម្លាប់ទទួលទានទឹកដាំពុះតិចជាងគេគឺភូមិបឹងត្រស់។ កត្តាដែលមិនប្រើប្រាស់បង្គន់អនាម័យ នឹងទម្លាប់ទទួលទានទឹកមិនដាំពុះរបស់ប្រជាពលរដ្ឋ។ ដូចនេះ វាធ្វើអោយប៉ះពាល់យ៉ាងខ្លាំងដល់សុខភាពរបស់ប្រជាពលរដ្ឋ នៅក្នុងឃុំនេះបញ្ជាក់អោយដឹងថាស្ថានភាពអនាម័យនៅតាមគ្រួសារនៅមានកម្រិតនៅឡើយ ដោយសារប្រជាពលរដ្ឋពុំសូវមានការយល់ដឹងពីសុខភាព និងអនាម័យ។ បញ្ហាដែលប្រជាជន និងមិនមានបង្គន់អនាម័យ។ បញ្ហាដែលប្រជាពលរដ្ឋមិនមានបង្គន់អនាម័យប្រើប្រាស់ និងមិនទម្លាប់ទឹកដាំពុះដោយសារប្រជាជនពុំទាន់មានការយល់ពីអត្ថប្រយោជន៍នៃការប្រើប្រាស់បង្គន់ ហើយម៉្យាងវាជាទម្លាប់ចាប់ពីមុនមកដែលប្រជាពលរដ្ឋមិនប្រើប្រាស់បង្គន់អនាម័យ ដោយសំអាងផ្ទះមានដីទូលាយនៅក្បែរព្រៃ។ ដើម្បីដោះស្រាយបញ្ហាសុខភាពប្រជាពលរដ្ឋ ឃុំមានទិសដៅអប់រំសុខភាពអនាម័យជូនប្រជាពលរដ្ឋពីការរស់នៅស្អាត ហូបស្អាត និងកិច្ចការពារបរិស្ថាន និងផ្លាស់ប្តូរទំលាប់ប្រជាពលរដ្ឋអោយប្រើប្រាស់បង្គន់អនាម័យដែលអាចទប់ស្កាត់បាននូវជំងឺឆ្លងនានាដល់មនុស្ស និង សត្វពាហនៈ។ ធ្វើការទំនាក់ទំនងជាមួយអង្គការជាតិ អន្តរជាតិ និងស្ថាប័នពាក់ព័ន្ធលើគម្រោងស្នើសុំបង្គន់អនាម័យ តាមគោលការណ៍ចូលរួមបដិភាគពីប្រជាពលរដ្ឋ។

នៅក្នុងឃុំមានគ្រួសារដែលមានសមាជិកកើតអេដស៍មានចំនួន១៣គ្រួសារ ចំនួនកុមារកំព្រាអាយុក្រោម១៨ឆ្នាំ ដោយសារអេដស៍ ចំនួនកុមារកំព្រាអាយុក្រោម១៨ឆ្នាំ(ទូទៅគ្រប់ករណី)ចំនួន១២នាក់។ ចំនួនមនុស្សចាស់ជរាគ្មានទីពឹងចំនួន២២នាក់ ចំនួនជនពិការមិនអាចរកចំណូលបាន៥នាក់ ចំនួនជនពិការអាយុក្រោម១៨ឆ្នាំ មានចំនួន៥នាក់។ នេះជាបន្ទុកធ្ងន់ធ្ងររបស់ឃុំដែលដែលត្រូវការជួយដោះស្រាយសម្រាប់បន្ទុកដល់ក្រុមជនងាយរងគ្រោះដែលត្រូវទទួលកិច្ចការពារ ព្រោះជនទាំងនេះជួបប្រទះនូវការលំបាកក្នុងជីវភាពគ្រួសារប្រចាំថ្ងៃមិនអាចប្រកបរបរកស៊ី នឹងដោះស្រាយជីវភាពគ្រួសារខ្លួនឯងបានស្រួលឡើយ។ បញ្ហានេះមកពីប្រជាជនមួយចំនួនមិនទាន់បានយល់អោយទូលាយ ពីបញ្ហាគ្រោះថ្នាក់ដោយសារជំងឺអេដស៍ ធ្វេសប្រហែសពីបញ្ហារួមភេទធ្វើអោយសមាជិកគ្រួសារឆ្លងជំងឺអេដស៍ស្លាប់ទុកកូនកំព្រារ។ ការមិនចាក់ថ្នាំបង្ការ និងការពិនិត្យសុខភាពអោយបានទៀងទាត់ នៅពេលមានផ្ទៃពោះធ្វើអោយកូនកើតមកពិការ និងការបន្សល់នៃជនពិការពីសង្គ្រាម។ ដើម្បីដោះស្រាយ និងជួយសម្រាល់បន្ទុកដល់ជនងាយរងគ្រោះ ឃុំមានគោលដៅសហការជាមួយអង្គការ ស្ថាប័នពាក់ព័ន្ធជួយស្តារលទ្ធភាពរាងកាយជនពិការ បណ្តុះបណ្តាលវិជ្ជាជីៈកម្មវិធីអាហាររូបត្ថម្ភ អប់រំសុខភាពបន្តពូជ សុខភាពមាតា និងកុមារ ការលុបបំបាត់មូលហេតុបណ្តាលនៃជម្ងឺ ការចាត់វិធានការបង្ការ និងការផ្តល់ការព្យាបាលដែលចាំបាច់គឺមានសារៈសំខាន់ ក្នុងការលើកកម្ពស់

ស្ថានភាពសុខភាពរបស់ប្រជាជនទូទៅ។ យកចិត្តទុកដាក់ជាពិសេសក្នុងការអប់រំផ្សព្វផ្សាយពីការកាត់បន្ថយការរីករាលដាល នៃហ៊ីវ (អេដស៍)ជាពិសេសចំពោះគ្រួសារដោយការព្យាយាមអប់រំ និងការផ្តល់ពត៌មានអោយបានទូលំទូលាយ និងមានកម្មវិធីឧបត្ថម្ភសង្គមកិច្ច។

### ២.២.៣ ផ្នែកធនធានធម្មជាតិ និងបរិស្ថាន[13]

ដោយសារឃុំនេះស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៧ និងមានព្រៃលិចទឹក ដែលជាកន្លែងសម្រាប់សត្វត្រីពង និងសម្រាប់ប្រជាពលរដ្ឋនេសាទផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ។ ព្រៃលិចទឹកនេះ មានការយកចិត្តទុកដាក់ខ្ពស់ពីប្រជាពលរដ្ឋ អាជ្ញាធរ ដែលពាក់ព័ន្ធ ក្នុងការពារ មិនឲ្យមានការឆក់ត្រីដោយខុសច្បាប់ឡើយ ជាពិសេស មិនមានការបង្ហូរទឹកកង្វក់ចូលទៅ ព្រៃលិចទឹកនេះឡើយ ដែលអាច ធ្វើឲ្យប៉ះពាល់ប៉ះពាល់បរិស្ថាន។

### ២.២.៤ ផ្នែកសេវាកម្មរដ្ឋបាល និង សន្តិសុខ[14]

#### ២.២.៤.១ ការងាររដ្ឋបាល

បច្ចុប្បន្នរាជរដ្ឋាភិបាលកម្ពុជា បានធ្វើកំណែទម្រង់រដ្ឋាបាលសាធារណៈយ៉ាងស៊ីជម្រៅដោយផ្តោតទៅលើរដ្ឋាបាលសាធារណៈជាស្នូលអភិបាលកិច្ចល្អ នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដែលកំពុងបានអនុវត្តគោលនយោបាយវិមជ្ឈការ និងសហវិមជ្ឈការតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលកើតចេញពីការបោះឆ្នោតសកល និងអសកលសម្រាប់បម្រើផលប្រយោជន៍ និងផ្តល់សេវាសាធារណៈ ជូនដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន សំដៅលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋតាមរយៈការកាត់បន្ថយភាពក្រីក្រ។

ក្នុងការបំពេញការងារជាប្រចាំថ្ងៃ ឃើញថាប្រជាពលរដ្ឋភាគច្រើនបានយល់ច្បាស់ពីការចុះអត្រានុកូលដ្ឋាន ឬ សំបុត្រអាពាហ៍ពិពាហ៍ ដែលមានផលប្រយជន៍ដល់រូបគេផ្ទាល់។ ដូចនេះហើយភាគច្រើនណាស់ ដែលមិនបានមកចុះអត្រានុកូលដ្ឋាន សំបុត្រអាពាហ៍ពិពាហ៍ ក្នុងមួយឆ្នាំៗកន្លងមក។

- ❖ ឃុំបានយកចិត្តទុកដាក់ ការផ្តល់សេវារដ្ឋបាលសាធារណៈ
    - ទទួល និងផ្សព្វផ្សាយលិខិតបទដ្ឋាននានា
    - ចងក្រងស្ថិតិ និងចុះបញ្ជីអត្រានុកូលដ្ឋាន

[13] ដកស្រង់ចេញពីសៀវភៅកម្មវិធីវិនិយោគឃុំឆ្នាំ២០១៦ របស់ឃុំជីពាទ៍ទី២ នៅទំព័រទី១២

[14] ដកស្រង់ចេញពីសៀវភៅកម្មវិធីវិនិយោគឃុំឆ្នាំ២០១៦ របស់ឃុំជីពាទ៍ទី២ នៅទំព័រទី១៥

- បម្រើសេវារដ្ឋបាលជូនប្រជាពលរដ្ឋ(អនុវត្តតាមរាតាងតម្លៃសេវារដ្ឋបាលឃុំ)
- ទទួលពាក្យបណ្តឹង និងដោះស្រាយ សម្រុះសម្រួលទំនាស់ផ្សេងៗ
- រៀបចំសណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ
- សហការជាមួយក្រសួង ស្ថាប័ន អង្គការជាតិ អន្តរជាតិ សប្បុរសជន
- ទំនាក់ទំនងរវាងរដ្ឋបាលឃុំ និងរដ្ឋបាលផ្សេងៗទៀត
- ផ្សព្វផ្សាយផែនការភូមិ ឃុំមានសុវត្ថិភាព

❖ ឃុំនៅមានចំណុចខ្វះខាតមួយចំនួនដូចខាងក្រោម

- សម្តភាពក្រុមប្រឹក្សានៅមានកម្រិតការឆ្លើយតបទៅនឹងតម្រូវការ

  របស់ប្រជាពលរដ្ឋពុំទាន់បានសមស្រប
- ខ្វះព័ត៌មានត្រឡប់ និងការចូលរួមពីសកគមន៍
- ខ្វះការតាមដានត្រួតពិនិត្យ ការផ្លាស់ប្តូរទីកន្លែងមួយទៅកន្លែងមួយ ឬ មកស្នាក់នៅគ្មានដំណឹង។

❖ ដើម្បីឆ្លើយតបបញ្ហាប្រឈមទាំងនេះត្រូវៈ

- ពង្រឹងអភិបាលកិច្ចល្អ
- ប្រសិទ្ធិភាពការងារ
- កែលម្អគុណភាព ការផ្លាស់ប្តូរសេវាសាធារណៈ
- កែប្រែអាកប្បកិរិយា និងឥរិយាបទរបស់ក្រុមប្រឹក្សា និងស្មៀន
- ពង្រឹង និងបង្កើនសម្តភាពរបស់ក្រុមប្រឹក្សា និងស្មៀន

### ២.២.៤.២ ការងារសន្តិសុខ

បញ្ហាសន្តិសុខ គឺជាបញ្ហាមួយ មិនមែនជាបញ្ហាចំបង តែវាមានការដោះស្រាយបន្តិចបន្តួចស្ទើររាល់ខែដែរ។ ក្នុងឆ្នាំ២០១៥នេះ បើយើងប្រៀបធៀបទៅនឹងឆ្នាំ២០១៤ កន្លងមកយើងឃើញថា បញ្ហាសន្តិសុខសណ្តាប់ធ្នាប់សង្គម មានការថយចុះច្រើន ដោយសារលោកមេឃុំបានចាត់វិធានការអោយក្រុមប្រឹក្សាម្នាក់ៗក្តាប់តាមភូមិ ដើម្បីជួយណែនាំអប់រំ អោយប្រជាជនយល់ច្បាប់ភូមិបាល និងចេះអធ្យាស្រ័យ អត់អោនអោយគ្នា ព្រមទាំងជួយពង្រឹង ប្រជាការពារបន្ថែមទៀត។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ក៏ក្រុមប្រឹក្សាឃុំ ត្រូវមានការយល់ដឹងពីច្បាប់បន្ថែមទៀត អំពីនិតិវិធីក្នុងការដោះ

ស្រាយ ទំនាស់ក្រៅតុលាការ។ ដើម្បីជៀសវាងទំនាស់ដីធ្លីផ្សេងៗ ប្រជាពលរដ្ឋត្រូវមានប្លង់ដីដែលបញ្ជាក់ពីព្រំប្រទល់ច្បាស់លាស់។ ដូចនេះសមាជិកក្រុមប្រឹក្សាឃុំត្រូវយល់ពីច្បាប់ភូមិបាល បានស៊ីជម្រៅដែរ ទើបការដោះស្រាយទំនាស់តិចតួចប្រកបដោយយុត្តិធម៌ និងតម្លាភាព វាជាវិធានការការពារទុកជាមុន ដ៏សមស្របបំផុត ដែលឃុំប្រកាន់យក ដើម្បីការពារទំនាស់កុំអោយរីករាលដាលកាន់តែខ្លាំងថែមទៀត។ ឯចំណែកការសាមគ្គីផ្ទៃក្នុងវិញ គឺពុំមានអ្វីគួរអោយពិបាកដោះស្រាយទេ គឺមានការសាមគ្គី រវាងគ្នា និងគ្នា។

❖ ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមឃុំមានវិធានការចំពោះមុខ

- ពង្រឹងបន្ថែមកម្លាំងប្រជាការពារ
- បណ្តុះបណ្តាលសមត្ថភាពដល់កម្លាំងប្រជាការពារ
- ផ្សព្វផ្សាយពីច្បាប់ព្រហ្មទណ្ឌ ច្បាប់ចរាចរណ៍ផ្លូវគោក
- បង្ក្រាបទប់ស្កាត់បទល្មើសនេសាទគ្រប់ប្រភេទ
- បង្ក្រាប់ទប់ស្កាត់ការចែកចាយ និងប្រើប្រាស់គ្រឿងញៀនស៊ីសង
- តាមដានរាល់បណ្តាមុខសញ្ញា
- ផ្សព្វផ្សាយផែនការ ភូមិ ឃុំ មានសុវត្ថិភាព
- ផ្សព្វផ្សាយ ទប់ស្កាត់ ការជួញដូរស្ត្រី និង កុមារ
- ផ្សព្វផ្សាយពីការធ្វើចំណាក់ស្រុកដោយសុវត្ថិភាព។

### ២.២.៥ ផ្នែកយេនឌ័រ[15]

យោងតាមផែនការណែនាំ និងសកម្មភាពជាក់ស្តែង ដែលយើងទាំងអស់គ្នាបានដឹង នៅឃុំជីរោទ៍ទី២ មិនមានការប្រកាន់ បែងចែកគ្នា រវាងបុរស និងរវាងស្ត្រី ឬរវាងកូនប្រុស និងស្រី ដែលមានលក្ខណៈពិបាកគួរអោយកត់សំគាល់នោះទេ។

ភាគរយរបស់ក្មេងប្រុស និងក្មេងស្រី មិនបានចូលរៀននៅតាមភូមិខ្លះៗមានចំនួនប្រហាក់ប្រហែលគ្នា ហើយភាគរយបុរស និងស្ត្រី មិនចេះអក្សរ ក៏ប្រហាក់ប្រហែលគ្នាដែរ។ ថ្វីត្បិតតែនៅតាមភូមិខ្លះៗនៅមានអំពើហិង្សាក្នុងគ្រួសារដែលកើតមានឡើង វាគ្រាន់តែជាប្រភេទទំនាស់គ្រួសារធម្មតា រវាងប្តី និង ប្រពន្ធ តែប៉ុណ្ណោះ។ គេក៏មិនអាចចាត់ទុកថា បុរសមានអំណាចរំលោភទៅលើស្ត្រីបានទេ។

---

[15] ដកស្រង់ចេញផ្នែកយេនឌ័រ ទំព័រទី១៧ នៅក្នុងសៀវភៅ កម្មវិធីវិនិយោគឃុំ២០១៦

ចាប់តាំងពីការរៀបចំឲ្យមានវគ្គបណ្តុះបណ្តាល ស្តីពីបញ្ហាយេនឌ័រ និងអំពើហិង្សាក្នុងគ្រួសារមក ក្នុងឃុំជីពោទ៍ទី២ បានកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារបានយ៉ាងច្រើន។ ម្យ៉ាងទៀតការផ្សព្វផ្សាយតាមបញ្ចាក់ទូរទស្សន៍ តាមវិទ្យុ តាមរូបបិទផ្សាយតាមភូមិ-ឃុំ និងជនបង្គោលយេនឌ័រដែលបានការបណ្តុះបណ្តាលនៅឃុំ បានរៀបចំសហការជាមួយលោកមេភូមិ តាមភូមិនីមួយៗ ជួយអប់រំណែនាំ ដល់ប្រជាពលរដ្ឋទូទៅ ឲ្យគេយល់ច្បាស់ពីច្បាប់ លើអំពើហិង្សាក្នុងគ្រួសារ ដែលកើតឡើងមកពីការស្រវឹងស្រា និងការលេងល្បែងស៊ីសង ទាំងអស់នេះហើយ ដែលធ្វើឲ្យមានអំពើហិង្សា។

ដូច្នេះ យើងឃើញថា ក្នុងឃុំជីពោទ៍ទី២ ប្រជាពលរដ្ឋមានការយល់ដឹងច្រើនអំពីអំពើហិង្សាក្នុងគ្រួសារ គួរឲ្យធូរស្រាលមួយកម្រិតថែមទៀត។

❖ ដើម្បីជម្រុញយេនឌ័រឲ្យមានការអភិវឌ្ឍឡើងនោះយើងត្រូវ

- ពង្រឹងសមត្ថភាពដល់អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ
- ផ្សព្វផ្សាយអំពីសិទ្ធិ និងតួនាទីស្ត្រីក្នុងសង្គម
- សុខភាពមាតា និងទារក
- ជម្រុញ និងលើកទឹកចិត្តដល់ស្ត្រី ក្នុងការចូលរួមកិច្ចការនយោបាយ និងសង្គម
- រៀបចំឲ្យមានវេទិការស្ត្រីបានទូលំទូលាយ
- បណ្តុះបណ្តាលសមត្ថភាពដល់ស្ត្រី
- ផ្សព្វផ្សាយស្តីពីការលើកកម្ពស់អនាម័យ
- ផ្សព្វផ្សាយទប់ស្កាត់ការកេងប្រវ័ញ្ចលើកម្លាំងពលកម្មកុមារ។

បញ្ហាដែលចោទខ្លាំងដែលកំពុងពិចារណារកដំណោះស្រាយ គឺគ្រួសារដែលមានស្ត្រីជាមេគ្រួសារហើយមានកូនអាយុតិចជាង៥ឆ្នាំ កំពុងស្ថិតនៅក្នុងបន្ទុក។ គ្រួសារតែងតែជួបការលំបាកយ៉ាងខ្លាំង ក្នុងការរកនៅប្រាក់ចំណូល ចិញ្ចឹមជីវិត ព្រោះជាស្ត្រីត្រូវរកប្រាក់ចំណូល ចិញ្ចឹមគ្រួសារផង និងត្រូវថែទាំកូនរបស់ខ្លួនផង។

## ២.៣ សកម្មភាពដែលបានអនុវត្តចន្លោះឆ្នាំ ២០១៤-២០១៧

### ២.៣.១ សកម្មភាពបានអនុវត្តក្នុងឆ្នាំ ២០១៤[16]

១. ជួសជុលផ្លូវក្រាលគ្រួសក្រហម ចំនួនបីភូមិ ដោយនៅក្នុងនោះមានប្រវែង១៥៩១ម៉ែត ហើយត្រូ

[16] ដកស្រង់ចេញពីឯកសារសកម្មភាពដែលបានអនុវត្តក្នុងឆ្នាំ២០១៤ របស់ឃុំជីពោទ៍ទី២

ចំណាយថវិការ៦៥,៩៣១,៩៨០រៀល ដែលត្រូវបានគាំទ្រដោយ មូលនិធិឃុំ

២. ជីកអណ្តូងស្នប់ អនុវត្តទូទាំងឃុំ ក្នុងនោះមាន៧១អណ្តូង ហើយត្រូវចំណាយថវិការ ២៩១,១០០,០០០រៀល ដែលត្រូវបានគាំទ្រដោយ សមាគមន៍មូស្លីមកម្ពុជា

៣. ផ្តល់ធុងចម្រោះទឹកស្អាត ទូទាំងឃុំ មាន៣៩៥ធុង គាំទ្រដោយ អង្គការស្អាតកម្ពុជា

៤. ជួសជុលផ្លូវក្រឡុកសំបុកមាន់ អនុវត្តនៅភូមិអណ្តូងជា ដែលមានចំនួន១គ.ម ហើយត្រូវចំណាយថវិការ ៩,៩៨៤,៣០០រៀល គាំទ្រដោយមូនិធិឃុំ

៥. ចាក់វ៉ាក់សាំងគោ.ក្របី ទូទាំងឃុំ ចំនួន១២៧ក្បាល គាំទ្រដោយ មន្ទីកសិកម្ម

៦. អាហារូបករណ៍សិស្សក្រីក្រ នៅភូមិបឹងត្រស់ ចំនួន៣០គ្រួសារ ដោយអង្គការវឌ្ឍនភាព

៧. ផ្តល់ជូជមាន់ នៅភូមិបឹងត្រស់ ចំនួន២០គ្រួសារ គាំទ្រដោយ អង្គការណាស់

៨. ផ្តល់ពូជក្រូចឆ្មា នៅភូមិបឹងត្រស់ ចំនួន៩៥ដើម គាំទ្រដោយ អង្គការណាស់

៩. បណ្តុះបណ្តាលពីការគ្រប់គ្រងជំនួញនិរន្តរភាព ទូទាំងឃុំ ចំនួន១វគ្គ គាំទ្រដោយ អង្គការណាស់

១០. បណ្តុះបណ្តាលការស្រង់ទិន្នន័យបង្គន់អនាម័យ ទឹកស្អាត ទូទាំងឃុំ ចំនួន១វគ្គ

១១. បណ្តុះបណ្តាលកិច្ចការពារសុវត្ថិភាពគម្រោងឃុំ នៅសាលាស្រុក ១វគ្គ ដោយសាលាស្រុក

១២. ជម្រុញការធ្វើអត្រានុកូលដ្ឋានគ្រប់ប្រភេទ អនុវត្តនៅទូទាំងឃុំ ដែលមានចំនួន១២វគ្គ ហើយត្រូវចំណាយថវិការ ៤០០,០០០រៀល ត្រូវបានគាំទ្រដោយ ឃុំមន្ទីផែនការ

១៣. ការធ្វើទិន្នន័យភូមិ-ឃុំ ទូទាំងឃុំ ចំនួន១លើក គាំទ្រដោយមន្ទីផែនការ

១៤. ការធ្វើសមាហរណកម្មថ្នាក់ស្រុក នៅសាលាស្រុក ចំនួន២លើក គាំទ្រដោយ មន្ទីផែនការ

១៥. ផ្សព្វផ្សាយសេវាសុខភាព នៅមណ្ឌលសុខភាព ២លើក ដោយមន្ទីសុខាភិបាល

១៦. ផ្តល់ការចាក់វ៉ាក់សាំងដល់ស្ត្រី/កុមារ នៅទូទាំងឃុំ ចំនួន១២លើក គាំទ្រដោយមន្ទីសុខាភិបាល

១៧. សេវាសុខភាពស្ត្រីមានផ្ទៃពោះ នៅទូទាំងឃុំ ចំនួន១២លើក គាំទ្រដោយមន្ទីសុខាភិបាល

១៨. កម្មវីធីពន្យាកំណើត នៅមណ្ឌលសុខភាព ធ្វើឡើងចំនួន១២លើក គាំទ្រដោយមន្ទីសុខាភិបាល

១៩. បណ្តុះបណ្តាលវិជ្ជាជីវៈជំនាញដល់ជនពិការ នៅសាលាឃុំ ២វគ្គ ដោយ អង្គការជនពិការ

២០. បណ្តុះបណ្តាលពីសុខភាពអនាម័យ នៅទូទាំងឃុំ ២វគ្គ គាំទ្រដោយ អង្គការណាស់

២១. ផ្សព្វផ្សាយជម្រុញឪពុកម្តាយឲ្យនាំកូនចូលរៀន នៅទូទាំងឃុំ ១លើក គាំទ្រដោយមន្ទីអប់រំ

២២. ពង្រឹងនគបាលសហគមន៍ នៅប៉ុស្តិ៍រដ្ឋបាល ១២លើក ដោយ អធិការនគរបាលស្រុក

២៣. ជម្រុញសកម្មភាពបង្ក្រាបល្បែងស៊ីសង នៅទូទាំងឃុំ ១២លើក ដោយ អធិការនគរបាលស្រុក

២៤. ពង្រឹងវិធានការទប់ស្កាត់បទល្មើសនេសាទ ទូទាំងឃុំ ៤លើក ដោយ អធិការនគរបាលស្រុក

២៥. ផ្សព្វផ្សាយច្បាប់សាវាចរជើងគោក នៅទូទាំងឃុំ ចំនួន២លើក ដោយ អធិការនគរបាលស្រុក
២៦. ផ្សព្វផ្សាយច្បាប់ព្រហ្មទណ្ឌ នៅទូទាំងឃុំ ចំនួន១លើក គាំទ្រដោយ អធិការនគបាលស្រុក
២៧. ជម្រុញការបង្ក្រាបក្មេងទំនើង នៅទូទាំងឃុំ ចំនួន២លើក គាំទ្រដោយ អធិការនគបាលស្រុក
២៨. ផ្សព្វផ្សាយស្តីពីច្បាប់ក្នុងការប្រឆាំងអំពើហិង្សាក្នុងគ្រួសារ អនុវត្តនៅទូទាំងឃុំ ហើយមានចំនួន២លើក នឹងត្រូវចំណាយថវិការ ៤៦៤,០០០រៀល ត្រូវបានគាំទ្រដោយ មូលនិធិឃុំ
២៩. ផ្សព្វផ្សាយស្តីពីច្បាប់ក្នុងការប្រឆាំងការជួញដូរស្ត្រី និងកុមារ អនុវត្តនៅទូទាំងឃុំ ហើយមានចំនួន២លើក នឹងត្រូវចំណាយថវិការ ៤៦៤,០០០រៀល ត្រូវបានគាំទ្រដោយ មូលនិធិឃុំ
៣០. ផ្សព្វផ្សាយស្តីពីច្បាប់ក្នុងការធ្វើចំណាក់ស្រុកមានសុវត្ថិភាព អនុវត្តនៅទូទាំងឃុំ ហើយមានចំនួន២លើក នឹងត្រូវចំណាយថវិការ៤៦៤,០០០រៀល ត្រូវបានគាំទ្រដោយ មូលនិធិឃុំ
៣១. ធ្វើការពង្រឹងនូវសម្ថភាពការងាររបស់ គ.ក.ន.ក នៅសាលាស្រុក ត្រូវបានធ្វើឡើងមានចំនួន៣លើក ហើយត្រូវចំណាយថវិការគឺ៤៦៤,០០០រៀល ត្រូវបានគាំទ្រដោយ មូលនិធិរបស់ឃុំ។

### ២.៣.២ សកម្មភាពបានអនុវត្តក្នុងឆ្នាំ ២០១៥[17]

១. សាងសង់ផ្លូវក្រាលគ្រួសក្រហម ចំនួន៤ភូមិ ក្នុងនោះមានប្រវែង២,០១៨គ.ម ហើយត្រូវចំណាយថវិការអស់១២៣.៧២៦.០០០រៀល ដែលត្រូវបានគាំទ្រដោយ មូលនិធិរបស់ឃុំ
២. ជួសជុលផ្លូវក្រឡុកសំបុកមាន់ ស្ថិតនៅភូមិអណ្តូងជា ក្នុងនោះមានប្រវែង ១,៤៨០ម៉ែត្រ ត្រូវចំណាយថវិការអស់៨.០០០.០០០រៀល ដែលត្រូវបានគាំទ្រដោយ មូលនិធិរបស់ឃុំ
៣. សាងសង់ផ្លូវបេតុង ភូមិស្រែសៀម ប្រវែង២៥៥ម៉ែត្រ គាំទ្រដោយឧកញ៉ា ស្រ៊ុនសំណាង
៤. ជួសជុលផ្លូវក្រាលគ្រួសក្រហម ចំនួន២ភូមិ មានប្រវែង៤៨០ម៉ែត្រ គាំទ្រដោយ អៀង សារ៉េត
៥. ឈូសឆាយបើកផ្លូវលំ ភូមិស្រែសៀម ប្រវែង២០០ម៉ែត្រ គាំទ្រដោយ ឧកញ៉ា ស្រ៊ុនសំណាង
៦. ឈូសឆាយបើកផ្លូវលំ នៅភូមិស្រែសៀម មានប្រវែង១៣២ម៉ែត្រ គាំទ្រដោយ តុលារខេត្ត
៧. សាងសង់អណ្តូងស្នប់ នៅសាលាជ្រោយគរ ចំនួន១អណ្តូង គាំទ្រដោយ មន្ទីអភិវឌ្ឍន៍ខេត្ត
៨. ចាក់វ៉ាក់សាំង គោ ក្របី នៅទូទាំងឃុំ មានចំនួន៣០គ្រួសារ គាំទ្រដោយមន្ទីកសិកម្ម
៩. បណ្តុះបណ្តាលជីកុំប៉ុស្ត៍ នៅទូទាំងឃុំ មានចំនួន៣០គ្រួសារ គាំទ្រដោយមន្ទីកសិកម្ម
១០. គម្រោងសាកល្បងអនាម័យជនបទ នៅសាលាស្រុក ចំនួន២នាក់ គាំទ្រដោយ អង្គការណាស់
១១. បណ្តុះបណ្តាលគម្រោងឆ្ពោះទៅនិរន្តភាពមុខរបរ ចំនួន២២នាក់ គាំទ្រដោយ អង្គការណាស់
១២. បណ្តុះបណ្តាលអនុវត្តថវិការរដ្ឋបាលថ្នាក់ក្រោមជាតិ ចំនួន២នាក់ គាំទ្រដោយ សាលាខេត្ត

[17] ដកស្រង់ចេញពីឯកសារ សកម្មភាពដែលបានអនុវត្តក្នុងឆ្នាំ២០១៥

១៣. សិក្ខាសាលាស្តីពីការចែករំលែកចំពោះព័ត៌មាន និងយន្តការជំនួយខ្នាត់តូច ធ្វើឡើននៅ មន្ទីសុខាភិបាល ចំនួន២នាក់ គាំទ្រដោយ អង្គការជនពិការ

១៤. ផ្សព្វផ្សាយការធ្វើដំណើរដោះមីនមិនទាន់ផ្ទុះ នៅសាលាស្រុកចំនួន៣នាក់ គាំទ្រដោយCMAC

១៥. បណ្តុះបណ្តាលស្តីពីការធ្វើនីតិវិធីបច្ចេកទេស ការរៀបចំថវិការឃុំក្នុងឆ្នាំ២០១៦ ធ្វើឡើងនៅ សាលាខេត្ត ក្នុងនោះមានចំនួន២នាក់ ដែលត្រូវបានគាំទ្រដោយ សាលាខេត្ត

១៦. បណ្តុះបណ្តាលជនបង្គោលស្រ្តី និងកុមារនៅសាលាស្រុក គាំទ្រដោយ អង្គការវឌ្ឍន

១៧. ជំរុញការធ្វើអគ្រានុកូលដ្ឋានគ្រប់ប្រភេទ នៅទូទាំងឃុំ ចំនួន១២លើក គាំទ្រដោយ សាលាឃុំ

១៨. ការធ្វើទិន្នន័យភូមិ-ឃុំ នៅទូទាំងឃុំ ចំនួន១លើក គាំទ្រដោយ មន្ទីផែនការ

១៩. ការធ្វើសមារហរណកម្មផែនការថ្នាក់ស្រុក នៅសាលាស្រុក គាំទ្រដោយមន្ទី ផែនការ

២០. បណ្តុះបណ្តាលធ្វើបច្ចុប្បន្នភាពទិន្នន័យគ្រួសារក្រីក្រ ចំនួន២លើក គាំទ្រដោយ មន្ទីផែនការ

២១. ផ្សព្វផ្សាយពីសេវាសុខភាពនៅមណ្ឌលសុខភាព ចំនួន១២លើក គាំទ្រដោយ មន្ទីសុខាភិបាល

២២. ផ្តល់ការចាក់វ៉ាក់សាំងដល់ស្រ្តី និងកុមារ នៅទូទាំងឃុំចំនួន១២លើក ដោយមន្ទីសុខាភិបាល

២៣. សេវាសុខភាពស្ត្រីមានផ្ទៃពោះ នៅទូទាំងឃុំ ចំនួន១២លើក គាំទ្រដោយ មន្ទីសុខាភិបាល

២៤. កម្មវិធីពន្យាកំណើត នៅទូទាំងឃុំ ចំនួន១២លើក គាំទ្រដោយ មន្ទីសុខាភិបាល

២៥. បណ្តុះបណ្តាលវិជ្ជាជីវៈជំនាញ នៅទូទាំងឃុំ ចំនួន១លើក គាំទ្រដោយ អង្គការជនពិការ

២៦. ជំរុញសកម្មភាពបង្រ្កាបល្បែងស៊ីសង ទូទាំងឃុំ ចំនួន១២លើក ដោយអធិការនគបាលស្រុក

២៧. ផ្សព្វផ្សាយជូនដំណឹងរដូវនេសាទ ទូទាំងឃុំ ២លើក គាំទ្រដោយគណៈបញ្ជាការឯកភាព

២៨. វិធានបង្រ្កាបទប់ស្កាត់បទល្មើសនេសាទ ទូទាំងឃុំ ២លើក ដោយគណៈបញ្ជាការឯកភាព

២៩. ពង្រឹងនគបាលសហគមន៍ នៅទូទាំងឃុំ ចំនួន១២លើក គាំទ្រដោយ អធិការនគបាលស្រុក

៣០. ផ្សព្វផ្សាយច្បាប់ចរាចរផ្លូវគោក នៅទូទាំងឃុំ ចំនួន២លើក

៣១. ផ្សព្វផ្សាយច្បាប់ព្រហ្មទណ្ឌ នៅទូទាំងឃុំ ចំនួន១លើក គាំទ្រដោយ អធិការនគបាលស្រុក

៣២. ជម្រុញបង្រ្កាបសកម្មភាពក្មេងទំនើង នៅទូទាំងឃុំ ចំនួន៣លើក ដោយអធិការនគបាលស្រុក

៣៣. អប់រំផ្សព្វផ្សាយច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារ ចំនួន២លើក គាំទ្រដោយ មន្ទីកិច្ចការនារី

៣៤. ផ្សព្វផ្សាយច្បាប់ប្រឆាំងការជួញដូរស្រ្តី និងកុមារ ចំនួន២លើក គាំទ្រដោយ មន្ទីកិច្ចការនារី

៣៥. ផ្សព្វផ្សាយច្បាប់ចំណាក់ស្រុកមានសុវត្ថិភាព ចំនួន២លើក គាំទ្រដោយ មន្ទីកិច្ចការនារី

៣៦. ពង្រឹងសមត្ថភាពជនបង្គោលស្ត្រី និងកុមារ ចំនួន១២លើក គាំទ្រដោយ មន្ទីកិច្ចការនារី

៣៧. ការផ្តល់អត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋ ទូទាំងឃុំ ១២លើក ដោយស្នងការនគបាលខេត្ត

៣៨. ការចុះថតអត្តសញ្ញាណប័ណ្ណជូនគ្រួសារកងទ័ព ៣១០លើក ដោយ អធិការនគបាលស្រុក

### ២.៣.៣ សកម្មភាពបានអនុវត្តក្នុងឆ្នាំ ២០១៦[18]

១. ជម្រុញការធ្វើអត្រានុគោលដ្ឋានគ្រប់ប្រភេទ នៅទូទាំងឃុំ ចំនួន៦លើក គាំទ្រដោយ សាលាឃុំ

២. ផ្សព្វផ្សាយសេវាសុខភាពនៅមណ្ឌលសុខភាព ចំនួន២លើក គាំទ្រដោយ មន្ទីសុខាភិបាល

៣. សាងសងផ្លូវក្រាលគ្រួសក្រហម ចំនួន២ភូមិ មានប្រវែង ៣.៧៥៩ម៉ែត្រ តម្លៃប៉ាន់ស្មាន ៦៨,៦៧០,០០០រៀល

៤. ជួសជុលអណ្តូងស្នប់ នៅសណ្ឋាគារ ចំនួន៣អណ្តូង គាំទ្រដោយ មន្ទីអភិវឌ្ឍន៍ជនបទ

៥. បង្គន់អនាម័យ នៅសណ្ឋាគារភ្នំប្រុស ក្នុងនោះមានចំនួន១៩បង្គន់ តម្លៃត្រូវបានប៉ាន់ស្មានមានចំនួន៥,១៣០,០០០រៀល និងត្រូវបានគាំទ្រដោយ Water set h &ហ្វូវឡង់

៦. ជួយស្រ្តីសម្រាលកូននៅមណ្ឌលសុខភាព ធ្វើឡើងនៅទូទាំងឃុំ មានចំនួន១០លើក តម្លៃត្រូវគេប៉ាន់ស្មានមានចំនួន ៥០០.០០០រៀល ក្នុងនោះគាំទ្រដោយ ថវិការរបស់ឃុំ

៧. ជួយជនក្រីក្រគ្មានទីពឹង ធ្វើឡើងនៅទូទាំងឃុំ មានចំនួន២៧គ្រួសារ ក្នុងនោះតម្លៃត្រូវបានគេប៉ាន់ស្មានមានចំនួន ២,៧០០,០០០រៀល ត្រូវបានគាំទ្រដោយមេបញ្ជាការកងពល

៨. ផ្តល់ការចាក់វ៉ាក់សាំងដល់ស្ត្រី និងកុមារ ចំនួន១២លើក គាំទ្រដោយ មន្ទីសុខាភិបាល

៩. ផ្តល់សេវាសុខភាពដល់ស្ត្រីមានផ្ទៃពោះ ចំនួន១២លើក គាំទ្រដោយ មន្ទីសុខាភិបាល

១០. កម្មវិធីពន្យាកំណើត នៅទូទាំងឃុំ ចំនួន១២លើក គាំទ្រដោយ មន្ទីសុខាភិបាល

១១. បណ្តុះបណ្តាលវិជ្ជាជីវៈជំនាញដល់ជនពិការ ចំនួន១វគ្គ គាំទ្រដោយ អង្គការជនពិការកម្ពុជា

១២. ផ្សព្វផ្សាយឲ្យឪពុកម្តាយនាំកូនទៅរៀន នៅទូទាំងឃុំ ចំនួន១វគ្គ គាំទ្រដោយ អង្គការណាស់

១៣. បណ្តុះបណ្តាលពីសុខភាព អនាម័យ នៅទូទាំងឃុំ ចំនួន១វគ្គ គាំទ្រដោយ អង្គការណាស់

១៤. សាង់សងផ្ទះជូនជនក្រីក្រ ចំនួន២ភូមិ ដែលមាន៣ខ្នង គាំទ្រដោយ មេបញ្ជាការកងពល

១៥. សាង់សងសាលារៀន ស្ថិតនៅក្នុងភូមិទួលវិហារ ដែលមានចំនួន៣បន្ទប់ តម្លៃត្រូវបានគេបប៉ាន់ស្មានមានចំនួន ១៣៧,៧០០,០០០រៀល ក្នុងនោះត្រូវបានគាំទ្រដោយ សប្បុរសជន

១៦. សីសធម៌សង្គម ចំនួន១លើក តម្លៃប៉ាន់ស្មាន ២,០០០,០០០រៀល គាំទ្រដោយ មន្ទីកិច្ចការនារី

១៧. វគ្គបណ្តុះបណ្តាលកិច្ចការនារីឃុំ ១វគ្គ តម្លៃប៉ាន់ស្មាន ៥០,០០០រៀល ដោយមន្ទីកិច្ចការនារី

១៨. វគ្គបណ្តុះបណ្តាល"ខ្ញុំជាស្រ្តីចុះអ្នកវិញ" ចំនួន១ថ្ងៃ គាំទ្រដោយ អង្គការWater set h

១៩. សិក្ខាសិលាស្តីពីការលើកកម្ពស់ស្រ្តី នៅទូទាំងឃុំ ចំនួន២ថ្ងៃ គាំទ្រដោយ អង្គការWater set h

---

[18] ដកស្រង់ចេញពីឯកសារលទ្ធិផលនៃការអនុវត្តគម្រោងក្នុងឆ្នាំ២០១៦ របស់ឃុំជីពោទ៍ទី២

២០. ផ្សព្វផ្សាយ គ.ក.ន.ក តាមភូមិ ៤លើក តម្លៃប៉ាន់ស្មាន ៣,៥០០,០០០រៀល ដោយថវិការឃុំ

២១. ពង្រឹងសម្ថភាពការងារ គ.ក.ន.ក នៅទូទាំងឃុំ ចំនួន៣លើក គាំទ្រដោយកិច្ចការនារី

២២. ផ្សព្វផ្សាយអំពីច្បាប់ជលផល ធ្វើនៅក្នុងភូមិស្រែសៀម ធ្វើឡើងចំនួន១លើក ក្នុងនោះតម្លៃ ត្រូវបានគេប៉ាន់ស្មានមានចំនួន៤០០,០០០រៀល ត្រូវបានគាំទ្រដោយ រដ្ឋបាលជលផល

២៣. បណ្តុះបណ្តាលពីការស្រង់ទិន្នន័យបង្គន់អនាម័យទឹកស្អាត ក្នុងនោះបានធ្វើឡើងនៅទូទាំងឃុំ ដែលមាន ចំនួន១វគ្គ ហើយត្រូវបានគាំទ្រមកពី អង្គការ Water set h

២៤. ជំរុញសកម្មភាពបង្ក្រាបល្បែងស៊ីសង នៅទូទាំងឃុំ ៨វគ្គ គាំទ្រដោយ អធិការនគបាលស្រុក

២៥. ផ្សព្វផ្សាយច្បាប់ចរាចរជើងគោក  នៅទូទាំងឃុំ ចំនួន២លើក ដោយ អធិការនគបាលស្រុក

២៦. ផ្សព្វផ្សាយច្បាប់ព្រហ្មទណ្ឌ នៅទូទាំងឃុំ ចំនួន២លើក គាំទ្រដោយ អធិការនគបាលស្រុក

២៧. ជម្រុញការបង្ក្រាបសកម្មភាពក្មេងទំនើង ចំនួន១២លើក គាំទ្រដោយអធិការនគបាលស្រុក

២៨. ផ្សព្វផ្សាយច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារ ទូទាំងឃុំ ១លើក ដោយអធិការនគបាលស្រុក

២៩. បញ្ជូនស្ត្រីដែលមានផ្ទៃពោះទៅសម្រាលកូននៅក្នុងមណ្ឌលសុខភាព បានធ្វើឡើងនៅទូទាំង ឃុំ តម្លៃប៉ាន់ស្មានមានចំនួន៦៩,២០០,០០០រៀល ហើយគាំទ្រដោយ មូលនិធិរបស់ឃុំ

### ២.៣.៤ សកម្មភាពមួយចំនួនបានអនុវត្តក្នុងឆ្នាំ ២០១៧[19]

១. សងសង់ផ្លូវក្រាលក្រួសក្រហម  មានប្រវែង ៣,០០០ម៉ែត្រ ត្រូវចំណាយថវិការអស់ ១២០,០០០,០០០រៀល ក្នុងនោះអ្នកដែលទទួលផលមានចំនួន ២ភូមី គឺភូមិម្រាមទាក និងភូមិទឹកចេញ។

## ២.៤ សមិទ្ធិផលនៃការអភិវឌ្ឍ

### ១. ការគ្រប់គ្រងរដ្ឋបាលឃុំ

ក. អំពីក្រុមប្រឹក្សា

យុំជីពោទីពោទ៍ទី២ មាន៨រូប ស្រី៣រូប រីឯ ការលើកកម្ពស់ប្រសិទ្ធិភាព ការគ្រប់គ្រងរដ្ឋបាលឃុំ តាមរយៈការប្រជុំ យោងតាមបទបញ្ជាផ្ទៃក្នុង ក្រុមប្រឹក្សាឃុំ បានធ្វើការប្រជុំអាណត្តិទៀងទាត់ជារៀងរាល់ខែ និង ការប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា បានប្រជុំអនុម័តលើការងារចាំបាច់ និង កិច្ចការផ្សេងៗទៀតដែលជាតម្រូវការរបស់ប្រជាពលរដ្ឋ។ លើសពីនេះទៅទៀត ក្រុមប្រឹក្សាឃុំបាន ប្រជុំពិគ្រោះយោបល់ ជាមួយប្រជាពលរដ្ឋ នូវផែនការ៥ឆ្នាំ និងកម្មវិធីវិនិយោគឃុំ ១ឆ្នាំម្តងៗស្វែង

[19] ដកស្រង់ចេញពីសៀវភៅ សំណើរគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៧

រកនៅផែនការ និងកម្មវិធីវិនិយោគឃុំ បញ្ចូលនូវគម្រោងមួយចំនួនពាក់ព័ន្ធស្ត្រី និងកុមារ ដើម្បីក្រុមប្រឹក្សាឃុំធ្វើការអនុម័ត។

ខ. ការងាររដ្ឋបាល

ការផ្តល់សេវារដ្ឋបាល: ក្នុងការធ្វើលិខិតស្នាមផ្សេងៗ មានដូចជា ការផ្តល់អត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋ ចំនួន ២,១៧៥អត្តសញ្ញាណប័ណ្ណ ធ្វើអត្រានុកូលដ្ឋានគ្រប់ប្រភេទចំនួន ៨៥១នាក់ ផ្តល់កម្មសិទ្ធិដីធ្លីសរុបចំនួន ៣,០៣៦កម្មសិទ្ធិ រៀបចំផែនការកំណត់តំបន់ប្រើប្រាស់ដីធ្លីមានចំនួនសរុប ១,៧៩៤នាក់ និងសេវាផ្សេងៗទៀតបានធ្វើជូន ប្រជាជន តាមសំណូមពរ និងទាន់ពេលវេលា។

ការទំនាក់ទំនង ការគាំទ្រ និងសហប្រតិបត្តិការ រវាងរដ្ឋបាលឃុំជាមួយរដ្ឋបាលក្រុង ស្រុក ខេត្ត មន្ទីរអង្គភាពនានា រយៈពេល៥ឆ្នាំ ឃុំបានធ្វើការទំនាក់ទំនងស្វែងរកការងារគាំទ្រ ពីស្រុក ខេត្ត អង្គភាពនានា មន្ទីរវិស័យ អង្គការ សប្បុរជន និងដៃគូរអភិវឌ្ឍន៍ រូបវន្ត និងអរូបវន្តដើម្បីសំដៅអោយជីវភាពប្រជាពលរដ្ឋកាន់តែប្រសើរឡើង និងកាត់បន្ថយភាពក្រីក្រ។

## ២. វិស័យសេដ្ឋកិច្ច

ការបង្កបង្កើនផលរយៈពេល៤ឆ្នាំ (២០១៤-២០១៧) ខាងផ្នែកកសិកម្ម ឃុំជីពោទី២មាន ស្រះត្រីចំនួន ៤៣ស្រះ កសិដ្ឋាចចិញ្ចឹមទាមានចំនួន ១កន្លែង គោ ក្របីមានចំនួនប្រហែ ២,០២៥ក្បាល គ្រួសារចិញ្ចឹមជ្រូកមានចំនួនប្រហែ ២៥៩ក្បាល ពូជមាន់ ២០ក្បាល ពូជក្រូចឆ្មា ៤៥ដើម ចាក់វ៉ាក់សាំងគោ ក្របី ១២៣ក្បាល អណ្តូងស្នប់ ៥៩អណ្តូង ឡជីឧស្ម័ន ៥ឡ និងបណ្តុះបណ្តាលការចិញ្ចឹមជ្រូក ១៨គ្រួសារ។

ជីវភាពរស់នៅរបស់ប្រជាជនមានភាពធូរធាសមរម្យ ជាមធ្យម ១គ្រួសារមាន កង់ រទេស និងម៉ូតូ ១គ្រឿង រយន្តដឹកជញ្ជូនទំនិញ ៣៧គ្រឿង គ្រឿងយន្តកសិកម្ម ៣៧០គ្រឿង រថយន្តឈ្នួលដឹកអ្នកដំណើរមាន ១៩គ្រឿង ។

## ៣. វិស័យសុខាភិបាល

- ផ្តល់ការចាក់វ៉ាក់សាំងដស់ស្ត្រី និងកុមារ មានចំនួនសរុប ៩៣០នាក់ ធ្វើឡើងនៅទូទាំងឃុំ
- ផ្តល់សេវាសុខភាពស្ត្រីមានផ្ទៃពោះ មានចំនួនសរុប ៤៧៥នាក់ ធ្វើឡើងនៅទូទាំងឃុំ
- ផ្តល់កម្មវិធីពន្យាកំណើត មានចំនួនសរុប៤៧៥នាក់ ទូទាំងឃុំ ធ្វើឡើងមានចំនួន១២លើក
- បណ្តុះបណ្តាលសុខភាពអនាម័យ មានចំនួន ២,៥៤០នាក់ នៅទូទាំងឃុំ
- ផ្សព្វផ្សាយពីសេវាសុខភាពនៅមណ្ឌល់សុខភាព ចំនួន៥៦០នាក់ នៅមណ្ឌលសុខភាព

- ផ្តល់ធុងចម្រោះទឹកស្អាត ចំនួន៣៩៥ធុង អ្នកទទួលផលសរុប ៣៩៥នាក់
- បង្គន់អនាម័យ ៤៦៦បង្គន់។

**៤. វិស័យអប់រំ**

- សាងសង់សាលារៀន ចំនួន ៣បន្ទប់ នៅភូមិទូវិហា សម្រាប់សិស្ស ១៨០នាក់
- អាហារូបករណ៍សិស្សក្រីក្រ ចំនួន៣០នាក់
- ផ្សព្វផ្សាយជម្រុញឲ្យឪពុកម្តាយនាំកូនចូលរៀន ចំនួន ១១៨នាក់។

**៥. វិស័យគមនាគមន៍**

| | | |
|---|---|---|
| ○ ផ្លូវក្រាលគ្រួសក្រហមបានធ្វើថ្មី | ៣ខ្សែ | ប្រវែង ៧,៧៦៧ម៉ែត្រ |
| ○ សាងសង់ផ្លូវបេតុង | ១ខ្សែ | ប្រវែង ២៥៥ម៉ែត្រ |
| ○ ជួសជុលផ្លូវក្រាលគ្រួសក្រហម | ២ខ្សែ | ប្រវែង ៣,០៧១ម៉ែត្រ |
| ○ ជួសជុលផ្លូវក្រឡុកសំបុកមាន់ | ២ខ្សែ | ប្រវែង ២,៤៨០ម៉ែត្រ |
| ○ ឈូសឆាយបើកផ្លូវលំ | ២ខ្សែ | ប្រវែង ៣៣២ម៉ែត្រ។ |

**៦. វិស័យសង្គមកិច្ច**

| | |
|---|---|
| ○ ជួយជនក្រីក្រគ្មានទីពឹង | ១៣៥នាក់ |
| ○ សាងសង់ផ្ទះជូនជនក្រីក្រ | ១៥ផ្ទះ |
| ○ បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់ជនពិការ | ១២នាក់។ |

**៧. រដ្ឋាបាលសន្តិសុខ**

| | |
|---|---|
| ○ ជំរុញការបញ្ចប់សកម្មភាពល្បែងស៊ីសង | ១២២នាក់ |
| ○ ផ្សព្វផ្សាយច្បាប់ចរាចរណ៍ជើងគោក | ១៨៧នាក់ |
| ○ ផ្សព្វផ្សាយច្បាប់ព្រហ្មទណ្ឌ | ១៩២នាក់ |
| ○ ជំរុញការបង្ក្រាបសកម្មភាពក្មេងទំនើង | ២៨នាក់ |
| ○ ផ្សព្វផ្សាយច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារ | ១២៧នាក់ |
| ○ ច្បាប់ផ្សព្វផ្សាយច្បាប់ប្រឆាំងការជួញដូរស្ត្រី និង កុមារ | ២៣០នាក់ |
| ○ ផ្សព្វផ្សាយច្បាប់ចំណាក់ស្រុកមានសុវត្ថិភាព | ២៣០នាក់។ |

**៨. ការលើកម្ពស់សមាសភាពសមធម៌យេនឌ័រ និងការជួយជនរងគ្រោះ**

ក. សិក្ខាសិលាស្តីពីការលើកម្ពស់ស្ត្រី

នៅក្នុងឃុំជីពោទី២ ទទួលបានជោគជ័យក្នុងការលើកកម្ពស់សមាសភាពសមធម៌ជាពិសេស

គ.ក.ន.ក បានការចូលរួមយ៉ាងច្រើនក្នុងការយកចិត្តទុកដាក់ដល់ស្ត្រី និងកុមារ។ ទន្ទឹមនឹងនេះ ក៏មានការចូលរួមពីអង្គមួយចំនួន ក្នុងការលើកម្ពស់សមាសភាពសមធម៌ ដូចជា អង្គការ Water set h បានបណ្តុះបណ្តាលដល់ស្ត្រីចំនួន ៥នាក់ យល់ដឹងពីការលើកកម្ពស់ស្ត្រី។

ខ. ការជួយជនរងគ្រោះនៅក្នុងឃុំ

ដោយមានការយកចិត្តទុកដាក់ ពីក្រុមប្រឹក្សាឃុំ និង នគបាលសន្តិសុខឃុំ តែងតែបង្ក្រាប់រាល់អំពើរហិង្សារទៅលើស្ត្រី នឹងបានអនុវត្តទៅតាមផ្លូវច្បាប់ ដើម្បីធ្វើយ៉ាងណាអោយស្ត្រី មានសិទ្ធិពេញលេញក្នុងការរស់នៅ ។ ជាក់ស្តែង នគបាលនៅក្នុងឃុំជីពោទ៍ទី២ បានបង្ក្រាបអំពើហិង្សាទៅលើស្ត្រី ចំនួន១២៧នាក់។

## ២.៥ បញ្ហាដែលជួបប្រទះ និង ដំណោះស្រាយ

### ២.៥.១ បញ្ហាជួបប្រទះ

ទន្ទឹមនឹងភាពជោគជ័យក្នុងការអភិវឌ្ឍជីវភាពប្រជាជននៅក្នុងឃុំជីពោទី២ ទាំងអស់ខាងលើនេះ ឃុំក៏ជួបនូវបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម:

- ផ្លូវពិបាកធ្វើដំណើរ : បញ្ហានេះកើតមានចំនួន ១០ភូមិ ហើយមូលហេតុមកពី ផ្លូវចាស់ទ្រុឌទ្រោម ទឹកហូរកាត់ផ្លូវ ទំនុបទឹកដាច់ និងទ្វាទឹកខូច។
- ទិន្នផលស្រូវថយចុះ : បញ្ហានេះកើតឡើងទូទាំងឃុំ ដោយសារតែ ធ្វើស្រែតាមទម្លាប់ ធ្វើស្រែខ្វះបច្ចេកទេស និងខ្វះជីវជាតិ។
- ទិន្នផលសត្វថយចុះ : បញ្ហានេះកើតឡើងទូទាំងឃុំ ដោយសារតែ ខ្វះបច្ចេកទេសចិញ្ចឹមជ្រូក ខ្វះបច្ចេកទេសចិញ្ចឹមមាន់ទា ខ្វះបច្ចេកទេសចិញ្ចឹមគោក្របី ខ្វះពូជគោក្របី
- ទិន្នផលត្រីធ្លាក់ចុះ : បញ្ហានេះកើតឡើងទូទាំងឃុំ បញ្ហាកើតឡើងដោយសារតែ ប្រើឧបករណ៍នេសាទ ខុសច្បាប់ និងខ្វះពូជត្រី
- ប្រជាពលរដ្ឋមានជម្ងឺច្រើន : បញ្ហាបានកើតឡើងទូទាំងឃុំ ដោយសារតែ ខ្វះការយល់ដឹងពីការការពារ និងថៃទាំសុខភាពតាមទម្លាប់។
- អសន្តិសុខក្នុងឃុំ : បញ្ហានេះកើតឡើងទូទាំងឃុំ ដោយសារតែមាន ចោរលួច-ឆក់ ចែកចាយនិងប្រើប្រាស់គ្រឿងញៀន អំពើរហិង្សាក្នុងគ្រួសារ។
- ទំនាស់ដីធ្លី : កើតឡើងទូទាំងឃុំ កើតឡើងដោយសារតែ រំលោភបំពានដីធ្លី ព្រំប្រទល់មិនច្បាស់លាស់ ប្រជាពលរដ្ឋមិនយល់ដឹង ពីច្បាប់ភូមិបាល។
- ប្រជាពលរដ្ឋមិនមកចុះអត្រានុកូលដ្ឋានគ្រប់ៗគ្នា: កើតឡើងទូទាំងឃុំ បញ្ហាកើតឡើង

ដោយសារ ប្រជាពលរដ្ឋមិនយល់ដឹងពីផលប្រយោជន៍សំបុត្រអត្រានុកូលដ្ឋាន។

- កុមារមិនបានចូលរៀន : កើតឡើងទូទាំងឃុំ បញ្ហាកើតឡើងដោយសារតែ ឪពុកម្ដាយខ្វះការយល់ដឹងពីសារប្រយោជន៍នៃការសិក្សា ក្មេងគេចសាលា គ្រួសារក្រីក្រ សាលាភក់ជ្រាំ ខ្វះសៀវភៅក្នុងបណ្ណាល័យ។
- អំពើរហិង្សាក្នុងគ្រួសារ : កើតឡើងទូទាំងឃុំ បញ្ហាកើតឡើងដោយសារតែ ប្រច័ណ្ឌ ខ្វះការយោគយល់គ្នា
- ចំណាក់ស្រុក : កើតឡើងទូទាំងឃុំ ហើយការធ្វើចំណាក់ស្រុកគឺគ្មានសុវត្ថិភាព។

### ២.៥.២ ដំណោះស្រាយ

- ផ្លូវពិបាកធ្វើដំណើរ : ដំណោះស្រាយចំពោះបញ្ហាទាំងអស់នេះគឺ ធ្វើការជួសជុលផ្លូវក្រាលគ្រួសក្រហម និង សាងសង់លូកាត់ផ្លូវ។
- ទិន្នផលស្រូវថយចុះ : ដំណោះស្រាយចំពោះបញ្ហានេះគឺ ស្ដារប្រឡាយស្រោចស្រព ជួសជុលទំនប់ទឹក សាងសង់ទ្វាទឹក វគ្គបណ្តុះបណ្តាលបច្ចេកទេសការដាំដំណាំស្រូវ វគ្គស្រែបង្ហាញដំណាំស្រូវ វគ្គបច្ចេកទេសប្រព័ន្ធកសិកម្មចម្រុះ វគ្គបច្ចេកទេសជីកំប៉ុស្ត៍ វគ្គបច្ចេកទេសកែប្រែគុណភាពដី។
- ទិន្នផលសត្វថយចុះ : បញ្ហានេះត្រូវបានដោះស្រាយគឺ ធ្វើការបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វ វគ្គបច្ចេកទេសចិញ្ចឹមជ្រូក វគ្គបច្ចេកទេសចិញ្ចឹមមាន់-ទា វគ្គបច្ចេកទេសផលិតចំណីសត្វ វគ្គបច្ចេកទេសចិញ្ចឹមគោ-ក្របី ចាក់វ៉ាក់សាំងការពារជម្ងឺសត្វ វគ្គបណ្តុះបណ្តាល និង ពង្រឹងភ្នាក់ងារសុខភាពសត្វភូមិ ផ្តល់ពូជគោ-ក្របី ផ្តល់ពូជជ្រូក ផ្តល់ពូជមាន់-ទា។
- បញ្ហាទិន្នផលត្រីថយចុះ : ដំណោះស្រាយគឺ អប់រំចំណេះដឹងពីបរិស្ថាន និងច្បាប់បរិស្ថាន អប់រំផ្សព្វផ្សាយច្បាប់ជលផល ពង្រឹងវិធានការទប់ស្កាត់បទល្មើសនេសាទ គាំទ្រសកម្មភាពសហគមន៍នេសាទ ពង្រឹងវិធានការការពារព្រៃលិចទឹក បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រី វគ្គបច្ចេកទេសចិញ្ចឹមត្រីក្នុងថង់ប្លាស្ទិក ផ្តល់ពូជត្រីចិញ្ចឹម។
- ប្រជាពលរដ្ឋមានជម្ងឺច្រើន : ដំណោះស្រាយគឺ បណ្តុះបណ្តាលវគ្គអប់រំចំណេះដឹងអំពីជម្ងឺអេដស៍ ជួយគាំទ្រអ្នកផ្ទុកមេរោគអេដស៍ អប់រំចំណេះដឹងពីជម្ងឺគ្រុនឈាម និងវិធានការការពារផ្តល់មុង និងទឹកជ្រលក់មុង ដើម្បីការជម្ងឺគ្រុនចាញ់ ផ្តល់ការព្យាបាលជម្ងឺគ្រុនចាញ់ ផ្សព្វផ្សាយជម្ងឺគ្រុនផ្តាសសាយបក្សី អប់រំផ្សព្វផ្សាយអនាម័យដល់ប្រជាជនមូលដ្ឋាន ផ្សព្វផ្សាយពីសេវាសុខភាពនៅមណ្ឌលសុខភាព អប់រំចំណេះដឹងពីការថែទាំសុខភាពបឋម

ស្ត្រីនិងកុមារ ផ្តល់ថ្នាំជីវជាតិA និងថ្នាំជាតិដែក កម្មវិធីពន្យាកំណើត ផ្តល់ការចាក់វ៉ាក់សាំងដល់ស្ត្រី និងកុមារ អប់រំថែទាំម្តាយ និងទារក មុននិងក្រោយសម្រាល បណ្តុះបណ្តាលភ្នាក់ងារសុខភាពភូមិ សេវាសុខភាពស្ត្រីមានផ្ទៃពោះ ផ្តល់ការអប់រំចំណេះដឹងពីការបន្តពូជ សាងសង់អគារសម្រាប់អ្នកជម្ងឺ បង្កើនប្រសិទ្ធភាពមធ្យោបាយដឹកអ្នកជម្ងឺ អប់រំសុខភាពអនាម័យ សង់បង្គន់អនាម័យ ផ្តល់មធ្យោបាយចម្រោះទឹកស្អាត និងជីកអណ្តូងស្នប់

- អសន្តិសុខក្នុងឃុំ : ដំណោះស្រាយ ពង្រឹងសកម្មភាពក្រុមប្រជាការពារ វិធានការទប់ស្កាត់ការជួញដូរប្រើប្រាស់គ្រឿងញៀន ផ្សព្វផ្សាយច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារ ផ្សព្វផ្សាយច្បាប់ ក្រមរដ្ឋប្បវេណី និងព្រហ្មទណ្ឌ ផ្សព្វផ្សាយច្បាប់ចរាចរ និងសណ្តាប់ធ្នាប់សារធារណៈដល់ប្រជាពលរដ្ឋ ប្រមូលក្រុមជនពាលដើម្បីធ្វើការអប់រំ ផ្សព្វផ្សាយច្បាប់ប្រឆាំងការជួញដូរស្ត្រី និងកុមារ ដាក់ផ្លាកសញ្ញាចរាចរ ជំរុញសកម្មភាពបង្ក្រាប់ល្បែងស៊ីសង បង្កើនការបង្ក្រាប់បទល្មើសនានា អប់រំឲ្យដឹងពីការប្រើប្រាស់គ្រឿងញៀន អប់រំប្រជាពលរដ្ឋឲ្យយល់ដឹងច្បាស់ពីការប្រើប្រាស់អាវុទជាតិផ្ទុះ។
- ទំនាស់ដីធ្លី : ដំណោះស្រាយ អប់រំផ្សព្វផ្សាយពីច្បាប់ភូមិបាល ផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី ផ្សព្វផ្សាយ និងជម្រុញការងាចុះបញ្ជីដីធ្លី រៀបចំផែនការកំណត់តំបន់ប្រើប្រាស់ដីធ្លី កំណត់តំបន់ប្រើប្រាស់ដីព្រៃសមស្រប។
- ប្រជាពលរដ្ឋមិនមកចុះអត្រានុកូលដ្ឋានគ្រប់គ្នា : ដំណោះស្រាយ ជំរុញពង្រឹងកិច្ចការចុះបញ្ជីអត្រានុកូលដ្ឋាន ផ្តល់សេវាចុះបញ្ជីអត្រានុកូលដ្ឋានតាមភូមិ។
- កុមារមិនបានចូលរៀន : ដំណោះស្រាយ ជួសជុលអគា និងបន្ទប់ នៅសាលាបឋមសិក្សា ផ្សព្វផ្សា និងជម្រុញឲ្យឪពុកម្តាយនាំកូនមកចុះឈ្មោះចូលរៀន ឧបត្ថម្ភកុមារក្រីក្រអោយចូលរៀន ចាក់ដីនៅទីធ្លាសាលាបឋមសិក្សា អាហារូបករណ៍ដល់សិស្សក្រីក្រ ផ្តល់គ្រឿងសង្ហារឹមដល់សាលាអនុវិទ្យាល័យ។
- អំពើហិង្សាក្នុងគ្រួសារ : ដំណោះស្រាយ ផ្សព្វផ្សាយច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារ ផ្សព្វផ្សាយបញ្ញាបយេនឌ័រ និងសមធម៌ អប់រំពីសិទ្ធ តួនាទី បុរស និងស្ត្រី។
- ចំណាក់ស្រុក : ដំណោះស្រាយ ផ្សព្វផ្សាយពីច្បាប់ចំណាក់ស្រុកមានសុវត្ថិភាព បណ្តុះបណ្តាលវិជ្ជាជីវៈ
- ជនពិការ : ដំណោះស្រាយ បង្កើតមុខរបរសម្រាប់ជនពិការ សាងសង់អគាសាធារណៈឲ្យមានជម្រាល ផ្តល់ឧបករណ៍ជំនួយដល់ជនពិការ។

## ២.៦ ទិសដៅអនាគតក្នុងការអភិវឌ្ឍរយៈពេល៥ឆ្នាំ (២០១៧-២០២២)[20]

### ២.៦.១ ចក្ខុវិស័យអភិវឌ្ឍន៍

ឆ្នាំ២០១៧-២០២២ ខាងមុខនេះ ប្រជាពលរដ្ឋក្នុងឃុំជីពាទ៍ទី២ មានជីវភាពរស់នៅសមរម្យ ធានាបាននៅសន្តិសុខស្បៀង មានប្រព័ន្ធគមនាគមន៍ល្អប្រសើរ គុណភាពអប់រំត្រូវបានលើកកម្ពស់ ប្រជាពលរដ្ឋ ឲ្យមានសុខភាពល្អបរិបូរណ៍ បរិស្ថានរស់នៅល្អ មានការអភិរក្សធនធានធម្មជាតិ មានការឆ្លើយតបចំពោះគ្រោះមហន្តរាយ បានទាន់ពេលវេលា សន្តិសុខសណ្តាប់ធ្នាប់សង្គមមានភាពល្អប្រសើរ។

### ២.៦.២ គោលបំណងអភិវឌ្ឍន៍

ដើម្បីសម្រេចឲ្យបាននូវចក្ខុវិស័យខាងលើក្រុមប្រឹក្សាឃុំត្រូវរៀនចំគោលបំណងអភិវឌ្ឍន៍ដូចខាងក្រោមៈ

#### ២.៦.២.១ គោលបំណងផ្នែកសេដ្ឋកិច្ច

បង្កើនប្រាក់ចំណូលប្រជាពលរដ្ឋតាមរយៈការកែលម្អប្រព័ន្ធធារាសាស្ត្រហេដ្ឋារចនាសម្ព័ននានា លើកកម្ពស់ការផលិតកសិកម្ម សេវាកម្មឲ្យមានបរិមាណ និងគុណភាពឲ្យស្របតាមបទដ្ឋានបច្ចេកទេស និងពង្រឹងសម្ថភាពធនធានមនុស្ស។ ដើម្បីសម្រេចគោលបំណងនេះ រដ្ឋបាលឃុំបានរៀបចំគោលបំណងយ៉ាងច្បាស់លាស់ តាមវិស័យមានជាអាទ៏៖

-ការបង្កើនទិន្នផលផលិតផលកសិកម្ម

-ការបង្កើនប្រាក់ចំណូលក្នុងគ្រួសារ។

#### ២.៦.២.២ គោលបំណងផ្នែកសង្គមកិច្ច

លើកកម្ពស់សុខភាពប្រជាពលរដ្ឋ តាមរយៈការកាត់បន្ថយអត្រាមរណៈភាពមាតា និងទារក ការទប់ស្កាត់នៅការរីករាលដាលជម្ងឺឆ្លង ជម្ងឺមិនឆ្លង ការផ្គត់ផ្គង់ទឹកស្អាត ការអប់រំសុខភាពអនាម័យ ការលើកកម្ពស់ គុណភាពអប់រំតាមរយៈការអប់រំមាតាបិតាឲ្យបញ្ជូនកុមារគ្រប់អាយុសិក្សាចូលសាលា ការកសាងនៅអគាសិក្សា និងការផ្តល់គ្រូតាមសាលាតំបន់ជនបទ។ ដើម្បីសម្រេចគោលបំណងសង្គមទាំងមូល ត្រូវសម្រេចគោលបំណង មួយចំនួនដូចខាងក្រោម៖

-កុមារគ្រប់អាយុបានចូលរៀនគ្រប់ៗគ្នា

-មានអ្នកវិនិយោគទុនលើប្រព័ន្ធទឹកស្អាតជនបទ។

[20] ដកស្រង់ចេញពីសៀវភៅផែនការអភិវឌ្ឍរយៈពេល៥ឆ្នាំ(២០១៧-២០២២) របស់ឃុំជីពាទ៍ទី២

**២.៦.២.៣ គោលបំណងផ្នែកការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ**

លើកកម្ពស់បរិស្ថានរស់នៅតាមរយៈការគ្រប់គ្រងកាកសំណល់ ការថែរក្សានៅតំបន់អភិរក្សធនធានធម្មជាតិ ការកាត់បន្ថយទំនាស់ដីធ្លី និងការយកចិត្តទុកដាក់លើការគ្រប់គ្រងគ្រោះមហន្តរាយ។ ដើម្បីសម្រេច គោលបំណងនេះត្រូវសម្រេចឲ្យបានគោលបំណងលម្អិតមួយចំនួនជាមុនៈ

-លើកកម្ពស់បរិស្ថានរស់នៅ

-លុបបំបាត់បទល្មើសតំបន់អភិរក្ស

-ការបន្ថយទំនាស់ដីធ្លី

-ការយល់ដឹងពីគ្រោះមហន្តរាយ។

**២.៦.២.៤ គោលបំណងផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ**

ការកាត់បន្ថយគ្រោះថ្នាក់ចរាចរ និងបទល្មើសផ្សេងៗ។ ចូលរួមកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ ការជម្រុញ និងការលើកកម្ពស់ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋប្រកបដោយគុណភាព និងប្រសិទ្ធិភាព។ ដើម្បីសម្រេច គោលបំណងនេះត្រូវសម្រេចឲ្យបានគោលបំណងលម្អិតមួយចំនួនដូចខាងក្រោមៈ

-កាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍

-កាត់បន្ថយការធ្វើចំណាក់ស្រុក

-កាត់បន្ថយអំពើហឹង្សាក្នុងគ្រួសារ។

### ២.៦.៣ គោលដៅអភិវឌ្ឍន៍

ដើម្បីសម្រេចបាននូវគោលបំណងអភិវឌ្ឍន៍ និងចក្ខុវិស័យខាងលើ ចាំបាច់ក្រុមប្រឹក្សាឃុំត្រូវសម្រេច គោលដៅចម្បងៗតាមវិស័យដូចខាងក្រោមៈ

**២.៦.៣.១ គោលដៅផ្នែកសេដ្ឋកិច្ច**

-កសិករមានចំណេះដឹងលើបច្ចេកទេសកសិកម្ម

-កសិករមានប្រភពទឹកសម្រាប់ស្រោចស្រព

-កសិករមានស្រូវពូជសុទ្ធដាំដុះ

-បង្កើនគុណភាពដី

-ប្រជាពលរដ្ឋមានជំនាញវិជ្ជាជីវៈ

-ប្រជាពលរដ្ឋមានដើមទុនប្រកបអាជីវកម្ម។

**២.៦.៣.២ គោលដៅផ្នែកសង្គមកិច្ច**

-ឪពុកម្តាយបញ្ជូនកូនទៅសាលាគ្រប់ៗគ្នា

-មានគ្រូបង្រៀនគ្រប់គ្រាន់នៅតាមសាលា

-កាត់បន្ថយការដឹកជញ្ជូនលើសទម្ងន់

-កាត់បន្ថយការខូចផ្លូវ

-បញ្ចៀសការហូរសឹកផ្លូវដោយទឹកជំនន់

-ប្រជាពលរដ្ឋគ្រប់មូលដ្ឋានមានទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់

-មានអ្នកវិនិយោគទុនលើប្រព័ន្ធទឹកស្អាតជនបទ

-មានការថែទាំប្រព័ន្ធទឹកស្អាតជនបទ

-នៅតាមជនបទមានបង្គន់អនាម័យប្រើប្រាស់

-មានការយល់ដឹងពីការថែទាំសុខភាព

-មានមណ្ឌលសុខភាពផ្តល់សេវាសុខភាពគ្រប់គ្រាន់នៅមូលដ្ឋាន

-ប្រជាពលរដ្ឋមានការយល់ដឹងពីសុខភាពគ្រប់គ្រាន់នៅមូលដ្ឋាន

-ប្រជាពលរដ្ឋមានការយល់ដឹងពីសុខភាពបន្តពូជ

-ប្រជាពលរដ្ឋមានការយល់ដឹងពីជម្ងឺឆ្លង។

**២.៦.៣.៣ គោលដៅផ្នែកការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ**

-លើកកម្ពស់បរិស្ថានរស់នៅ

-មិនមានការបំពុលបរិស្ថានពីឧស្សាហាកម្ម សិប្បកម្ម

-ប្រជាពលរដ្ឋមានប័ណ្ណកម្មសិទ្ធិដីធ្លីប្រើប្រាស់គ្រប់គ្នា

-ប្រជាពលរដ្ឋមានការយល់ដឹងពីសិទ្ធកាន់កាប់ដីធ្លី។

**២.៦.៣.៤ គោលដៅផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ**

-អ្នកដំណើរអាចដឹងជាមុនពីស្ថានភាពផ្លូវ

-ប្រជាពលរដ្ឋមានការយល់ដឹងពីច្បាប់ចរាចរណ៍

-ប្រជាពលរដ្ឋមានជំនាញប្រកបអាជីវកម្ម

-មិនមានការលេងល្បែងស៊ីសងគ្រប់ប្រភេទ

-ប្រជាពលរដ្ឋមានការយល់ដឹងពីច្បាប់។

### ២.៦.៤ យុទ្ធសាស្ត្រអភិវឌ្ឍន៍

ដើម្បីសម្រេចទៅបាននូវចក្ខុវិស័យ គោលបំណងអភិវឌ្ឍន៍ និងគោលដៅអភិវឌ្ឍន៍ខាងលើ ចាំបាច់ក្រុមប្រឹក្សាឃុំត្រូវសម្រេច យុទ្ធសាស្ត្រអភិវឌ្ឍន៍ចម្បងៗដូចខាងក្រោមៈ

#### ២.៦.៤.១ យុទ្ធសាស្ត្រអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច

-បណ្តុះបណ្តាលបច្ចេកទេសកសិកម្ម

-សាងសង់ទំនប់ទឹក

-ជួសជុលទំនប់ទឹក

-ជីកប្រឡាយ

-ស្តារប្រឡាយ

-ស្តារអាងស្តុកទឹក

-បណ្តុះបណ្តាលបច្ចេកទេសបង្កាត់ពូជស្រូវ

-បណ្តុះបណ្តាលបច្ចេកទេសធ្វើជីកំប៉ុស្តិ៍

-ផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមមាន់

-ផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមជ្រូក

-ផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រី

-ផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមគោ+ក្របី

-ផ្សព្វផ្សាយការងារកសិកម្ម

-បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈផ្សេងៗ

-ផ្តល់ដើមទុនដល់ប្រជាពលរដ្ឋប្រកបអាជីវកម្ម

-សាងសង់ផ្លូវបេតុង

-សាងសង់ផ្លូវក្រាលគ្រួសក្រហម

#### ២.៦.៤.២ យុទ្ធសាស្ត្រអភិវឌ្ឍន៍ផ្នែកសង្គមកិច្ច

-ផ្សព្វផ្សាយការយល់ដឹងពីសារៈសំខាន់នៃការសិក្សា

-ផ្សព្វផ្សាយការយល់ដឹងពីច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធការងារដឹកជញ្ជូន

- ជួសជុលប្រព័ន្ធទឹកស្អាតជនបទ

-សាងសង់អណ្តូងស្នប់

-សាងសង់អណ្តូងលូ

-ជួសជុលអណ្តូងស្នប់

-ជួសជុលអណ្តូងលូ

-ស្តារស្រះ

-ជម្រុញ និងលើកកម្ពស់ការផ្តល់សេវាសាធារណៈ

-បណ្តុះបណ្តាលបច្ចេកទេសថែទាំប្រព័ន្ធទឹកស្អាតជនបទ

-សាងសង់បង្គន់អនាម័យ

-ជួសជុលមណ្ឌលសុខភាព

-ផ្សព្វផ្សាយការយល់ដឹងពីសុខភាពអនាម័យ

-ផ្សព្វផ្សាយការយល់ដឹងពីសុខភាពបន្តពូជ

-ផ្សព្វផ្សាយការយល់ដឹងពីការឆ្លងជម្ងឺគ្រុនចាញ់

-ផ្សព្វផ្សាយការយល់ដឹងពីការឆ្លងជម្ងឺគ្រុនឈាម។

**២.៦.៤.៣ យុទ្ធសាស្រ្តអភិវឌ្ឍន៍ផ្នែកការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ**

-ផ្តល់ធុងសម្រាប់តាមទីសាធារណៈ

-បង្កើតសេវាប្រមូលសម្រាមតាមទីសាធារណៈ

-បង្កើតទីតាំងចាក់សម្រាម

-ផ្សព្វផ្សាយច្បាប់បរិស្ថាន

-ផ្សព្វផ្សាយវិធានការការពារការបំពុលបរិស្ថាន

-ផ្សព្វផ្សាយវិធានការការពារព្រៃលិចទឹក

-ផ្សព្វផ្សាយវិធានការការពារការបំពុលបរិស្ថាន

-ផ្សព្វផ្សាយវិធានការការពារព្រៃលិចទឹក

-ផ្សព្វផ្សាយការពារសហគមន៍នេសាទ

-វាស់វែងផ្តល់ប័ណ្ណកម្មសិទ្ធិជាលក្ខណៈប្រព័ន្ធ

-វាស់វែងផ្តល់ប័ណ្ណកម្មសិទ្ធិជាលក្ខណៈដាច់ដោយដុំ

-ផ្សព្វផ្សាយការយល់ដឹងពីច្បាប់ភូមិបាល។

**២.៦.៥ យុទ្ធសាស្រ្តអភិវឌ្ឍន៍ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ**

-រៀបចំស្លាកសញ្ញាចរាចរណ៍តាមដងផ្លូវ

-ផ្សព្វផ្សាយច្បាប់ចរាចរណ៍ផ្លូវគោក

-បណ្តុះបណ្តាលជំនាញជួសជុលម៉ូតូ

-បណ្តុះបណ្តាលជំនាញបច្ចេកទេសជួសជុលទូរស័ព្ទ+ទូរទស្សន៍

-បណ្តុះបណ្តាលជំនាញជួសជុលគោយន្ត

-បណ្តុះបណ្តាលជំនាញផ្សារដែក+សំណង់+កាត់កញ្ចក់

-បណ្តុះបណ្តាលជំនាញជួសជុលម៉ាស៊ីនត្រជាក់

-បណ្តុះបណ្តាលជំនាញកាត់ដេរសម្លៀកបំពាក់

-បណ្តុះបណ្តាលជំនាញថែរក្សាសម្ផស្ស

-បណ្តុះបណ្តាលជំនាញកាត់សក់

-បណ្តុះបណ្តាលជំនាញកែឆ្នៃចំណីអាហារ

-បណ្តុះបណ្តាលជំនាញអាជីវកម្មខ្នាតតូច

-ផ្សព្វផ្សាយការយល់ដឹងពីធ្វើចំណាកស្រុក

-ចាត់វិធានការបង្ក្រាបការលេងល្បែងស៊ីសង

-ផ្សព្វផ្សាយការយល់ដឹងពីច្បាប់អំពើហឹង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ

### ២.៦.៦ ក្របខ័ណ្ឌអភិវឌ្ឍន៍

ចក្ខុវិស័យៈ នៅឆ្នាំ២០១៧-២០២២ខាងមុខ ប្រជាពលរដ្ឋនៅក្នុងឃុំជីរោទ៍ទី២ មានជីវភាពរស់នៅសមរម្យ ធានាបាននៅសន្តិសុខស្បៀង មានប្រព័ន្ធគមនាគម៍ល្អប្រសើរ គុណភាពការអប់រំត្រូវបានលើកកម្ពស់ ប្រជាពលរដ្ឋមាន សុខភាពល្អបរិបូរណ៍ បរិស្ថានរស់នៅល្អ មានការអភិរក្សធនធានធម្មជាតិ មានការឆ្លើយតបចំពោះគ្រោះមហន្តរាយ បានទាន់ពេលវេលា សន្តិសុខសណ្តាប់ធ្នាប់សង្គមមានភាពល្អប្រសើរ។

#### ក. ផ្នែកសេដ្ឋកិច្ច

គោលបំណងអភិវឌ្ឍន៍៖ បង្កើនប្រាក់ចំណូលប្រជាពលរដ្ឋតាមរយៈការកែលម្អ ហេដ្ឋារចនាសម្ព័ននានា ងាយស្រួលក្នុងការដឹកកសិផលចេញ-ចូលទីផ្សា លើកកម្ពស់ផលិតផលកសិកម្ម សេវាកម្មឲ្យមានបរិមាណ និងគុណភាពឲ្យសមស្របតាមបទដ្ឋានបច្ចេកទេស និងការពង្រឹងសម្ថភាពធនធានមនុស្ស។

#### ខ. ផ្នែកសង្គមកិច្ច

គោលបំណងៈ លើកកម្ពស់សុខមាលភាពប្រជាពលរដ្ឋ តាមរយៈការកាត់បន្ថយអត្រាម

រណៈភាពមាតា និងទារក ការទប់ស្កាត់ការរីករាលដាលជម្ងឺឆ្លង ជម្ងឺមិនឆ្លង ការផ្គត់ផ្គង់ទឹកស្អាត់ ការអប់រំសុខភាពអនាម័យ ការលើកកម្ពស់ គុណភាពអប់រំតាមរយៈការអប់រំមាតាបិតាឲ្យបញ្ជូនកុមារគ្រប់អាយុសិក្សាចូលសាលា ការកសាងអគាសិក្សានិងការផ្តល់គ្រូតាមសាលាតំបន់ជនបទ។

**គ. ផ្នែកការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន គ្រោះមហន្តរាយ និងការ ប្រែប្រួល អាកាសធាតុ**

គោលបំណង: លើកកម្ពស់បរិស្ថានរស់នៅតាមរយៈការគ្រប់គ្រងកាកសំណល់ ការថែរក្សាតំបន់អភិរក្សធនធានធម្មជាតិ ការកាត់បន្ថយទំនាស់ដីធ្លី និងការយកចិត្តទុកដាក់លើការគ្រប់គ្រងគ្រោះមហន្តរាយ

**ឃ. ផ្នែករដ្ឋបាល សន្តិសុខ**

គោលបំណង: ការកាត់បន្ថយគ្រោះថ្នាក់ចរាចរ និងបទល្មើផ្សេងៗ។ ចូលរួមកាត់បន្ថយអំពីហឹង្សាក្នុងគ្រួសារ ការជម្រុញ និងលើកកម្ពស់ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋប្រកបដោយគុណភាព និងប្រសិទ្ធិភាព

# ជំពូកទី៣

# ការពិភាក្សាលើលទ្ធផលស្រាវជ្រាវ

## ៣.១ ការវិភាគលើសមិទ្ធផល

### ៣.១.១ ការគ្រប់គ្រងរដ្ឋបាល

ក្រុមប្រឹក្សាឃុំជីរោទ៍ទី២ មានការសហការខ្ពស់ជាមួយគ្នា ក្នុងការរៀបចំគម្រោងផ្សេងៗក្នុងការអភិវឌ្ឍឃុំ ជាពិសេស បានធ្វើការប្រជុំអាណត្តិទៀងទាត់ជារៀងរាល់ខែ និងការប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា បានប្រជុំអនុម័តលើការងារចាំបាច់ និងកិច្ចការផ្សេងៗទៀត ដែលជាតម្រូវការរបស់ប្រជាពលរដ្ឋ។ លើសពីនេះទៅទៀត ប្រធាន និងសមាជិកក្រុមប្រឹក្សាឃុំ បានយកចិត្តទុកដាក់ខ្ពស់ទៅលើការអនុវត្តគម្រោង រហូតទទួលបានជោគជ័យ មានដូចជា ផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី ៣,០៣៦ប័ណ្ណកម្មសិទ្ធិ បានផ្តល់អត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋចំនួន ២,១៧៥ប័ណ្ណ ធ្វើអត្រានុកូលដ្ឋានគ្រប់ប្រភេទចំនួន ៨៩១នាក់ សំបុត្របញ្ជាក់កំណើត និងសេវាផ្សេងៗទៀត។

ដូចនេះ ការគ្រប់គ្រងរដ្ឋបាល របស់ឃុំជីរោទ៍ទី២ ទទួលបានលទ្ធផលល្អច្រើន និងបានឆ្លើយតបទៅនឹងគម្រោងដែលបានរៀបចំក្នុងចន្លោះ ឆ្នាំ២០១៥-២០១៧។ ជាពិសេស ការផ្តល់សេវាក្នុងការធ្វើលិខិតផ្សេងៗ ជូនប្រជាពលរដ្ឋទាន់ពេលវេលា។

### ៣.១.២ វិស័យសេដ្ឋកិច្ច

#### ៣.១.២.១ ស្ថានភាពមុខរបរចំបងក្នុងវិស័យសេដ្ឋកិច្ចរបស់ឃុំជីរោទ៍ទី២

ក្រាហ្វិកទី១: ស្ថានភាពមុខរបរចំបងរបស់ប្រជាជនក្នុងឃុំ ជីរោទ៍ទី២ (ឯកតា គិតជាគ្រួសារ)




(ដកស្រង់ពីឯកសាររបស់ឃុំ ជីរោទ៍ទី២)

នៅក្នុងឃុំជីរោទ៍ទី២ មានគ្រួសារសរុបចំនួន៣,០៣៤គ្រួសារ។ យោងទៅតាមក្រាហ្វិកទី១ ខាងលើ បញ្ជាក់ថាប្រជាពលរដ្ឋដែលធ្វើកសិកម្មជាចំបងមាន ២,៩១៦គ្រួសារស្មើរនឹង ៧៩.៦% ដែលច្រើនជាងមុខរបរផ្សេងៗ បើធ្វើការប្រៀបធៀបទៅ មុខរបរសិប្បកម្មមាន ៤៦៨គ្រួសារស្មើរនឹង

១៥.៩% មុខរបរជំនាញមាន ៩១៩គ្រួសារស្មើរនឹង ១៣.៦% និង របរសេវាកម្មមាន ៥៩គ្រួសារ ស្មើរនឹង ១.៧% ។

ដូចនេះ សក្តានុពលសេដ្ឋកិច្ចរបស់ឃុំជីពាទ់ទី២ ក្នុងរយៈពេល៥ឆ្នាំ (២០១៥-២០១៧) គឺអាស្រ័យលើវិស័យកសិកម្មជាចំបង និងវិស័យផ្សេងៗទៀតជាវិស័យបន្ទាប់បន្សំនៅក្នុងសេដ្ឋកិច្ចរបស់ឃុំ។

### ៣.១.២.២ វិស័យកសិកម្ម

**ក្រាហ្វិកទី២: ការវាយតម្លៃទិន្នផលស្រូវរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងទិន្នផលស្រូវរបស់ឃុំជីពាទ់ទី២**




(ដកស្រង់ពីក្រសួងកសិកម្ម និកឯកសារឃុំជីពាទ់ទី២)

**ក្រាហ្វិកទី៣: ស្ថានភាពការប្រើប្រាស់ផ្ទៃដីក្នុងការធ្វើស្រែរបស់ឃុំ ជីពាទ់ទី២**




(ដកស្រងពីឯកសារឃុំ ជីពាទ់ទី២)

យោងតាមក្រាហ្វិកទី២ បានបង្ហាញថាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានធ្វើការវាយតម្លៃទូទាំងប្រទេសគឺ ផ្ទៃដីមួយហិកតាជាមធ្យម អាចទទួលបានទិន្នផលស្រូវ ៣,៣៥០តោនក្នុងមួយហិកតា។[21] ដោយឡែក ក្នុងឃុំជីពាទ់ទី២ទទួលបានទិន្នផលស្រូវត្រឹមតែ ១,៥០០តោនប៉ុណ្ណោះ ក្នុងមួយហិកតា។ ទិន្នផលស្រូវដែលទទួលបាន គឺមានកម្រិតទាប មិនអាចឆ្លើយតបទៅនឹងទិន្នន័យជាតិ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឡើយ។ បញ្ហាដែលធ្វើឲ្យទិន្នផល

[21] របាយការណ៍សមិទ្ធិផលការងាររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ស្រូវនៅក្នុងឃុំជីពោទ៍ទី២ ទទួលបានផលទាប ដោយសារតែប្រជាពលរដ្ឋ ធ្វើស្រែតាមទំលាប់មានចំនួនច្រើន។ ជាក់ស្តែង យោងតាមក្រាហ្វិកទី៣ខាងលើ បានបង្ហាញឲ្យឃើញថាផ្ទៃដីធ្វើស្រែតាមទំលាប់ (រងចាំទឹកភ្លៀង)មានចំនួន ៣០,៨៥០ហិកតាស្មើរនឹង ៨៩.៤% ច្រើនជាងផ្ទៃដីធ្វើស្រែដោយប្រព័ន្ធធារាសាស្ត្រមានចំនួន ៣,៦៥០ហិកតាស្មើរនឹង ១០.៦% ដែលធ្វើឲ្យកសិករនៅក្នុងឃុំជីពោទ៍ទី២ ទទួលបានទិន្នផលទាប និងមិនអាចឆ្លើយតបតាមតម្រូវរបស់ទីផ្សារដែលបានឡើយ។

ដូចនេះ សម្ទទ្ធិផលដែលសម្រេចបានលើវិស័យកិសកម្ម របស់ឃុំជីពោទ៍ទី២ ចន្លោះឆ្នាំ ២០១៤-២០១៧ គឺទទួលតិចតួច បើធ្វើកាប្រៀបធៀបសម្ទទ្ធិផលដែលជាទិន្នន័យជាតិដែលបានកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ បញ្ហានេះដោយសារតែរកសិករភាគច្រើនធ្វើស្រែតាមទំលាប់ (រង់ចាំទឹកភ្លៀង)មានចំនួនច្រើន។

### ៣.១.៣ វិស័យសិប្បកម្ម

ក្រុមប្រឹក្សាឃុំជីពោទ៍ទី២ បានកំណត់គោលនយោបាយស្តីពីនីតិវិធី និងបែបបទស្នើសុំបង្កើតកន្លែងសិប្បកម្ម ស្របតាមការកំណត់របស់ ក្រសួងឧស្សាហាកម្ម និង សិប្បកម្ម ក្នុងឆ្នាំ ២០១៦-២០១៧ ដើម្បីបង្កភាពងាយស្រួលសម្រាប់ប្រជាជនក្នុងការធ្វើលិខិត ដើម្បីបង្កើតសហគ្រាសធនតូច និង មធ្យម។[22] បន្ទាប់ពីការអនុវត្តតាមគោលនយោបាយរបស់ ក្រសួងឧស្សាហាកម្ម និង សិប្បកម្ម សមិទ្ធិផលឃុំជីពោទ៍ទី២ សម្រេចបានមានដូចជា សិប្បកម្មថាមពលអគ្គិសនីវិនិយោគដោយក្រុមហ៊ុនឯកជន ដែលមានតម្លៃត្រឹមតែ ១,០៥០រៀល/គីឡូវ៉ាត់ សិប្បកម្មម៉ាស៊ីនកិនស្រូវចំនួន ២៨កន្លែង សិប្បកម្មខ្នាត់តូចចំនួន ៥កន្លែង សេវាកម្មខ្នាតតូច (កាត់សក់)ចំនួន ២៤កន្លែង និង មានការធ្វើចង្អេរ កញ្ជើរ ល្អី កញ្ច្រែង និងសម្ភារៈផ្សេងៗទៀត ហើយផលិតផលទាំងអស់នេះក៏មានទីផ្សារនៅក្នុងស្រុក និង ក្រៅស្រុកដែរ។ វិស័យសិប្បកម្មនេះ បានជួយប្រជាជនក្នុងឃុំជីពោទ៍ទី២ អោយមានការងារធ្វើប្រហែល ៩៥នាក់ ស្មើនឹង០.៦% នៃប្រជាពលរដ្ឋសរុបក្នុងឃុំ។ ជាទស្សនៈវិស័យរបស់ឃុំ ក្នុងការអភិវឌ្ឍលើវិស័យសិប្បកម្មនេះ គឺឃុំធ្វើការពង្រឹងសេវាអគ្គិសនីអោយបានល្អ ដើម្បីបំរើសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ និងសម្រួលតំលៃអគ្គិសនី ធ្វើអោយមានតំលៃសមរម្យ ដើម្បីធ្វើការរួមចំណែកកាត់បន្ថយភាពក្រីក្រ។

ដូចនេះ ឃុំជីពោទ៍ទី២ ទទួលបានប្រយោជន៍ច្រើនពីវិស័យសិប្បកម្ម។ ដោយវិស័យនេះបានជួយអោយប្រជននៅក្នុងឃុំមានការងារធ្វើ មានការអភិវឌ្ឍសេដ្ឋកិច្ចគ្រួសារ និងលុបបំបាត់ភាពក្រីក្រ ស្របតាមយុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាល តំណាក់កាលទី៣។

[22] ដកស្រង់ចេញពីរបាយការណ៍បូកសរុបលទ្ធផលការងាររបស់ក្រសួងឧស្សាហាកម្ម និង សិប្បកម្មក្នុងឆ្នាំ ២០១៧

### ៣.១.៤ វិស័យសេវាកម្ម

ចំនួនគ្រួសារដែលប្រកបរបរសេវាកម្មនៅក្នុងឃុំជីពាទ់ទី២ មានចំនួន ៥៤គ្រួសារ។ វិស័យសេវាកម្មបានចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ចហើយបានកាត់បន្ថយភាពក្រីក្រ និងលុបបំបាត់អត្រាអ្នកគ្មានការងារធ្វើរហូតទៅដល់ ១.៧%នៅក្នុងឃុំជីពាទ់ទី២ ។ ការបំរើលើវិស័យសេវាកម្មនៅក្នុងឃុំ មាន ឡានឈ្នួលដឹកអ្នកដំណើរចំនួន ១៩គ្រឿង រថយន្តដឹកជញ្ជូនទំនិញ ៣៧គ្រឿង គ្រឿងយន្តកសិកម្ម ៣៧០គ្រឿង។ ទន្ទឹមនឹងនេះ ឃុំបានបង្ករភាពងាយស្រួលក្នុងការបងពន្ធ ដោយរៀបចំទីស្នាក់ការបង់ពន្ធ នៅសាលាឃុំ ដើម្បីកុំឲ្យប្រជាពលរដ្ឋ ពិបាកក្នុងការទៅបង់ពន្ធនៅសាខាពន្ធដាខេត្ត ឬនៅធនាគាអេស៊ីលីដាឡើយ។ ការបង់ពន្ធនៅក្នុងឃុំ ជីពាទ់ទី២ លើរថយន្តឈ្នួល រថយន្តដឹកជញ្ជូន និង រថយន្តគ្រប់ប្រភេទ មិនបានកំណត់តម្លៃបង់ពន្ធលើស ឬមានអំពើពុករលួយឡើយ ដោយធ្វើឡើងស្របតាមគោលនយោបាយរបស់ក្រសួងសេដ្ឋកិច្ច និង ហេរញ្ញវត្ថុ ដែលបានកំណត់ដូចខាងក្រោម:[23]

### ក. រថយន្តដឹកអ្នកដំណើរ

តារាងទី១: បង្ហាញពីប្រភេទរថយន្តដឹកអ្នកដំណើរដែលត្រូវបង់ពន្ធក្នុង ឃុំជីពាទ់ទី២

| រថយន្តដឹកអ្នកដំណើរ | កម្រិតប្រាក់ពន្ធសម្រាប់ ១ឆ្នាំ/គ្រឿង |
|---|---|
| រថយន្តដឹកអ្នកដំណើរមានកៅអីដល់ ១៥កៅអី | ១៥០ ០០០រៀល |
| រថយន្តដឹកអ្នកដំណើរធុនមធ្យមមានកៅអីដល់ ១៦កៅអី ដល់ ២៥ កៅអី | ២០០ ០០០រៀល |
| រថយន្តដឹកអ្នកដំណើរធុនធំមានកៅអីលើស ២៥កៅអី | ២៥០ ០០០រៀល |

### ខ. រថយន្តដឹកទំនិញ

តារាងទី២: បង្ហាញពីប្រភេទរថយន្តដឹកទំនិញដែលត្រូវបង់ពន្ធ ក្នុងឃុំជីពាទ់ទី២

| រថយន្តដឹកទំនិញ | កម្រិតប្រាក់ពន្ធសម្រាប់ ១ឆ្នាំ/គ្រឿង |
|---|---|
| ទម្ងន់ឡាន និង ទម្ងន់ផ្ទុកដល់ ៣តោន | ២០០ ០០០រៀល |

[២៣] ដកស្រង់ចេញពីក្រសួងសេដ្ឋកិច្ច និង ហេរញ្ញវត្ថុ ស្តីពីការកំណត់ប្រាក់ពន្ធតាមប្រភេទសេវាកម្មរថយន្តដឹកជញ្ជូនឆ្នាំ ២០១៧

| | |
|---|---|
| ទម្ងន់ឡាន និង ទម្ងន់ផ្ទុកលើស ៣តោន ដល់ ១០តោន | ៥០០ ០០០រៀល |
| ទម្ងន់ឡាន និង ទម្ងន់ផ្ទុកលើស ១០តោន ដល់ ២០តោន | ១ ០០០ ០០០រៀល |
| ទម្ងន់ឡាន និង ទម្ងន់ផ្ទុកលើស ២០តោន | ២ ០០០ ០០០រៀល |

**គ. រឺម៉ុកសណ្តោង**

តារាងទី៣: បង្ហាញពីប្រភេទរឺម៉កសណ្តោងដែលត្រូវបង់ពន្ធក្នុង ឃុំជីពោទ៍ទី២

| **រឺម៉ុកសណ្តោង** | **កម្រិតប្រាក់ពន្ធសម្រាប់ ១ឆ្នាំ/គ្រឿង** |
|---|---|
| ទម្ងន់រឺម៉ក និង ទម្ងន់ផ្ទុកចាប់ពី ៣តោន ដល់ ១០តោន | ៥០០ ០០០រៀល |
| ទម្ងន់រឺម៉ក និង ទម្ងន់ផ្ទុកលើសពី ១០តោន ដល់ ២០តោន | ១ ០០០ ០០០រៀល |
| ទម្ងន់រឺម៉ក និង ទម្ងន់ផ្ទុកលើសពី ២០តោន | ២ ០០០ ០០០រៀល |

ក្នុងឃុំជីពោទ៍ទី២ មានការលក់ដូរជាលក្ខណៈគ្រួសារមានចំនួនច្រើន ។ ក្រៅពីការលក់ដូរជាលក្ខណៈគ្រួសារ ក្នុងនោះក៏មានជាងជួសជុលម៉ូតូ-ជាងអ៊ុតសក់ សិប្បកម្មឈើ-ដែក-សំណាង់ និងផ្សេងៗមួយចំនួនទៀត ដែលបំរើដល់សេដ្ឋកិច្ចគ្រួសារ។

ដូចនេះ វិស័យសេវាកម្ម បានជួយយ៉ាងច្រើនដល់ការអភិវឌ្ឍឃុំ ក្នុងនោះបានកាត់បន្ថយភាពក្រីក្រ លុបបំបាតភាពគ្មានការងារធ្វើ និង បានបង្កើតអោយមានចរន្តសេដ្ឋកិច្ចកើនឡើងនៅក្នុងឃុំជីពោទ៍ទី២។ ជាពិសេស មានការយកចិត្តទុកដាក់ខ្ពស់ពីក្រុមប្រឹក្សាឃុំ ដើម្បីជួយសម្រួលលើវិស័យសេវាកម្មឲ្យមានដំណើរការបានល្អ។

**៣.១.៥ វិស័យឧស្សាហកម្ម**[24]

នៅក្នុងឃុំជីពោទ៍ទី២ មានរោចក្រសំខាន់មួយគឺ រោងចក្រហ្គ្រីនហ្វីត (green feed) ដែលស្ថិតនៅក្នុងភូមិម្រាមទាក។ រោងចក្រនេះ បានផលិតចំណីសត្វ មាន់ ទា ជ្រូក ក្នុងរយៈមួយឆ្នាំមានចំនួន ១២០ពាន់តោន/ឆ្នាំ។ រោចក្រហ្គ្រីនហ្វីត (green feed)បានជួយប្រជាជននៅក្នុងឃុំជីពោទ៍ទី២ អោយមានការងារធ្វើចំនួន ១៥០នាក់ស្មើនឹង ១.០២%នៃប្រជាជនសរុបនៅក្នុងឃុំ។ ជាពិសេស រោងចក្រនេះត្រូវការវត្ថុធាតុដើមរបស់ប្រជាពលរដ្ឋក្នុងឃុំជីពោទ៍ទី២ និង ក្នុងស្រុកត្បូងឃ្មុំទាំងមូលគឺ ពោតក្រហម(ស្ងួត) ១៥,០០០ត កន្ទក់ ៣,៥០០ត ចុងអង្ករ ២,០០០ត ដំឡូងមីចំណិនស្ងួត ៤,០០០ត និង

[24] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងឆ្នាំ ២០១៦

កាកសណ្តែកសៀង ២០,០០០ត ក្នុងរយៈពេលមួយឆ្នាំ។ តម្រូវការវត្ថុធាតុដើមទាំងអស់នេះ បានធ្វើអោយប្រជាជននៅក្នុងឃុំជីពោទ៍ទី២ ជាពិសេស ភូមិស្រាមទាក បានបង្កើនការផលិតវត្ថុធាតុដើមដូចជា ពោតក្រហម ដំឡូងមី សណ្តែកសៀង ចុងអង្គុ និង កន្ទក់ ដែលអាចអោយប្រជាពលរដ្ឋរកចំណូលបានច្រើន និង មិនបានធ្វើចំណាក់ស្រុកទៅរកការងារនៅទីក្រុង និង ការងារនៅក្រៅប្រទេសឡើយ។

ដូចនេះ រោចក្រហ្វ៊ីនហ្វីត ( green feed) ដើរតួយ៉ាងសំខាន់ក្នុងវិស័យឧស្សាហកម្ម ក្នុងការជួយដល់ប្រជាពលរដ្ឋនៅក្នុងឃុំជីពោទ៍ទី២ អោយមានការងារធ្វើ និង បានលើកកម្ពស់កម្រិតជីវភាពនៃការរស់របស់ប្រជាពលរដ្ឋកាន់តែល្អប្រសើរឡើង។

**៣.១.៦ វិស័យសុខាភិបាល**

សេវាសុខាភិបាលរបស់ឃុំជីពោទ៍ទី២ បានយកចិត្តទុកដាក់ និង បានសម្រេចគោលដៅមួយចំនួនដូចជាកាចាក់វ៉ាក់សាំងដល់ស្រ្តី និងកុមារចំនួន ៩៣០នាក់ស្ថិតនៅទូទាំងឃុំ ផ្តល់សេវាសុខភាពស្ត្រីមានផ្ទៃពោះចំនួន ៤៧៥នាក់ស្ថិតនៅទូទាំងឃុំ បណ្តុះបណ្តាលសុខភាពអនាម័យចំនួន ២,៥៤០នាក់ស្ថិតនៅទូទាំងឃុំ ផ្សព្វផ្សាយពីសេវាសុខភាពនៅមណ្ឌលសុខភាព ៤៦០នាក់ ផ្តល់កម្មវិធីពន្យាកំណើតចំនួន ៤៧៥នាក់ស្ថិតនៅទទូទាំងឃុំ និងបង្គន់អនាម័យចំនួន ៤៦៦បង្គន់។ ការសម្រេចបាននៅសមិទ្ធិផលទាំងអស់នេះ បានជួយយ៉ាងច្រើនដល់ប្រជាពលរដ្ឋនៅក្នុងឃុំ ហើយបានឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋប្រហែលមានចំនួន ៨,២៧៨នាក់ស្មើនឹង ២៩,២% នៃប្រជាពលរដ្ឋសរុបនៅក្នុងឃុំ។

តែប្រជាជនមួយចំនួនតូច ក្នុងឃុំជីពោទ៍ទី២ មិនមានការយល់ដឹងពី ការសម្រាលកូនដោយឆ្មបបុរាណដែលបណ្តាលឲ្យមានគ្រោះថ្នាក់ ជាពិសេសការថៃទាំសុខភាព និងមិនទាន់យល់ច្បាស់ពីជំងឺឆ្លងផ្សេងៗ។ មួយវិញទៀតនៅក្នុងឃុំនេះ ប្រជាពលរដ្ឋមួយចំនួននូវមិនទាន់ទទួលបានទឹកស្អាតប្រើប្រាស់ឡើងយមានចំនួន ១,០៣៥គ្រួសារស្មើរនឹង ៤៣%នៃគ្រួសារសរុបនៅក្នុងឃុំ។

ដូចនេះ សម្ទទ្ធិផលដែលសម្រេចបានពីវិស័យសុខាភិបាលរបស់ឃុំជីពោទ៍ទី២ គឺមានកម្រិតល្អមធ្យម ក្នុងចន្លោះឆ្នាំ ២០១៤ ដល់ ២០១៧ ដោយបានបំពេញនៅតម្រូវការ និងបានឆ្លើយតបទៅនឹងការចង់បានរបស់ប្រជាពលរដ្ឋនៅទូទាំងឃុំ។ ទោះបីយ៉ាងនេះក្តី ក្នុងឃុំនេះក៏នៅតែមានបញ្ហាមួយចំនួនដែលមិនទាន់បានដោះស្រាយរួចផងដែរ។

**៣.១.៧ វិស័យអប់រំ**

សមទ្ធផលដែលសម្រេចបាន ចំពោះវិស័យអប់រំក្នុងចន្លោះឆ្នាំ២០១៤-២០១៧ របស់ឃុំជីពោទ៍ទី២ មានដូចជា បង្កើតសាលារៀន ៣បន្ទប់ សម្រាប់សិស្ស ១៨០នាក់ នៅភូមិទួលវិហារ ផ្តល់អាហា

រូបករណ៍ដល់សិស្សក្រីក្រចំនួន ៣០នាក់ នៅភូមិបឹងត្រស់ ផ្សព្វផ្សាយ និងជំរុញឲ្យឪពុកម្តាយឲ្យនាំកូនចុះឈ្មោះចូលរៀនចំនួន ១១៨នាក់ នៅទូទាំងឃុំ ។ សមទ្ធផលដែលបានសម្រេចបានក្នុងរយៈពេល៤ឆ្នាំ គឺមិនទាន់ឆ្លើយតបទៅការចង់បានរបស់ប្រជាពលរដ្ឋឡើយ ដោយឃុំមិនទាន់បានអនុវត្តលើគម្រោងក្នុងឆ្នាំ២០១៥ និង ២០១៦ឡើយ គម្រោងនោះមាន ការជួសជុលអគារសាលាបឋមសិក្សាអង្គនារាម ផ្តល់គ្រឿងសង្ហារឹមតាមសាលាអនុវិទ្យាល័យទួលវិហារ ចាក់ដីទីធ្លាសាលាបឋមសិក្សាអង្គនារាម។ គម្រោងដែលមិនទាន់បានអនុវត្តក្នុងឆ្នាំ ២០១៥ និង ២០១៦ គឺអាចប៉ះពាលដល់សិស្សចំនួន ១០,៥៤នាក់។ យោងតាមការអង្កេត ទៅលើលើសកម្មភាពអនុវត្តចន្លោះឆ្នាំ ២០១៤ ដល់ ២០១៧ របស់ឃុំជីរោទ៍ទី២ បានបង្ហាញឲ្យឃើញថា មិនមានសម្ទទ្ធិផលធំណាមួយឡើយចំពោះវិស័យអប់រំ។

ដូចឆ្នេះ វិស័យអប់រំរបស់ឃុំជីរោទ៍ទី២ នៅចន្លោះឆ្នាំ ២០១៤ ដល់ ២០១៧ មិនទាន់មានការរីកចម្រើនច្រើនឡើយ។ ដោយមិនបានឆ្លើយតបទៅនឹងគម្រោងដែលបានរៀបចំទុក និងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋនៅក្នុងឃុំ។

### ៣.១.៨ វិស័យគមនាគមន៍

**ក្រាហ្វិកទី៤:ក្រាបបង្ហាពីការអនុវត្តគម្រោង ក្នុងការជួសជុល និង បង្កើតផ្លូវក្រាលគ្រួក្រហម ឯកតា(គិតជាម៉ែត្រ)**




(ដកស្រង់ចេញពីឃុំជីរោទ៍ទី២)

ឃុំជីពោទ៍ទី២ ទទួលបានជោគជ័យ ក្នុងការអនុវត្តគម្រោងដែលបានរៀបចំទុក ក្នុងចន្លោះឆ្នាំ ២០១៤-២០១៧។ គម្រោង និងសកម្មភាពបានអនុវត្តគឺស្មើរគ្នា ក្នុងឆ្នាំ២០១៤ បានជួសជុលផ្លូវក្រាលគ្រួសក្រហមមានប្រវែង ១,៥៩១ម ឆ្នាំ២០១៥ បានបង្កើតផ្លូវក្រាលគ្រួសក្រហម មានប្រវែង ២,០១៨ម ឆ្នាំ២០១៦ បានបង្កើតផ្លូវមានប្រវែង ២,៧៤៩ម ឆ្នាំ២០១៧ បង្កើតផ្លូវក្រាលគ្រួសក្រហម មានប្រវែង ៣,០០០ម (តាមក្រាហ្វិកទី៣)។ ជាពិសេស ការជួសជុល និង បង្កើតផ្លូវថ្មី ទទួលបានសម្ទិផលលើសពីការគ្រោងទុក។ ការសម្រេចបានសម្ទិផលដ៏ជោគជ័យនេះ បានជួយយ៉ាងច្រើនដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងឃុំ ម្យ៉ាងវិញទៀតការសម្រេចបាននៅសម្ទិផលនេះជួយយ៉ាងច្រើនដល់សេដ្ឋកិច្ចរបស់ឃុំជីពោទ៍ទី២ផងដែរ។

ដូចនេះ ផ្នែកគមនាគមន៍របស់ឃុំជីពោទ៍ទី២ ទទួលបានសម្ទិផលយ៉ាងខ្ពស់។ សម្ទិផលទាំងអស់នេះ គឺជាកាខិតខំប្រឹងប្រែងរបស់ក្រុមប្រឹក្សាឃុំ ដើម្បីឆ្លើយតបទៅនឹងការចង់បានរបស់ប្រជាពលរដ្ឋនៅក្នុងឃុំ។ ជាក់ស្តែងយើងពិនិត្យឃើញថា តាំងពីឆ្នាំ ២០១៤ រហូតដល់ ២០១៧ បានអនុវត្តគម្រោងជួសជុល និង បង្កើតផ្លូវក្រាលគ្រួសក្រហម គឺអនុវត្តបានសម្រេច ១០០% ទៅតាមការគ្រោងទុក ដែលអាចចាត់ទុកថា រដ្ឋបាលឃុំមានសម្ថភាពចាត់ចែងលើកិច្ចការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវបានល្អប្រសើរ។

### ៣.១.៩ វិស័យសង្គមកិច្ច

នៅក្នុងឃុំជីពោទ៍ទី២ មានការយកចិត្តទុដាក់ខ្ពស់ ដល់ជនក្រីក្រគ្មានទីពឹង បានសាងសង់ផ្ទះជូនជនក្រីក្រ បណ្តុះបណ្តាលជំនាញវិជ្ជាជិវៈដល់ជនពិការ និងសកម្មភាពសំខាន់ផ្សេងៗទៀត ដើម្បីឲ្យពួកគេមានជីវភាពរស់នៅល្អប្រសើរ ដូចអ្នកធម្មតាដែរ។ ឃុំនេះទទួលបានសម្រេចក្នុងការអនុវត្តគម្រោងក្នុងការជួយជនក្រីក្រគ្មានទីពឹង ១៣៥នាក់ សង់ផ្ទះជូនអ្នកក្រីក្រ ១៥ផ្ទះ នឹង បណ្តុះជំនាញដល់ជនពិការ ១២នាក់ ។

ដូចនេះ នៅក្នុងឃុំជីពោទ៍ទី២ ចន្លោះឆ្នាំ២០១៤-២០១៧ មានការរីកចំរើនច្រើន ចំពោះផ្នែកសង្គមកិច្ច។ ការរីកចំរើននេះ ឆ្លើយតបទៅនឹងការចង់បានរបស់ ជនក្រីក្រគ្មានទីពឹង និងជនពិការក្នុងគោលបំណង ជួយឲ្យការរស់នៅរបស់ពួកគេល្អប្រសើរជាងនេះ។

### ៣.១.១០ រដ្ឋបាលសន្តិសុខ

ការទប់ស្កាត់ និង ការបញ្ឈប់ សកម្មភាពល្បែងស៊ីសងមាន ១២២នាក់ បង្រ្កាប់ក្មេងទំនើង ២៨នាក់ ផ្សព្វផ្សាយច្បាប់ព្រហ្មទណ្ឌមាន ១៩២នាក់ ផ្សព្វផ្សាយច្បាប់ចារាចរណ៍ជើងគោកមាន ១៨៧នាក់ ផ្សព្វផ្សាយច្បាប់ប្រឆាំងអំពើរហិង្សាក្នុងគ្រួសារមាន ១២៧នាក់ ផ្សព្វផ្សាយច្បាប់ប្រឆាំង

ការជួញដូរស្ត្រី និងកុមារមានចំនួន ២៣០នាក់។ ដោយសម្ទទិ្ធផលទាំងអស់នេះហើយដែលធ្វើឲ្យប្រជាពលរដ្ឋរស់នៅក្នុងឃុំជីពោទ៍ទី២ រស់នៅដោយសុខសាន្ត មិនមានភាពភ័យខ្លាចផ្សេងៗ។ មួយវិញទៀត ក្រុមប្រឹក្សាឃុំ នគបាល និងដៃគូរដែលពាក់ព័ន្ធ បានធ្វើការផ្សព្វផ្សាយស្ដីអំពីច្បាប់នានាក្នុងគោលបំណងឲ្យឃុំមានសន្តិសុខល្អ ហើយច្បាប់ដែលបានផ្សព្វផ្សាយនោះ មានដូចជា ច្បាប់ចរាចរណ៍ជើងគោក ច្បាប់ព្រហ្មទណ្ឌ ច្បាប់ប្រឆាំងអំពើហឹង្សាក្នុងគ្រួសារ ច្បាប់ចំណាក់ស្រុកមានសុវត្ថិភាព ច្បាប់ប្រឆាំងការជួញដូរស្ត្រី និង កុមារ ។

ដូចនេះ រដ្ឋបាលសន្តិសុខ របស់ឃុំជីពោទ៍ទី២ មានការរីកចំរើន និង ប្រសិទ្ធិភាពខ្ពស់ ក្នុងការរក្សានូវសន្តិសុខជូនប្រជាពលរដ្ឋ ដោយមិនឲ្យមានគ្រោះហានិភ័យផ្សេងៗ។

#### ៣.១.១១ ការលើកកម្ពស់សមាសភាពសមធម៌យេនឌ័រ និងការជួយជនរងគ្រោះ

ក្នុងឃុំជីពោទ៍ទី២ ទទួលបានជោគជ័យ ក្នុងការអនុវត្តគម្រោងចន្លោះឆ្នាំ ២០១៤-២០១៧ ក្នុងការការលើកកម្ពស់ សមាសភាពសមធមិយេនឌ័រ ជាពិសេស គ.ន.ក បានចូលរួមយ៉ាងច្រើនក្នុងការយកចិត្តទុកដាក់ដល់ស្ត្រី និង កុមារ។ ទន្ទឹមនឹងនេះ ដោយមានការយកចិត្តទុកដាក់ ពីក្រុមប្រឹក្សាឃុំ និង នគបាលសន្តិសុខឃុំ តែងតែបង្ក្រាប់រាល់អំពើហិង្សាលើស្ត្រី ដើម្បីធ្វើយ៉ាងណាឲ្យស្ត្រីមានសិទ្ធិពេញលេញក្នុងការរស់នៅ។

ដូចនេះ សម្ទទិ្ធផលចន្លោះឆ្នាំ ២០១៤-២០១៧ ទទួលបានលទ្ធផលល្អចំពោះ ផ្នែកសមធមិយេនឌ័រ និងការជួយជនរងគ្រោះ។ សម្ទទិ្ធផលទាំងនេះ មានសារៈសំខាន់ណាស់ក្នុងការលើកកម្ពស់តម្លៃរបស់ស្ត្រី។

## ៣.២ បញ្ហាប្រឈម និង ដំណោះស្រាយ

### ៣.២.១ បញ្ហាហេដ្ឋារចនាសម្ព័ន្ធ

ក្នុងឃុំជីពោទ៍ទី២ មានបញ្ហាតិចតួចដែលកើតមានលើផ្នែកហេដ្ឋារចនាសម្ព័ន្ធ បញ្ហានោះគឺផ្លូវពិបាកធ្វើដំណើរ ដោយសារតែ ផ្លូវចាស់ទ្រុឌទ្រោម ទឹកហូរកាត់ផ្លូវ ទំនុបទឹកដាច់ និង ទ្វារទឹកដាច់។ បញ្ហានេះបានធ្វើឲ្យប៉ះពាល់ដល់ប្រជាពលរដ្ឋចំនួន ១០ភូមិ។

ដំណោះស្រាយចំពោះបញ្ហានេះ ឃុំបានធ្វើកាយកចិត្តទុកដាក់ ក្នុងការជួសជុលផ្លូវដែលពិបាកធ្វើដំណើរ ហើយបានសាងសង់លូកាត់ផ្លូវ ដើម្បីកុំឲ្យមានបញ្ហានេះកើតឡើងទៀត។

ដើម្បីដោះស្រាយអំពីបញ្ហានេះ ឃុំគួរតែផ្លាស់ប្តូរទំនប់ទឹកថ្មី កសាងលូកាត់ផ្លូវឲ្យបានច្រើនដែលអាចធ្វើទៅបាន ដើម្បីការពារទឹកកុំឲ្យហូរកាត់ផ្លូវ និង មិនឲ្យមានរយន្តទាំងឡាយណាដែលលើសទម្ងន់ឆ្លងកាត់ផ្លូវនោះឡើយ។ ជាពិសេស ត្រូវសហាការជាមួយរាជរដ្ឋាភិបាល និងអង្គការ

ក្រៅរដ្ឋាភិបាល ដើម្បីទទួលបានជំនួយ ក្នុងការជួសជុលផ្លូវ។

**៣.២.២ បញ្ហាទិន្នផលកសិកម្ម**

**ក. ស្រូវ**

ទិន្នផលស្រូវក្នុងឃុំជីពោទី២ មានការធ្លាក់ចុះ ដោយសារតែ ប្រជាពលរដ្ឋភាគច្រើនធ្វើស្រែតាមទំលាប់ ខ្វះបច្ចេកទេស និង ខ្វះជីរជាតិ។ បញ្ហានេះ ធ្វើឲ្យប៉ះពាល់ដល់ប្រជាពលរដ្ឋទូទាំងឃុំ។

ដំណោះស្រាយចំពោះបញ្ហានេះ ឃុំបានធ្វើការដោះស្រាយគឺ ស្តារប្រឡាយស្រោចស្រពជួសជុលទំនប់ទឹក សាងសង់ទ្វាទឹក វគ្គបណ្តុះបណ្តាលបច្ចេកទេសការដាំដំណាំស្រូវ វគ្គបច្ចេកទេសប្រព័ន្ធកសិកម្មចម្រុះ វគ្គបច្ចេកទេសជីកំប៉ុស្តិ៍ វគ្គបច្ចេកទេសកែប្រែគុណភាពដី។

ដើម្បីដោះស្រាយអំពីបញ្ហាទិន្នផលស្រូវធ្លាក់ចុះគឺ ប្រជាពលរដ្ឋត្រូវប្រើគ្រាប់ពូជស្រូវដែលមានគុណភាពខ្ពស់ មានចំណេះដឹងគ្រប់គ្រាន់ក្នុងការធ្វើកសិកម្ម យកចិត្តទុកដាក់ថែទាំឲ្យបានល្អចំពោះដំណាំស្រូវ និង ត្រូវប្តូរការធ្វើស្រែតាមទំលាប់ ទៅជាការធ្វើស្រែបែបទំនើបកម្ម។

**ខ.សត្វ**

ទិន្នផលសត្វនៅក្នុងឃុំជីពោទ៍ទី២ មានការថយចុះ ដោយសារតែ ខ្វះបច្ចេកទេសចិញ្ចឹមជ្រូក ខ្វះបច្ចេកទេសចិញ្ចឹមមាន់ ទា ខ្វះបច្ចេកទេសចិញ្ចឹមគោ ក្របី ខ្វះពូជគោ ក្របី ខ្វះបច្ចេកទេសចិញ្ចឹមត្រី ខ្វះពូជត្រី ជាពិសេស ប្រើឧបករណ៍នេសាទខុសច្បាប់។ បញ្ហានេះ បានកើតមានទូទាំងឃុំ។

ដើម្បីដោះស្រាយអំពីបញ្ហានេះ ឃុំបានធ្វើការដោះស្រាយគឺ ធ្វើការបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វ វគ្គបច្ចេកទេសចិញ្ចឹមជ្រូក វគ្គបច្ចេកទេសចិញ្ចឹមមាន់-ទា វគ្គបច្ចេកទេសផលិតចំណីសត្វ វគ្គបច្ចេកទេសចិញ្ចឹមគោ-ក្របី ផ្តល់ពូជគោ-ក្របី ផ្តល់ពូជជ្រូក ផ្តល់ពូជមាន់-ទា អប់រំអំពីច្បាប់ជលផល ទប់ស្កាត់បទល្មើសនេសាទ ពង្រឹងវិធានការការពារព្រៃលិចទឹក បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រូវ។

ដំណោះស្រាយបន្ថែមពីបញ្ហានេះ គួរចាក់វ៉ាក់សាំងការពារជម្ងឺសត្វ វគ្គបណ្តុះបណ្តាល និងពង្រឹងភ្នាក់ងារសុខភាពសត្វភូមិ ត្រូវមានការសហការគ្នា រវាង ក្រុមប្រឹក្សាឃុំ នគបាល និងប្រជាពលរដ្ឋដែលស្ថិតនៅក្នុងឃុំ ដើម្បីទប់ស្កាត់រាល់បទល្មើសនេសាទផ្សេងៗដែលបានកើតឡើង។

**៣.២.៣ បញ្ហាសុខាភិបាល**

ប្រជាពលរដ្ឋមួយចំនួន នៅក្នុងឃុំជីពោទ៍ទី២ មានផ្ទុកជម្ងឺ បញ្ហានេះកើតឡើងដោយសារតែខ្វះការយល់ដឹងពីការការពារ និងការថែទាំសុខភាព ជាពិសេសសកម្មភាពប្រចាំថ្ងៃ មានដូចជា ការហូបស្អាត់ ផឹកស្អាត់ និង រស់នៅស្អាត់។ បញ្ហានេះកើតឡើងទូទាំងឃុំ។

ដំណោះស្រាយចំពោះបញ្ហានេះ ឃុំបាន បណ្តុះបណ្តាលវគ្គអប់រំចំណេះដឹងអំពីជម្ងឺអេដស៍

ជួយគាំទ្រអ្នកផ្ទុកមេរោគអេដស៍ អប់រំពីចំណោះពីជម្ងឺគ្រុនឈាម ផ្តល់មុង និងទឹកជ្រលក់មុង ដើម្បីការពារពីជម្ងឺគ្រុនចាញ់ ផ្តល់ការព្យាបាលជម្ងឺគ្រុនចាញ់ ផ្សព្វផ្សាយពីគ្រោះថ្នាក់នៃជម្ងឺគ្រុនផ្តាសសាយបក្សី។

ដើម្បីដោះស្រាយអំពីបញ្ហានេះ ក្រុមប្រឹក្សាឃុំ គួរបង្កើនការផ្សព្វផ្សាយបន្ថែមទៀត ពីសារៈប្រយោជន៍នៃការ ហូបស្អាត់ ផឹកស្អាត់ និងរស់នៅឲ្យបានច្រើនដែលអាចធ្វើទៅបាន ជាពិសេស ត្រូវផ្តល់ប្រព័ន្ធទឹកស្អាត់ ដល់ប្រជាពលរដ្ឋគ្រប់គ្នា។

**៣.២.៤ បញ្ហាការអប់រំ**

មានកុមារមួយចំនួនមិនបានចូលរៀននៅក្នុងឃុំជីរោទ៍ទី២ បញ្ហានេះកើតឡើងដោយសារតែឪពុកម្តាយខ្វះការយល់ដឹងពីសារៈប្រយោជន៍នៃការសិក្សា ក្មេងគេចសាលា គ្រួសារក្រីក្រ សាលាភក់ជ្រាំ។ បញ្ហានេះ បានកើតឡើងទូទាំងឃុំ។

ដំណោះស្រាយចំពោះបញ្ហានេះ ឃុំបានធ្វើការជួសជុល និងបង្កើតអគារសាលាបឋមសិក្សា ផ្សព្វផ្សាយ និងជំរុញឲ្យឪពុកម្តាយនាំកូនមកចុះឈ្មោះចូលរៀន ឧបត្ថម្ភកុមារក្រីក្រអោយបានចូលរៀន ចាក់ដីនៅទីធ្លាសាលាបឋមសិក្សា ផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ ផ្តល់គ្រឿងសង្ហារឹមដល់សាលាអនុវិទ្យាល័យ។

ដំណោះស្រាយបន្ថែម ឃុំគួរតែស្នើរដល់ភាគគីដែលពាក់ព័ន្ធ មានដូចជា រាជរដ្ឋាភិបាល និង អង្គការផ្សេងៗ ដើម្បីបង្កើតអគាថ្មីៗ ហើយគ្រូបង្រៀនត្រូវធ្វើការតាមដានការសិក្សាក្មេងៗឲ្យបានទៀងទាត់ ដើម្បីជៀសវៀងការគេចសាលា ជាពិសេស ឃុំត្រូវគាំទ្រ និង យកចិត្តទុកដាក់ឲ្យបានខ្ពស់ដល់សិស្សក្រីក្រ ដែលមិនមានលទ្ធភាពមករៀន។

**៣.២.៥ បញ្ហារដ្ឋបាល**

នៅក្នុងឃុំ មានប្រជាពលរដ្ឋមិនមកចុះអត្រានុកូលដ្ឋានគ្រប់គ្នាឡើយ។ បញ្ហានេះកើតឡើងដោយសារ ប្រជាពលរដ្ឋមិនយល់ដឹងពីផលប្រយោជន៍សំបុត្រអត្រានុកូលដ្ឋាន។ បញ្ហានេះ បានកើតឡើងនៅទូទាំងឃុំ របស់ឃុំជីរោទ៍ទី២។

ដំណោះស្រាយចំពោះបញ្ហានេះ ឃុំបានធ្វើការដោះស្រាយគឺ ជំរុញពង្រឹងកិច្ចការចុះបញ្ជីអត្រានុកូលដ្ឋាន និងផ្តល់សេវាចុះបញ្ជីអត្រានុកូលដ្ឋានតាមភូមិ ក្នុងគោលបំណង ឲ្យអ្នកមិនទាន់មានបញ្ជីអត្រានុកូលដ្ឋាន ត្រូវមកចុះបញ្ជីអត្រានុកូលដ្ឋានឲ្យបានគ្រប់ៗគ្នា។

ដើម្បីដោះស្រាយអំពីបញ្ហាដែលប្រជាពលរដ្ឋមិនមកចុះបញ្ជីអត្រានុកូលដ្ឋាន ឃុំត្រូវធ្វើការផ្សព្វផ្សាយនៅទូទាំងភូមិ ជាពិសេស ត្រូវឲ្យមេភូមិ ឫសមាជិកភូមិដែលខ្លួនកំពុងកាន់កាប់ ត្រូវធ្វើការទទួលខុសត្រូវក្នុងការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋរបស់ខ្លួន។

### ៣.២.៦ បញ្ហារដ្ឋបាលសន្តិសុខ

ក្នុងឃុំជីពោទ៍ទី២ មានអសន្តិសុខ និង អំពើរហិង្សា បានកើតឡើង បញ្ហាទាំងនេះកើតឡើង ដោយសារតែ មានចោរលួច-ឆក់ ចែកចាយ និងប្រើប្រាស់គ្រឿងញៀន ការប្រច័ណ្ឌគ្នា និងមិនចេះយោគយល់គ្នា។ បញ្ហាទាំងអស់នេះ បានកើតមាននៅទូទាំងឃុំ។

ដំណោះស្រាយចំពោះបញ្ហានេះ ឃុំបានពង្រឹងសកម្មភាពក្រុមប្រជាការពារ វិធានការទប់ស្កាត់ការជួញដូរប្រើប្រាស់គ្រឿងញៀន ផ្សព្វផ្សាយច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារ ផ្សព្វផ្សាយច្បាប់ក្រមរដ្ឋប្បវេណី និងព្រហ្មទណ្ឌ ផ្សព្វផ្សាយច្បាប់ចរាចរ និងសណ្ដាប់ធ្នាប់សាធារណៈដល់ប្រជាពលរដ្ឋ ប្រមូលជនពាលដើម្បីធ្វើការអប់រំ ផ្សព្វផ្សាយច្បាប់ប្រឆាំងការជួញដូរស្ត្រី និងកុមារ ដាក់ផ្លាកសញ្ញាចរាចរ ជំរុញកម្មភាពបង្រ្កាប់ល្បែងស៊ីសង បង្កើនការបង្រ្កាប់បទល្មើសនានា អប់រំឲ្យដឹងពីការប្រើប្រាស់គ្រឿងញៀន អប់រំប្រជាពលរដ្ឋយល់ដឹងពីការប្រើប្រាស់អាវុទជាតិផ្ទុះ អប់រំពីសិទ្ធិតួនាទី បុរស និងស្ត្រី។

ដំណោះស្រាយបន្ថែម ដើម្បីដោះស្រាយលើបញ្ហាទាំងអស់នេះឲ្យកាន់មានប្រសិទ្ធិភាព ឃុំត្រូវមានការចូលរួមពីប្រជាពលរដ្ឋឲ្យបានច្រើន ជាពិសេស ជាមួយមន្ត្រីថ្នាក់ស្រុក និងមន្ត្រីថ្នាក់ខេត្ត ដើម្បីអោយជួយសម្រួលក្នុងផ្សព្វផ្សាយពីច្បាប់នានា ក្នុងគោលបំណង លុបបំបាត់ទាំងស្រុងចំពោះបញ្ហារដ្ឋបាលសន្តិសុខ។

### ៣.២.៧ បញ្ហាទំនាស់ដីធ្លី

នៅក្នុងឃុំជីពោទ៍ទី២ មានបញ្ហាទំនាស់ដីធ្លីកើតឡើង បញ្ហានេះកើតឡើងដោយសារ មានការរំលោភបំពានដីធ្លី ព្រំប្រទល់មិនច្បាស់លាស់ និង ប្រជាពលរដ្ឋមិនយល់ពីច្បាប់ភូមិបាល។

ឃុំបានធ្វើការដោះស្រាយបញ្ហាទាំងនេះ ដោយធ្វើការអប់រំ និងផ្សព្វផ្សាយពីច្បាប់ភូមិបាល ផ្ដល់ប័ណ្ណកម្មសិទ្ធិដីធ្លី ផ្សព្វផ្សាយ និងជម្រុញការងារចុះបញ្ជីបញ្ជីដីធ្លី រៀបចំផែនការកំណត់តំបន់ប្រើប្រាស់ដីធ្លី កំណត់តំបន់ប្រើប្រាស់ដីព្រៃសមស្រប។

ដើម្បីដោះស្រាយអំពីបញ្ហាទំនាស់ដីធ្លី ឲ្យមានប្រសិទ្ធិភាព គឺមន្ត្រីដែលចូលមកដោះស្រាយទំនាស់ដីធ្លី ត្រូវមានសម្ថភាពគ្រប់គ្រាន់ស្ដីពីច្បាប់ភូមិបាល និងត្រូវមានទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ ដើម្បីសម្រួលដល់ការចុះបញ្ជីដីធ្លី។

### ៣.២.៨ បញ្ហាចំណាកស្រុក

នៅក្នុងឃុំជីពោទ៍ទី២ មានបញ្ហាចំណាកស្រុក ដោយសារតែ ប្រជាពលរដ្ឋមួយចំនួន រស់នៅក្នុងភាពក្រីក្រ មិនមានការងារធ្វើ។ បញ្ហានេះបានកើតមាននៅទូទាំងឃុំ។

ឃុំបានធ្វើការដោះស្រាយលើបញ្ហានេះ ដោយផ្សព្វផ្សាយ ពីចំណាកស្រុកមានសុវត្ថិភាព

និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ដើម្បីអាចបំពេញការងារនៅឃុំខ្លួនឯងបាន។

ដំណោះស្រាយបន្ថែម សូមឲ្យក្រុមប្រឹក្សាឃុំ ធ្វើការទំនាក់ទំនង ជាមួយនិយោជក ថៅកែ និងស្ថាប័នផ្សេងៗ ដើម្បីបង្កើតការងារជូនប្រជាពលរដ្ឋនៅក្នុងឃុំ គោលបំណង ដើម្បីជៀសវាងពីការធ្វើចំណាកស្រុកខុសច្បាប់។

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាផ្នែកទ្រឹស្តី ការសិក្សាស្វែងអំពីគោលនយោបាយក្នុងការអភិវឌ្ឍ និងការសិក្សាស្រាវជ្រាវលើស្ថានភាពការរស់នៅដោយផ្ទាល់របស់ប្រជាពលរដ្ឋ បានបង្ហាញឲ្យឃើញថា ការអភិវឌ្ឍរបស់ឃុំ សង្កាត់ ពិតជាមានសារៈសំខាន់យ៉ាងខ្លាំង ក្នុងការបង្ហាញពីសុខមាលភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់។ រដ្ឋាភិបាលមានការយកចិត្តទុកដាក់យ៉ាងខ្ពស់ និងយ៉ាងម៉តចត់ទៅលើការអភិវឌ្ឍរបស់ឃុំ ដោយបានបង្កើតគោលនយោបាយ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងគោលនយោបាយក្នុងការអភិវឌ្ឍឃុំ សង្កាត់(២០១៧-២០២២) ក្នុងគោលបំណងដើម្បីឲ្យប្រជាពលរដ្ឋរស់នៅប្រកបដោយ សុខសាន្ត សម្បូរសប្បាយ មិនមានធ្វើការចំណាក់ស្រុក ការឆក់ប្លន់ ការអត់ឃ្លាន និងមិនមានគ្រោះភ័យខ្លាចផ្សេងៗ។ ការអភិវឌ្ឍឃុំ សង្កាត់ ដោយប្រសិទ្ធិភាព ទាមទារផ្នែកជាច្រើន មានដូចជា ផ្នែកសេដ្ឋកិច្ច ផ្នែកហេដ្ឋារចនាសម្ព័ន ការអប់រំ វិស័យសុខាភិបាល ការគ្រប់គ្រងធនធានធម្មជាតិ ការថែរក្សាបរិស្ថាន និងចំនុចតូចផ្សេងៗទៀត។ ការអភិវឌ្ឍឃុំ សង្កាត់ ទាមទារការចូលរួមទាំងរដ្ឋាភិបាល និងប្រជាពលរដ្ឋដែលរស់នៅក្នុងឃុំ សង្កាត់នោះ។ នៅពេលដែលឃុំ សង្កាត់ មានការរីកចំរើនខ្លាំង នោះជម្រុញឲ្យប្រទេសកម្ពុជាក្លាយជាប្រទេសមានការរីកចំរើនយ៉ាងខ្លាំង។

ចំនែកឯនៅក្នុងឃុំជីពោទ៍ទី២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ យើងសង្កេតឃើញថា មានសកម្មភាពរបស់ក្រុមប្រឹក្សាឃុំជីពោទ៍ទី២ ក្នុងការចូលរួម ធ្វើឲ្យជីវភាពរស់នៅ របស់ប្រជាពលរដ្ឋនៅក្នុងឃុំទាំងមូល ហាក់ដូចមានលក្ខណៈធូរធារជាងមុន ពោលគឺដោយសារតែ ក្រោមការខិតខំប្រឹងប្រែងអភិវឌ្ឍន៍របស់ឃុំ ស្ទើគ្រប់វិស័យទាំង ផ្នែកសេដ្ឋកិច្ច និងផ្នែកសង្គមកិច្ច......។ ទន្ទឹមនិងការរីកចំរើនយ៉ាងច្រើននេះ ក៏មានចំនុចខ្វះខាត់តិចតួចផងដែរ ដែលមិនទាន់បានដោះស្រាយបានជោគជ័យនៅឡើយ គឺការធ្វើកសិកម្មភាគច្រើនតាមទម្លាប់(តាមប្រពៃណី) ប្រើប្រាស់ជីគីមីមានចំនួនច្រើន ខ្វះការយល់ដឹងពីការប្រើប្រាស់សេវាមណ្ឌលសុខភាពនៅក្នុងឃុំ និង នៅតែមានកុមារមិនបានចូលរៀនផងដែរ។

សមិទ្ធិផលល្អៗយ៉ាងច្រើនទាំងអស់នេះគឺ កើតចេញពីការខិតខំប្រឹងប្រែងរបស់ប្រជាពលរដ្ឋទាំងអស់គ្នា ជាពិសេសគឺ ក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាឃុំជីពោទ៍ទី២ បានរៀបចំជាផែនការអភិវឌ្ឍន៍ឃុំ(ឆ្នាំ២០១២-២០១៦) កម្មវិធីវិនិយោគរបស់ឃុំ សង្កាត់(ឆ្នាំ២០១៤-២០១៧) ឯកសារអនុវត្តគម្រោងក្នុង(ឆ្នាំ២០១៤,២០១៧) និងបានរៀបចំផែនកាទិសដៅរអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ(ឆ្នាំ

២០១៧-២០២២)។

សរុបមកការអភិវឌ្ឍឃុំជីពាទ៍ទី២ គឺមានការរីកចំរើនច្រើន ដែលស្របតាមការចង់បានរបស់ប្រជាពលរដ្ឋនៅក្នុងឃុំ ដើម្បីរួចផុតពីភាពក្រីក្រ ហើយស្របតាមយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ និងគោលនយោបាយរបស់រដ្ឋាភិបាល ក្នុងការអភិវឌ្ឍឃុំ សង្កាត់។

## ២. ការផ្តល់អនុសាសន៍

បន្ទាប់ពីបានសិក្សាស្វែងយល់ អំពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ឃុំជីពោទ៍ទី២ ក្រុមយើងយល់ឃើញថា ការងារអភិវឌ្ឍន៍មូលដ្ឋាន ជាគោលនយោបាយចំបងសំរាប់រាជរដ្ឋាភិបាលកម្ពុជា ដែលត្រូវធ្វើការយកចិត្តទុកដាក់។ យើងខ្ញុំ សូមចូលរួមផ្តល់ជាអនុសាសន៍មួយចំនួនក្នុងការអភិវឌ្ឍឃុំ សង្កាត់ ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ នៅក្នុងឃុំជីពោទ៍ទី២ ដូចខាងក្រោម:

- បញ្ហាប្រព័ន្ធធារាសាស្ត្រ និងបញ្ហាបច្ចេកទេសកសិកម្ម: សូមឲ្យរាជរដ្ឋាភិបាល ជួយដោះស្រាយមុនគេ ព្រោះយោងតាមជំពូកទី២ បានបង្ហាញថាប្រព័ន្ធធារាសាស្ត្រមានចំនួនតិច និងកសិករភាគច្រើនធ្វើកសិកម្ម ដោយគ្មានបច្ចេកទេស។ ដូចនេះរាជរដ្ឋាភិបាល គួរបង្កើតប្រព័ន្ធធារាសាស្ត្របន្ថែម និងធ្វើការបណ្តុះបណ្តាលបច្ចេកទេសក្នុងការធ្វើកសិកម្ម។

- បញ្ហាកង្វះការយល់ដឹងពីសេវាសុខាភិបាលរដ្ឋ: ប្រជាពលភាគច្រើន និយមប្រើវិធីសាស្ត្រសម្រាលកូនដោយឆ្មបបុរាណដោយគ្មានវិជ្ជាជីវៈច្បាស់លាស់ ដែលធ្វើអោយពួកគេប្រឈមមុខទៅនឹងហានិភ័យផ្សេងៗ(មរណៈភាពកុមារ ឫម្តាយ)។ ដូចនេះសូមឲ្យរាជរដ្ឋាភិបាល បង្កើនការផ្សព្វផ្សាយពីគុណវិបត្តិនៃការសម្រាលកូនដោយឆ្មប់បុរាណ និងគួរតែព្យាយាមលុបបំបាត់ឆ្មបទាំងឡាយណា ដែលគ្មានវិជ្ជាជីវៈច្បាស់លាស់។

- បញ្ហាវិស័យអប់រំ: ប្រធានក្រុមប្រឹក្សាឃុំ និងសមាជិកដែលពាក់ព័ន្ធ គួរបង្កើនការផ្សព្វផ្សាយ និងលើកទឹកចិត្តដល់ក្មេងៗ ដែលបោះបង់ការសិក្សា និងមិនទាន់បានចូលរៀន ឲ្យចុះឈ្មោះចូលរៀនគ្រប់ៗគ្នា។

- ក្រុមប្រឹក្សាឃុំត្រូវរៀបចំអោយមានផែនការ សំរាប់អភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួនអោយបានច្បាស់លាស់។

- ក្រុមប្រឹក្សាឃុំត្រូវធ្វើការផ្សព្វផ្សាយតាមភូមិនីមួយៗ ស្តីពីសារៈប្រយោជន៍នៃរបរផ្នែកសិប្បកម្ម និងសេវាកម្ម ដើម្បីលើកកម្ពស់សេដ្ឋកិច្ចគ្រួសាររបស់ប្រជាពលរដ្ឋឲ្យល្អប្រសើរជាងនេះ។

- ក្រុមប្រឹក្សាឃុំត្រូវធ្វើការទំនាក់ទំនងជាមួយក្រុមហ៊ុន ហ្គ្រីនហ្វីត(green feed) ដើម្បីធ្វើការបណ្តុះបណ្តាល់ជំនាញការផលិតចំណីសត្វ ដល់កម្មកររោងចក្រនៅក្នុងក្រុមហ៊ុន ហ្គ្រីនហ្វីត។

- រាជរដ្ឋាភិបាលគួរបណ្តុះបណ្តាលបន្ថែម មន្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ ឲ្យយល់ដឹងពីការគ្រប់គ្រងតាមបែបវិមជ្ឈការ។

- សូមអោយរាជរដ្ឋាភិបាល ជួយសំរួល និងជំរុញដល់ដល់អ្នកវិនិយោគមកសាងសងរោងចក្រនៅមូលដ្ឋាន ដើម្បីផ្តល់ការងារជូនប្រជាពលរដ្ឋនៅជនបទ ជៀសផុតពីការចាកចោលលំនៅ

ដ្ឋាន មកកាន់ទីក្រុង និងក្រៅប្រទេស ដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃ។

# ប្រភពឯកសារយោង

- ផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំរបស់ឃុំជីពោទ៍ទី២ (២០១៧-២០២២)
- បញ្ជីគម្រោងវិនិយោគដែលបានស្នើឡើងរបស់ឃុំជីពោទី២ ក្នុងឆ្នាំ២០១៤
- លទ្ធិផលនៃការអនុវត្តគម្រោងរបស់ឃុំជីពោទ៍ទី២ ក្នុងឆ្នាំ២០១៤
- កម្មវិធីវិនិយោគឃុំរបស់ឃុំជីពោទ៍ទី២ ក្នុងឆ្នាំ២០១៥
- កម្មវិធីវិនិយោគឃុំរបស់ឃុំជីពោទី២ ក្នុងឆ្នាំ២០១៦
- សៀវភៅគម្រោងសាងសង់ផ្លូវក្រាលក្រួសក្រហមរបស់ឃុំជីពោទ៍ទី២ ក្នុងឆ្នាំ២០១៧
- ដកស្រង់ចេញពីរបាយការណ៍កម្មសិក្សារបស់និស្សិត ញ៉ ឌីលុច្ស និង នៃ ស្រីមុំ ឆ្នាំ ២០០៩-២០១៣ ក្រោមប្រធានបទ "ការអភិវឌ្ឍជនបទក្នុងទិសដៅកាត់បន្ថយភាពក្រីក្រ" សាស្ត្រាចារ្យណែនាំ បណ្ឌិត ឈុន ពហុ
- ដកស្រង់ចេញពីរបាយការណ៍កម្មសិក្សារបស់និស្សិត ឡៅ ធន់សោភ័ណ្ឌ និង អន សុខអេង ឆ្នាំសិក្សា ២០០៧-២០១១ ក្រោមប្រធានបទ "ការអភិវឌ្ឍសហគមន៍នៅក្នុងភូមិព្រៃទទឹង" សាស្ត្រាចារ្យណែនាំ បណ្ឌិត ឈុន ពហុ
- ដកស្រង់ចេញពីរបាយការណ៍កម្មសិក្សារបស់និស្សិត ម៉ូវ រ័ត្នធូ ស៊ីម ពិសិដ្ឋ និង ជឹម សំនៀង ឆ្នាំសិក្សា ២០០២-២០០៦ ក្រោមប្រធានបទ "ការអភិវឌ្ឍឃុំ សង្កាត់តាមបែបវិមជ្ឈការ (ករណីនៅឃុំកំពង់សំណាញ់)" សាស្ត្រាចារ្យណែនាំ បណ្ឌិត ឈុន ពហុ
- ដកស្រង់ចេញពីរបាយការណ៍កម្មសិក្សារបស់និស្សិត សារ៉េន វិច្ឆិរ៉ា ក្រោមប្រធានបទ" ដំណើរការនៃការអភិវឌ្ឍជនបទនៅក្នុងភូមិព្រៃគាវ ខេត្តស្វាយរៀង" សាស្ត្រាចារ្យណែនាំ ឱុយ ចាន់ឌីណា
- ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ៥ឆ្នាំលើកទី២(២០០១-២០០៥)ក្រសួងអភិវឌ្ឍន៍ជនបទ.ខែសីហា ឆ្នាំ២០០០
- ដកស្រង់ចេញពីនិក្ខេបបទថ្នាក់អនុបណ្ឌិត លោក ជា ចំរើន ប្រធានបទ " ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់បែបវិជ្ឈការ "
- ដកស្រង់ចេញពីសៀវភៅណែនាំស្ដីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់
- របាយការណ៍សមិទ្ធិផលការងាររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- របាយការណ៍បូកសរុបលទ្ធផលការងាររបស់ក្រសួងឧស្សាហាកម្ម និងសិប្បកម្មឆ្នាំ ២០១៧
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងឆ្នាំ២០១៦ ស្ដីពីរោងចក្រហ្គ្រីនហ្វីត

- ក្រសួងសេដ្ឋកិច្ច និងហេរញ្ញវត្ថុ ស្តីពីការកំណត់ប្រាក់ពន្ធតាមប្រភេទសេវាកម្មរថយន្តដឹកជញ្ជូនឆ្នាំ ២០១៧
- Michael P.Todro " Economic Development " Fifth Edition